ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសុខាភិបាល

សៀវភៅណែនាំស្តីពី
ការគ្រប់គ្រងព័ត៌មានវិទ្យាសុខាភិបាល
តាមរយៈគេហទំព័រ

ខែកញ្ញា ឆ្នាំ២០១១

មាតិកា

ជំពូក ១

ប្រព័ន្ធព័ត៌មានសុខាភិបាលសាធារណៈ ១

អំពីប្រព័ន្ធព័ត៌មានសុខាភិបាលតាមរយៈគេហទំព័រ ២

រចនាសម្ព័ន្ធរបស់ ប្រព័ន្ធព័ត៌មានសុខាភិបាលលើគេហទំព័រ ៣

តម្រូវការចាំបាច់សម្រាប់ដំណើរការប្រព័ន្ធព័ត៌មានសុខាភិបាលកម្ពុជាតាមរយៈគេហទំព័រ ៦

ជំពូក ២

ប្រព័ន្ធព័ត៌មានសុខាភិបាលសេវាឯកជន និងអង្គការមិនមែនរដ្ឋាភិបាល ៦៥

ជំពូក ៣

កម្មវិធីការបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូន តាមវិធីសាស្ត្រឆ្លើយតបរួមគ្នា ៨៨

ជំពូក ៤

ប្រព័ន្ធគ្រប់គ្រងទិន្នន័យមរណភាពមាតា ១០៨

ឧបសម្ព័ន្ធ

ឧបសម្ព័ន្ធប្រព័ន្ធព័ត៌មានសុខាភិបាល សេវាសាធារណៈ ១២៧

ឧបសម្ព័ន្ធប្រព័ន្ធព័ត៌មានសុខាភិបាល ផ្នែក PMTCT ១៥៥

ឧបសម្ព័ន្ធប្រព័ន្ធព័ត៌មានសុខាភិបាល ផ្នែកមរណភាពមាតា ១៥៩

អារម្ភកថា

ប្រព័ន្ធព័ត៌មានសុខាភិបាលដោះស្រាយអំពីតម្រូវការ ទិន្នន័យមានគុណភាពខ្ពស់ ត្រឹមត្រូវគ្រប់ជ្រុងជ្រោយ និងទាន់ពេលវេលាដើម្បីជាមូលដ្ឋានដល់ការតាក់តែងគោលនយោបាយ ផ្តែកលើភស្តុតាងការធ្វើផែនការការត្រួតពិនិត្យតាមដានស្នាដៃការងារនិងការវាយតម្លៃ។ ចំនុចផ្តោតជាចំបង គឺលើកស្ទួយ ការសម្របសម្រួល និងកិច្ចសហប្រតិបត្តិការទាំងក្នុង និងក្រៅវិស័យសុខាភិបាលតាមរយៈការចែករំលែកទិន្នន័យ ការគ្រប់គ្រង ការវិភាគ ការផ្សព្វផ្សាយនិងប្រើប្រាស់ ព្រមទាំងការដាក់បញ្ចូលព័ត៌មាន ពីវិស័យឯកជន អង្គការមិនមែនរដ្ឋាភិបាល និងពង្រីកការបណ្តុះបណ្តាលដើម្បីកសាងសមត្ថភាពប្រព័ន្ធ ព័ត៌មានសុខាភិបាល។

ដើម្បីទទួលបានជោគជ័យលើការអនុវត្តន៍ផែនការយុទ្ធសាស្ត្រសុខាភិបាលលើកទី២ ឆ្នាំ២០០៨-២០១៥ ក្រសួងសុខាភិបាលនៃព្រះរាជាណាចក្រកម្ពុជា បានបន្តនឹងកំពុងបន្តពង្រឹងប្រព័ន្ធព័ត៌មានសុខាភិបាល នៅគ្រប់កំរិតនៃប្រព័ន្ធសុខាភិបាលនៅកម្ពុជា តាមរយៈការផ្តួចផ្តើមគោលគំនិតនិងអនុវត្តបច្ចេកវិទ្យាថ្មីសម្រាប់គ្រប់គ្រងប្រព័ន្ធព័ត៌មានសុខាភិបាលក្រសួងសុខាភិបាលបានកំណត់ថាប្រព័ន្ធព័ត៌មានសុខាភិបាល គឺជាឧបករណ៍ដ៏សំខាន់សម្រាប់ឲ្យអ្នកគ្រប់គ្រងនៅថ្នាក់ជាតិ ថ្នាក់ខេត្ត និងថ្នាក់ស្រុក ប្រើប្រាស់ដើម្បីកំណត់ ការងារជាអាទិភាព ការធ្វើផែនការសកកម្មភាពហើយ និងធ្វើការបែងចែកធនធាន។ ហេតុដូច្នេះការពង្រឹង ប្រព័ន្ធព័ត៌មានសុខាភិបាលគឺ ជាអទិភាពមួយក្នុងចំនោមយុទ្ធសាស្ត្រនានារបស់ផែនការយុទ្ធសាស្ត្រ សុខាភិបាលលើកទី២ (២០០៨-២០១៥)។ ដោយទទួលស្គាល់នូវបញ្ហានេះហើយ ទើបគំនិតផ្តួចផ្តើមមួយចំនួន ត្រូវបានលើកយកមកពិភាក្សាដូចជា បច្ចេកទេស និងបច្ចេកវិទ្យា លើកការគ្រប់គ្រងប្រព័ន្ធព័ត៌មានសុខាភិបាលជាដើម។ ជាចុងក្រោយ ដើម្បីពង្រឹងគុណភាព និងពន្លឿនការបញ្ជូនទិន្នន័យ និងកាធ្វើរបាយការណ៍ សុខាភិបាលឲ្យបានប្រសើរឡើង នាយកដ្ឋានផែនការនិងព័ត៌មានសុខាភិបាលនៃក្រសួងសុខាភិបាល ដោយមានការឧបត្ថម្ភបច្ចេកទេសពីគម្រោងធ្វើអោយសេវាសុខាភិបាលប្រសើរឡើងរបស់អង្គការ URC ក្រោមជំនួយឧបត្ថម្ភថវិការពីទីភ្នាក់ងារសហរដ្ឋអាមេរិកដើម្បីការអភិវឌ្ឍន៍អន្តរជាតិ USAID បានបង្កើតប្រព័ន្ធឃ្លាំងទិន្នន័យព័ត៌មានសុខាភិបាលតាមរយៈគេហទំព័រហើយ ប្រព័ន្ធនេះបានដំណើរការចាប់ពី ឆ្នាំ២០១០ និងបានកំពុងបន្តដំណើរការដែលទទួលទិន្នន័យ ១០០% ពីមូលដ្ឋានសុខាភិបាល បន្ថែមពីនេះប្រព័ន្ធគ្រប់គ្រង់ទិន្នន័យតាមគេហទំព័របានបន្តបញ្ចូលបន្ថែមទិន្នន័យសុខាភិបាលពីមូលដ្ឋាសេវាឯកជន និងអង្គការមិនមែនរដ្ឋាភិបាល។ ក្រសួងសុខាភិបាល បានពង្រីកបន្ថែមបញ្ចូលទិន្នន័យ តាមរយៈខ្សែរបណ្តោយពីកម្មវិធីជាតិ ដោយចាប់ផ្តើមពីកម្មវិធីបង្កការការចម្លងមេរោគអេដស៍ពីម្តាយទៅកូន និងការឆ្លើយតបរួមគ្នា។

សៀវភៅណែនាំនេះបានរៀបចំឡើងដើម្បីជាជំនួយក្នុងការបណ្តុះបណ្តាល និងការគ្រប់គ្រងប្រព័ន្ធព័ត៌មានសុខាភិបាលដល់មន្ត្រីសុខាភិបាលផ្នែកសាធារណៈ ឯកជន និងអង្គការមិនមែនរដ្ឋាភិបាល ដែលបម្រើការងារជាបុគ្គលិកប្រព័ន្ធព័ត៌មានសុខាភិបាលនៅកម្ពុជា។

ក្រសួងសុខាភិបាលមានជំនឿយ៉ាងមុតមាំថា សៀវភៅនេះជាឧបករណ៍ដ៏សំខាន់មួយឈរលើចក្ខុវិស័យរួមសម្រាប់ថ្នាក់ដឹកនាំមន្ត្រីរាជការ បុគ្គលិកសុខាភិបាលទូទាំងប្រទេស ក្រសួង ស្ថាប័នពាក់ព័ន្ធ ដៃគូអភិវឌ្ឍន៍ និងអង្គការជាតិ អន្តរជាតិ ធ្វើសកម្មភាពរួមគ្នាដោយប្រសិទ្ធិភាព និងការទទួលខុសត្រូវខ្ពស់ ចំពោះការលើកស្ទួយ និងពង្រឹងប្រព័ន្ធព័ត៌មានសុខាភិបាល នឹងឈានទៅលើកកំពស់សុខភាព និងសុខុមាលភាពប្រជាជនកម្ពុជាទាំងអស់។

រាជធានីភ្នំពេញ, ថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០១១

សាស្ត្រាចារ្យ **អេង ហួត**

រដ្ឋលេខាធិការក្រសួងសុខាភិបាល

សេចក្តីថ្លែងអំណរគុណ

ក្រសួងសុខាភិបាលសូមវាយតម្លៃខ្ពស់ចំពោះមន្ត្រី និងថ្នាក់ដឹកនាំនៃក្រសួងសុខាភិបាល និងដៃគូមិនមែនសុខាភិបាល ដែលបានផ្តល់នូវការគាំទ្រ និងមគ្គុទេសភាពក្នុងការដឹកនាំនឹងកំពុងបន្តដំណើរការរៀបចំពង្រឹងប្រព័ន្ធព័ត៌មានសុខាភិបាលកម្ពុជាដោយរៀបចំចងក្រងសៀវភៅណែនាំ ស្តីពីការគ្រប់គ្រងប្រព័ន្ធព័ត៌មានសុខាភិបាលតាមរយៈគេហទំព័រនេះ។ សៀវភៅណែនាំនេះមានសារៈសំខាន់ណាស់សម្រាប់យកទៅប្រើប្រាស់ និងគ្រប់គ្រងទិន្នន័យសុខាភិបាលតាមរយៈគេហទំព័រ ដើម្បីតម្រង់ទិសការងារក្នុង វិស័យសុខាភិបាលលើការពង្រឹងគុណភាពប្រព័ន្ធព័ត៌មានសុខាភិបាលសម្រាប់អំឡុងពេលខាងមុខ និងដើម្បីប្រើប្រាស់ ជាអទិភាពសម្រាប់ចក្ខុវិស័យសុខាភិបាល។ សៀវភៅណែនាំនេះនឹងពុំអាចកើតចេញជារូបរាងបាន ទេប្រសិនបើគ្មានការខិតខំប្រឹងប្រែងយ៉ាងសកម្មរបស់ក្រុមការងារ តាមរយៈការប្រជុំពិភាក្សាសិក្ខាសាលាពិគ្រោះយោបល់ដែលបានប្រព្រឹត្តិទៅដោយមានការចូលរួមយ៉ាងសកម្ម និងផ្តល់យោបល់ដ៏មានតម្លៃពី៖

មន្ត្រីនាយកដ្ឋានផែនការ និងព័ត៌មានសុខាភិបាល

- លោកវេជ្ជបណ្ឌិត ឡូវាសនាគីរី ប្រធាននាយកដ្ឋានផែនការ និងប្រព័ន្ធព័ត៌មានសុខាភិបាល ក្រសួងសុខាភិបាល
- លោកស្រីវេជ្ជបណ្ឌិត ខោល ខេមរារី ប្រធានការិយាល័យព័ត៌មានសុខាភិបាល
- លោក ប៊ុត សាបេន អនុប្រធាន ការិយាល័យព័ត៌មានសុខាភិបាល
- លោកវេជ្ជបណ្ឌិត មាស វណ្ណថន មន្ត្រី ផ្នែកព័ត៌មានសុខាភិបាល
- លោកវេជ្ជបណ្ឌិត យក់ តារារិទ្ធ មន្ត្រី ផ្នែកព័ត៌មានសុខាភិបាល
- លោក សេក សុខណា មន្ត្រី ផ្នែកព័ត៌មានសុខាភិបាល

មន្ត្រីមក្មវិធីបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូន៖

- លោកស្រីវេជ្ជបណ្ឌិត វង្ស សាត្យាវ៉ានី ប្រធានកម្មវិធីបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូន
- លោកស្រី វេជ្ជបណ្ឌិត ទូន សុវណ្ណ អនុប្រធានក្មវិធីបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូន

គំរោងធ្វើអោយសេវាសុខាភិបាលកាន់តែប្រសើររបស់អង្គការយូរ អរ ស៊ី (URC)

- លោកវេជ្ជបណ្ឌិត មាន រតនសម្បត្តិ ប្រធានកម្មវិធីតាមដាន និងការវាយតម្លៃ និងព័ត៌មានវិទ្យា
- លោក ហុង រ័ត្ន អ្នកដឹកនាំសរសេរកម្មវិធីព័ត៌មានវិទ្យា

ក្រសួងសុខាភិបាលសូមកោតសរសើរ ចំពោះការខិតខំប្រឹងប្រែងអស់ពីកម្លាំងកាយចិត្តរបស់មន្ត្រីបុគ្គលិកនាយកដ្ឋានផែនការ និងប្រព័ន្ធព័ត៌មានសុខាភិបាលក្នុងដំណើរការនៃការរៀបចំប្រព័ន្ធព័ត៌មានសុខាភិបាល និងចងក្រងសៀវភៅនេះ។ សូមថ្លែងអំណរគុណជាពិសេសចំពោះលោកវេជ្ជបណ្ឌិត ឡូ វាសនាគីរី

ប្រធាននាយកដ្ឋានផែនការ និងប្រព័ន្ធព័ត៌មាន ដែលបានដឹកនាំការសម្របសម្រួលរៀបចំ និងចាត់ចែងការងាររៀបចំចងក្រងសៀវភៅណែនាំការគ្រប់គ្រងប្រព័ន្ធព័ត៌មានសុខាភិបាលតាមរយៈគេហទំព័រ។

សូមថ្លែងអំណរគុណចំពោះដៃគូអភិវឌ្ឍទាំងអង្គការក្រៅរដ្ឋាភិបាល និងលោក លោកស្រីទាំងអស់ ដែលបានរួមវិភាគទាន និងផ្តល់ការគាំទ្រដល់ការងារដ៏សំខាន់នេះពិសេសគម្រោងធ្វើអោយ សេវាសុខាភិបាលកាន់តែប្រសើររបស់អង្គការ យូរ អរ ស៊ី (URC) ក្រោមជំនួយឧបត្ថម្ភពីទីភ្នាក់ងារសហរដ្ឋអាមេរិកដើម្បីការអភិវឌ្ឍន៍អន្តរជាតិ (USAID) ដែលបានផ្តល់ជំនួយបច្ចេកទេ និងថវិការបម្រាប់ដំណើរការរៀបចំសៀវភៅណែនាំការគ្រប់គ្រងប្រព័ន្ធព័ត៌មានសុខាភិបាលតាមរយៈគេហទំព័រ៕

គោលការណ៍ណែនាំ
សម្រាប់ការគ្រប់គ្រងប្រព័ន្ធព័ត៌មានវិទ្យាសុខាភិបាលកម្ពុជា
តាមរយៈគេហទំព័រ

✵✵✵✵✵

ជំពូក ១
ប្រព័ន្ធព័ត៌មានវិទ្យាសុខាភិបាលសាធារណៈ

អំពីប្រព័ន្ធព័ត៌មានវិទ្យាសុខាភិបាលតាមរយៈគេហទំព័រ

ការគ្រប់គ្រងផ្នែកសុខាភិបាលដ៏ល្អមួយ គឺជាធនធានដ៏សំខាន់បំផុត សម្រាប់ការត្រួតពិនិត្យ វាយតម្លៃស្ថានភាព សុខភាពរបស់ប្រជាជន និងគុណភាពសេវាសុខាភិបាលទូទាំងប្រទេស។ ការត្រួតពិនិត្យអាចធ្វើទៅបានទាន់ពេលវេលាទាមទារអោយមានព័ត៌មាន និងទិន្នន័យត្រឹមត្រូវ និងទាន់ពេលវេលាពីប្រភពខុសៗគ្នាដូចជា ពីមន្ទីរពេទ្យ និងមណ្ឌលសុខភាពសាធារណៈ ព្រមទាំងអ្នកផ្តល់សេវាសុខាភិបាលរបស់អង្គការក្រៅរដ្ឋាភិបាល និងមូលដ្ឋានសុខាភិបាលឯកជន។ ការធ្វើបច្ចុប្បន្នភាពលើប្រព័ន្ធឃ្លាំងទិន្នន័យសុខាភិបាលមានសារៈសំខាន់ណាស់ចំពោះអ្នកគ្រប់គ្រង់សេវាសុខាភិបាលសំរាប់ឆ្លុះបញ្ចាំងឃើញពីភាពជឿនលឿន ឬខ្វះខាតក្នុងការផ្តល់សេវាសុខាភិបាល និងដើម្បីកែលំអរលើការផ្តល់សេវាសុខាភិបាលនៅកម្ពុជា។ ការពង្រឹង និងគ្រប់គ្រងប្រព័ន្ធព័ត៌មានប្រកបដោយប្រសិទ្ធិភាព គឺជាបុព្វហេតុឆ្ពោះទៅដល់ការគ្រប់គ្រងដ៏ល្អមួយលើចក្ខុវិស័យសុខាភិបាល។ ប្រព័ន្ធព័ត៌មានវិទ្យាសុខាភិបាលតាមរយៈគេហទំព័រ គឺជាការគ្រប់គ្រងទិន្នន័យសុខាភិបាលដែលមានលក្ខណៈទំនើប និងងាយស្រួលបញ្ចូលទិន្នន័យពីមូលដ្ឋានសុខាភិបាលទាំងឡាយ ដូចជាទំរង់របាយការណ៍ប្រចាំខែសម្រាប់មណ្ឌលសុខភាព និងសម្រាប់មន្ទីរពេទ្យ និងត្រូវបានគេរក្សារទុកដើម្បីទាញយកមកប្រើប្រាស់និងដំណើរការ សម្រាប់ការធ្វើសេចក្តីសម្រេចចិត្ត និងការធ្វើផែនការនានាទាំងនៅថ្នាក់ជាតិ ថ្នាក់ខេត្ត ថ្នាក់ស្រុក និងមូលដ្ឋានសុខាភិបាល។ អាស្រ័យហេតុនេះ ប្រព័ន្ធព័ត៌មានវិទ្យាសុខាភិបាលតាមរយៈគេហទំព័របានផ្តល់នូវឧបករណ៍ថ្មីមួយទៀតសម្រាប់អ្នកគ្រប់គ្រង់ផ្នែកសុខាភិបាល ក៏ដូចជាបុគ្គលិក និងមន្ត្រីសុខាភិបាលដោយអនុញ្ញាតអោយទាញយកទិន្នន័យដោយផ្ទាល់ចេញពីប្រភពទិន្នន័យដើម។ ដូច្នេះអាចបញ្ចៀសបាននូវភាពយឺតយ៉ាវ និងកំហុសនានា ដែលអាចកើតចេញពីទម្រង់ទិន្នន័យនៅលើក្រដាស ការបញ្ជូន និងការបញ្ចូលទិន្នន័យ។ លើសពីនេះទៅទៀតការប្រមូលទិន្នន័យភ្លាមៗអាចជួយដល់ការធ្វើសេចក្តីសម្រេចចិត្ត និងការចូលរួមពីអ្នកពាក់ព័ន្ធ។ នាយកដ្ឋានផែនការ និងព័ត៌មានសុខាភិបាល របស់ក្រសួងសុខាភិបាលក្រោមជំនួយថវិកាពីទីភ្នាក់ងារសហរដ្ឋអាមេរិកសម្រាប់អភិវឌ្ឍអន្តរជាតិ តាមរយៈគម្រោងធ្វើអោយសេវាសុខាភិបាលកាន់តែប្រសើររបស់អង្គការ យូ អរ ស៊ី បានបង្កើតប្រព័ន្ធព័ត៌មានវិទ្យាសុខាភិបាលតាមរយៈគេហទំព័រថ្មីមួយដោយប្រើប្រាស់ទំរង់ព័ត៌មានដើមដូចគ្នាទៅនឹងប្រព័ន្ធព័ត៌មានសុខាភិបាលប្រើប្រាស់ពីមុននៅលើកម្មវិធី MS Access (ត្រូវបានបង្កើតក្នុងឆ្នាំ២០០៦ និងកែលម្អក្នុងឆ្នាំ ២០០៩) ប្រព័ន្ធថ្មីតាមរយៈគេហទំព័រត្រូវបានបង្កើតឡើងដោយប្រើះ

- *កម្មវិធី MySQL* ជាប្រព័ន្ធគ្រប់គ្រងទិន្នន័យដែលមានទំនាក់ទំនងនឹងគ្នាទៅវិញទៅមកធ្វើការនៅលើ *Server* មួយដែលអនុញ្ញាតអោយអ្នកប្រើប្រាស់ ប្រើបានច្រើនគ្នាក្នុងលក្ខណៈមួយដែលងាយស្រួលគ្រប់គ្រងនូវប្រព័ន្ធ ព័ត៌មានសុខាភិបាលព្រមទាំងអាចបង្កើតកម្មវិធីនានាទៅអនាគត។
- *កម្មវិធី PHP* ជាភាសាកម្មវិធីសម្រាប់មូលដ្ឋានទិន្នន័យមួយដែលប្រើប្រាស់បានយ៉ាងទូលំទូលាយតាមរូបភាពនានានៃសកម្មភាព។
- *កម្មវិធី Apache* ជាកម្មវិធីមួយរបស់ *Web Server* ត្រូវបានប្រើជាពិសេសសម្រាប់ទាំងព័ត៌មានដែលមានលក្ខណៈបេរ និងគេហទំព័រដែលមានលក្ខណៈងាយស្រួយប្រែប្រួលយ៉ាងរស់រវើកនៅលើប្រព័ន្ធ *World Wide Web*។

ប្រព័ន្ធឃ្លាំងទិន្នន័យព័ត៌មានសុខាភិបាលតាមរយៈគេហទំព័រត្រូវបានកែលម្អក្នុងបីដំណាក់កាលដូចខាងក្រោម៖

- *ដំណាក់កាលទីមួយ (HIS 1.0) ៖* បានបង្កើតកម្មវិធី *HIS MySQL/PHP* ថ្មីហើយបានផ្ទេរពាល់ទិន្នន័យរបស់ព័ត៌មានសុខាភិបាលដែលមានស្រាប់ទាំងអស់ទៅកាន់ប្រព័ន្ធទិន្នន័យថ្មី។ នេះគឺជាកម្មវិធីមួយតាមរយៈគេហទំព័រដែលមានមុខងារទំនើប ប្រើសម្រាប់បញ្ចូល ត្រួតពិនិត្យ និងកែសម្រួលព័ត៌មានសុខាភិបាលនៅគ្រប់កម្រិតទាំងអស់ ។
- *ដំណាក់កាលទីពីរ (HIS 2.0) ៖* ការបង្កើតមុខងារជាន់ខ្ពស់សម្រាប់ការធ្វើរបាយការណ៍ដែលឆ្លុះបញ្ចាំងនូវសូចនាករណ៍សំខាន់ៗក្នុងផែនការយុទ្ធសាស្រ្តសុខាភិបាលថ្នាក់ជាតិ HSP2 និងគោលដៅអភិវឌ្ឍសហស្សវត្សរ៍ (*MDG*)។ នាយកដ្ឋានផែនការនិងប្រព័ន្ធព័ត៌មានវិទ្យាសុខាភិបាល នឹងបន្តសហការជាមួយគម្រោងធ្វើឲ្យសេវាសុខភាពកាន់តែល្អប្រសើររបស់អង្គការ យូ អរ ស៊ី ក្រោមជំនួយថវិកាពីទីភ្នាក់ងារសហរដ្ឋអាមេរិកសម្រាប់អភិវឌ្ឍអន្តរជាតិ តែក៏អាចមានឱកាសសម្រាប់ការចូលរួមជាមួយដៃគូដទៃទៀតដែរ ក្នុងការរៀបចំការបណ្ដុះបណ្ដាលសម្រាប់បុគ្គលិក និងការផ្ដល់ជំនួយបច្ចេកទេសនៅថ្នាក់មូលដ្ឋាន ការណែនាំពីការធ្វើរបាយការណ៍ និងការប្រមូលទិន្នន័យសម្រាប់គម្រោង។
- *ដំណាក់កាលទីបី ៖* នឹងបង្កើតយន្តការចាំបាច់សម្រាប់បញ្ចូលប្រព័ន្ធទិន្នន័យផ្សេងៗទៀតទៅក្នុងប្រព័ន្ធព័ត៌មានសុខាភិបាលពិសេស គឺប្រព័ន្ធទិន្នន័យទាំងឡាយនៅក្នុងកម្មវិធីផ្សេងៗពីកម្មវិធីដែលមានរចនាសម្ព័ន្ធជាខ្សែបណ្ដោយ។

ការរៀបចំចងក្រងសៀវភៅណែសម្រាប់ការប្រើប្រាស់ HMIS Web Based Database ត្រូវបានបែងចែកជា ៥ ផ្នែកធំៗ៖ (១) តំរូវការចាំបាច់សម្រាប់ដំណើរការប្រព័ន្ធព័ត៌មានវិទ្យាសុខាភិបាលកម្ពុជានៅលើគេហទំព័រ (២) របៀបប្រើប្រាស់ HMIS Web Based Database នៅលើគេហទំព័រ (៣) ប្រភេទរបាយការណ៍ (៤) របៀបប្រើប្រាស់របាយការណ៍ (៥) នាំចូលនាំចេញ និងគ្រប់គ្រងអ្នកប្រើ។

រចនាសម្ព័ន្ធរបស់ ប្រព័ន្ធព័ត៌មានវិទ្យាសុខាភិបាលលើគេហទំព័រ៖

- បង្ហាញទិន្នន័យ
- បញ្ចូលទិន្នន័យ
- កែសម្រួលទិន្នន័យ
- បញ្ជីរបាយការណ៍
- គំរូរបាយការណ៍ប្រចាំខែ
- របាយការណ៍សូចនាករ
- នាំចូលនាំចេញ
- គ្រប់គ្រងអ្នកប្រើប្រាស់
- ចាកចេញ

ក. បង្ហាញទិន្នន័យ

Menu "បង្ហាញទិន្នន័យ" ប្រើសម្រាប់បង្ហាញទិន្នន័យទាំងអស់ដូចបានរៀបរាប់ខាងលើ។ អ្នកអាចមើល និងទាញយកទិន្នន័យអត្រាប្រជាជន ស្ថិតិប្រជាជន មូលដ្ឋានសុខាភិបាលសាធារណៈ មូលដ្ឋានសុខាភិបាលឯកជន និងសម្រាប់អង្គការ ទូទាំងប្រទេស (ជាថ្នាក់ជាតិ) តាមខេត្ត ស្រុកប្រតិបត្តិ និងមូលដ្ឋានសុខាភិបាល។ នៅលើ Menu "បង្ហាញទិន្នន័យ" នេះអ្នកក៏អាចមើល និងទាញយកទិន្នន័យរបស់មណ្ឌលសុខភាព មន្ទីរពេទ្យ ទិន្នន័យសេវាឯកជន អង្គការ និងទិន្នន័យមរណៈភាពមាតា។ ទិន្នន័យទាំងនោះត្រូវបានបែងចែកទៅតាមខេត្ត ស្រុកប្រតិបត្តិ និងតាមឆ្នាំនីមួយៗ ហើយអ្នកអាចមើលទៅលើមូលដ្ឋានសុខាភិបាលណាមួយដែលអ្នកចង់មើល ដោយធ្វើការជ្រើសរើសយកតែឈ្មោះមូលដ្ឋានសុខាភិបាលនោះ ម៉្យាងវិញទៀត អ្នកក៏អាចទាញយកជាឯកសារ Excel ដែរទេ។

ខ. បញ្ចូលទិន្នន័យ

នៅលើ Menu "បញ្ចូលទិន្នន័យ" នេះ មានលក្ខណៈជាដែនកំណត់ចំពោះមណ្ឌលសុខភាព មន្ទីរពេទ្យ ស្រុកប្រតិបត្តិ និងមន្ទីរសុខាភិបាល។ ក្នុងចំណុចនេះមូលដ្ឋានសុខាភិបាលនីមួយៗ អាចមានសិទ្ធិត្រឹមតែបញ្ចូលនូវទិន្នន័យរបស់ខ្លួនទៅលើមូលដ្ឋានសុខាភិបាលដែលខ្លួនប្រតិបត្តិប៉ុណ្ណោះ។

គ. កែសម្រួលទិន្នន័យ

"កែសម្រួលទិន្នន័យ" គឺជា Menu មួយដែលមានលក្ខណៈប្រុងប្រយ័ត្ន ពីព្រោះមិនមែនគ្រប់គ្នាដែលធ្វើប្រតិបត្តិការនៅលើប្រព័ន្ធព័ត៌សុខាភិបាលកម្ពុជា តាមរយៈគេហទំព័រនេះសុទ្ធតែអាចធ្វើការកែសម្រួលទិន្នន័យបានទាំងអស់នោះទេ។ ដូចដែលនៅក្នុង Menu បញ្ចូលទិន្នន័យដូច្នោះដែរ គឺមូលដ្ឋានសុខាភិបាលនីមួយៗអាចមានសិទ្ធិតែលើមូលដ្ឋានសុខាភិបាលរបស់ខ្លួនប្រតិបត្តិ និងអាចធ្វើការកែសម្រួលទិន្នន័យនោះ។

ឃ. បញ្ជីរបាយការណ៍

បញ្ជីរបាយការណ៍ គឺជា Menu សំរាប់អ្នកប្រើប្រាស់ទូទៅ។ អ្នកអាចដឹងបានថា តើមូលដ្ឋានសុខាភិបាលណាមួយដែលមានការយឺតយ៉ាវក្នុងការផ្ញើរបាយការណ៍ ជាពិសេស អាចជួយដល់អ្នកគ្រប់គ្រងក្នុងការផ្តល់ព័ត៌មានត្រឡប់ទៅដល់មូលដ្ឋានសុខាភិបាលក្នុងការបញ្ជូនទិន្នន័យអោយទាន់ពេលវេលា។

ង. គំរូរបាយការណ៍ប្រចាំខែ

គំរូរបាយការណ៍ប្រចាំខែ មាន HO2 ជារបាយការណ៍សម្រាប់មន្ទីរពេទ្យ និង HC1 ជារបាយការណ៍សម្រាប់មណ្ឌលសុខភាពប្រើប្រាស់។ អ្នកគ្រប់គ្រងមន្ទីរពេទ្យ និងមណ្ឌលសុខភាពក៏អាចប្រើ HO2 និង HC1 នេះបានដើម្បីបូកសរុបលទ្ធផលប្រចាំត្រីមាស ប្រចាំឆមាស និងប្រចាំឆ្នាំ។

ច. របាយការណ៍សូចនាករ

សូចនាករ គឺមានសារៈសំខាន់សំរាប់មូលដ្ឋានសុខាភិបាលនីមួយៗ ដើម្បីកំណត់រកភាពខ្លាំង ភាពខ្សោយ និងរៀបចំផែនការបន្ត ដូច្នេះហើយ Menu របាយការណ៍សូចនាករ មានអត្ថប្រយោជន៍ចំបងសំរាប់អ្នកប្រើប្រាស់គ្រប់រូប។

ឆ. នាំចូលនាំចេញ

Menu "នាំចូលនាំចេញ" នេះ គឺប្រើក្នុងករណីដែលមិនមាន Internet ប្រើប្រាស់នៅកន្លែងមូលដ្ឋានសុខាភិបាលដែលខ្លួនប្រតិបត្តិ។ គេអាចបញ្ចូលទិន្នន័យបានតាមរយៈការប្រើប្រាស់ម៉ាស៊ីនកុំព្យូទ័របន្ទាប់មកគេអាចយកទិន្នន័យនេះបញ្ចូលទៅក្នុងគេហទំព័របាននៅកន្លែងណាដែលមាន Internet ប្រើប្រាស់។

ជ. គ្រប់គ្រងអ្នកប្រើប្រាស់

"គ្រប់គ្រងអ្នកប្រើប្រាស់" គឺជា Menu សម្រាប់គ្រប់គ្រងទៅលើអ្នកដែលមានសិទ្ធិប្រើប្រាស់លើប្រព័ន្ធនេះ មានតែក្រសួងសុខាភិបាលប៉ុណ្ណោះ ដែលមានសិទ្ធិក្នុងការបង្កើតឈ្មោះអ្នកប្រើប្រាស់ និងលេខកូដសំងាត់។

I- តម្រូវការចាំបាច់សម្រាប់ដំណើរការប្រព័ន្ធព័ត៌មានវិទ្យាសុខាភិបាលកម្ពុជានៅលើគេហទំព័រ

គេហទំព័រប្រព័ន្ធព័ត៌មានវិទ្យាសុខាភិបាលកម្ពុជានេះ គឺបានបង្កើតឡើងដោយប្រើភាសាសរសេរកម្មវិធី PHP&MySQL ដើម្បីតំណើរការនៅលើគេហទំព័រជាលក្ខណៈសកល។ បច្ចេកវិទ្យាដែលត្រូវបានក្រុមការងារសរសេរកូដកម្មវិធីនេះឡើងគឺតម្រូវចាំបាច់អោយកុំព្យូទ័រទាំងអស់ត្រូវមានកម្មវិធីសម្រាប់តំណើរការ Internet ដែលគេហៅជាភាសាអង់គ្លេសថា៖ Mozilla Firefox និងពុម្ពអក្សរខ្មែរដែលមានលក្ខណៈស្តង់ដាគឺ Khmer Unicode សម្រាប់ការមើលដែលល្អបំផុត។

១. ការចាប់ផ្តើមដំណើរការគេហទំព័រ (តើធ្វើដូម្តេចដើម្បីចូលទៅក្នុងប្រព័ន្ធ)

- វាយបញ្ចូលឈ្មោះគេហទំព័រ www.hiscambodia.org (មើលរូបភាព១ លេខ១)
- វាយបញ្ចូល "ឈ្មោះអ្នកប្រើ"។ ឧទាហរណ៍៖ msambath (មើលរូបភាព១ លេខ២)
- វាយបញ្ចូល "លេខសំងាត់"។ ឧទាហរណ៍៖ ****** (មើលរូបភាព១ លេខ៣)
- វាយបញ្ចូល "កូដបញ្ជាក់" ចំនួនប្រាំខ្ទង់។ ឧទាហរណ៍៖ ៧១៧៩៦
- ចុចប្រអប់ "ចូលប្រើប្រាស់" (មើលរូបភាព១ លេខ៥)
- បន្ទាប់មកអ្នកនឹងឃើញដូចរូបភាព ២ខាងក្រោម

រូបភាព ១



II. របៀបប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងព័ត៌មានសុខាភិបាលតាមរយៈគេហទំព័រ (HMIS)

ជាដំបូងអ្នកត្រូវចូលទៅកាន់ទំព័រដើមរបស់គេហទំព័រ (សូមមើលលេខ១ "ការចាប់ផ្តើមដំណើរការគេហទំព័រ" និងរូបភាព១ ពីលេខ១ ដល់លេខ៥)។ បន្ទាប់មកអ្នកនឹងបានឃើញរូបភាព២ ខាងក្រោមនេះ៖

- ចុចលើ "MOH-HIS" (រូបភាព២ លេខ១) បន្ទាប់មកអ្នកនឹងបានចូលទៅកាន់ប្រព័ន្ធព័ត៌មានសុខាភិបាលកម្ពុជា ដូចនៅរូបភាព៣ បង្ហាញ។

រូបភាព ២ (សម្រាប់ចូលទៅកាន់ប្រព័ន្ធគ្រប់គ្រងព័ត៌មានសុខាភិបាលកម្ពុជា)



រូបភាព ៣ (រូបភាពទំព័រដំបូងរបស់ HMIS)



១. បង្ហាញទិន្នន័យ (តើត្រូវពិនិត្យទិន្នន័យតាមរបៀបណា?)

- ដាក់ Mouse លើ Menu "បង្ហាញទិន្នន័យ" (មើលរូបភាព៤ លេខ១)
- ឧទាហរណ៍ ៖ យើងចង់បង្ហាញ "ទិន្នន័យមន្ទីរពេទ្យ"
- ចុចលើទិន្នន័យមន្ទីរពេទ្យ (មើលរូបភាព៤ លេខ២)
- ជ្រើសរើសឆ្នាំ ខែ ក្នុងប្រអប់ "សូមជ្រើសរើសកាលបរិច្ឆេទ" និងជ្រើសរើសខេត្ត ស្រុកប្រតិបត្តិ និងប្រភេទមូលដ្ឋានសុខាភិបាលនៅក្នុងប្រអប់ "សូមជ្រើសរើសទីតាំង"

រូបភាព ៤ (គំរូសម្រាប់ជ្រើសរើសការបង្ហាញទិន្នន័យរបស់មន្ទីរពេទ្យ)



- ឧទាហរណ៍៖ អ្នកជ្រើសរើសឆ្នាំ ២០១០ ខែ កញ្ញា ខេត្តបន្ទាយមានជ័យ ស្រុកប្រតិបត្តិ មង្គលបូរី មន្ទីរពេទ្យបង្អែកសេរីសោភ័ណ (មើលរូបភាព៥ លេខ១ ដល់លេខ៥)
- បន្ទាប់ចុចលើប្រអប់ "ចាប់ផ្តើមការបង្ហាញទិន្នន័យ" (មើលរូបភាព៥ លេខ៦)
- អ្នកនឹងបានឃើញរូបភាពបង្ហាញដូចក្នុងរូបភាព ៦

រូបភាព ៥ (របៀបជ្រើសរើសមូលដ្ឋានសុខាភិបាលដើម្បីបង្ហាញទិន្នន័យ)



រូបភាព ៦ (គំរូនៃការពិនិត្យទិន្នន័យ ពិនិត្យពិគ្រោះជម្ងឺក្រៅ)



បរិមាណសកម្មភាព	ក្នុងស្រុកប្រតិបត្តិ/ខេត្ត	ក្រៅស្រុកប្រតិបត្តិ/ខេត្ត	សរុប	ប្រុស	ស្រី
ចំនួនករណីថ្មីដែលបញ្ជូនមកពីមណ្ឌលសុខភាព	11	5	16	6	10
ចំនួនករណីថ្មីមកពិនិត្យដោយខ្លួនឯងនៅមន្ទីរពេទ្យ	910	141	1051	330	721
ពិគ្រោះជំងឺសរុប	1108	146	1254	336	918

- អ្នកអាចជ្រើសរើសទំព័រណាមួយផ្សេងទៀតនៅក្នុងប្រអប់ "ជ្រើសរើសទំព័រ" (មើលរូបភាព៧ លេខ១)

- ប្រសិនបើអ្នកចង់បានទិន្នន័យជាឯកសារ Excel នៃក្នុងទំព័រនេះ ចុចលើប្រអប់ "នាំចេញ" (រូបភាព៧ លេខ២)

រូបភាព ៧ (គំរូសម្រាប់ការជ្រើសរើសបញ្ហាសុខភាព)



- បន្ទាប់មកចុចលើ "Open with" សម្រាប់បើកមើលទិន្នន័យដោយស្វ័យប្រវត្តិ និងចុចលើប្រអប់ "Save File" ដើម្បី ថតរក្សាឯកសារទុក រួចចុចពាក្យ "OK" (រូបភាព៨ ពីលេខ១ ដល់លេខ៣)
- អ្នកនឹងបានឯកសារជា Excel ដូចនៅរូបភាព ៩

រូបភាព ៨ (របៀបនៃការរក្សាទុក និងបើករបាយការណ៍)



រូបភាព ៩ (គំរូរបាយការណ៍ក្នុង Excel)



ពិនិត្យពិគ្រោះជំងឺក្រៅ					
បរិមាណសកម្មភាព	ក្នុងស្រុកប្រតិបត្តិ	ក្រៅស្រុកប្រតិបត្តិ	សរុប	ប្រុស	ស្រី
ចំនួនករណីថ្មីដែលបញ្ជូនមកពីមណ្ឌលសុខភាព	11	5	16	6	10
ចំនួនករណីថ្មីមកពិនិត្យដោយខ្លួនឯងនៅមន្ទីរពេទ្យ	910	141	1051	330	721
ពិគ្រោះជំងឺសរុប	1108	146	1067	336	918

២. បញ្ចូលទិន្នន័យ (តើត្រូវបញ្ចូលទិន្នន័យតាមរបៀបណា?)

- ដើម្បីបញ្ចូលទិន្នន័យបាន អ្នកត្រូវចូលទៅកាន់គេហទំព័រដើមរបស់ប្រព័ន្ធដូចទៅនឹងការបង្ហាញទិន្នន័យដូច្នោះដែរ។ ឧទាហរណ៍ថា *អ្នកនឹងបញ្ចូលទិន្នន័យរបស់មន្ទីរពេទ្យបង្អែកព្រះនេត្រព្រះ ស្ថិតក្នុងស្រុកប្រតិបត្តិ ព្រះនេត្រព្រះ ខេត្តបន្ទាយមានជ័យ នៅខែកញ្ញា ឆ្នាំ២០១១។*
- ដាក់ Mouse លើ Menu "បញ្ចូលទិន្នន័យ" រួចចុចលើ "ទិន្នន័យមន្ទីរពេទ្យ" (មើលរូបភាព១០ លេខ ១ និងលេខ២)

រូបភាព ១០ (គំរូសម្រាប់បង្ហាញការបញ្ចូលទិន្នន័យ)



- ជ្រើសរើសយកខែ ឆ្នាំ នៅក្នុងប្រអប់ "សូមជ្រើសរើសកាលបរិច្ឆេទ" (រូបភាព១១ លេខ១ និង២) និងជ្រើសរើសយកខេត្ត ស្រុកប្រតិបត្តិ និងមូលដ្ឋានសុខាភិបាលនៅក្នុងប្រអប់ "សូមជ្រើសរើសទីតាំង" (រូបភាព១១ លេខ៣ ដល់លេខ៥) និងចុចលើ "ចាប់ផ្តើមបញ្ចូលទិន្នន័យ" (រូបភាព១១ លេខ៦)។

រូបភាព ១១ (របៀបជ្រើសរើសមូលដ្ឋានសុខាភិបាលដើម្បីបញ្ចូលទិន្នន័យ)



- បន្ទាប់ពីជ្រើសរើស រួចចុចលើប្រអប់ "ចាប់ផ្តើមបញ្ចូលទិន្នន័យ" អ្នកនឹងអាចចាប់ផ្តើមបញ្ចូលទិន្នន័យបាន (មើលរូបភាព ១២)
- ក្នុងករណីដែលអ្នកបានឃើញអក្សរពណ៌ក្រហមបង្ហាញមកនូវពាក្យ "សូមពិនិត្យទិន្នន័យឡើងវិញ" (រូបភាព១២ លេខ១) នោះបញ្ជាក់ថា ទិន្នន័យដែលអ្នកបាននឹងកំពុងបញ្ចូលគឺ *មិនត្រឹមត្រូវទេ* ដូច្នេះសូមធ្វើការពិនិត្យមើលទិន្នន័យឡើងវិញ។
- បន្ទាប់ពីបានបញ្ចូលទិន្នន័យនៅទំព័រនេះចប់ អ្នកអាចចូលទៅកាន់ទំព័របន្តបន្ទាប់ ដោយគ្រាន់តែចុចនៅលើពាក្យ "ទៅទំព័របន្ទាប់" រួចទិន្នន័យនៅលើទំព័រនេះនឹងត្រូវបានរក្សាទុកដោយស្វ័យប្រវត្តិ (រូបភាព១២ លេខ២)។
- បន្ទាប់ពីបញ្ចប់ការបញ្ចូលទិន្នន័យនៅទំព័រចុងក្រោយ អ្នកអាចចុចលើពាក្យ "បញ្ចប់ប្រតិបត្តិការ" (រូបភាព១៣ លេខ១)
- ប្រសិនបើអ្នកមិនទាន់ចុច "បញ្ចប់ប្រតិបត្តិការ" ទេ អ្នកអាចចុចលើប្រអប់ "ត្រឡប់មកទំព័រមុន" ក្នុងករណីដែលអ្នកចង់មើលបញ្ជាក់នៅទំព័រមុននោះ (រូបភាព១៣ លេខ២)

រូបភាព ១២ (គំរូនៃការបញ្ចូលទិន្នន័យ ពិនិត្យពិគ្រោះជម្ងឺក្រៅ)



រូបភាព ១៣ (គំរូនៃការបញ្ចូលទិន្នន័យ ពិនិត្យពិគ្រោះជម្ងឺក្រៅ)



<u>ចំណាំ៖</u>

១. អ្នកនឹងបានឃើញនៅក្នុងប្រអប់សម្រាប់បញ្ចូលទិន្នន័យមួយចំនួន មានពណ៌ទឹកក្រូច ជាពិសេសនៅលើប្រអប់សរុប បានន័យថា អ្នកមិនចាំបាច់បញ្ចូលទិន្នន័យសរុបក្នុងប្រអប់នោះទេ ព្រោះប្រព័ន្ធនឹងធ្វើការបូកសរុបនៅពេលដែលតួរលេខត្រូវបានបញ្ចូល។

២. ដោយឡែកក្នុងប្រអប់មួយចំនួនមានពណ៌ខៀវ នោះបញ្ជាក់ថា អ្នកមិនអាចធ្វើការបញ្ចូលទិន្នន័យក្នុងប្រអប់នោះទេ(ប្រអប់ពណ៌ខៀវមិនត្រូវមានទិន្នន័យ) ។

៣. កែសម្រួលទិន្នន័យ (តើត្រូវធ្វើដូម្ដេចដើម្បីកែសម្រួលទិន្នន័យ?)

Menu "កែសម្រួលទិន្នន័យ" ប្រើសម្រាប់ធ្វើការកែប្រែទិន្នន័យដែលបានបញ្ចូលខុស ឬលុបទិន្នន័យដែលមិនត្រឹមត្រូវ។ អ្នកអាចធ្វើការកែសម្រួលទិន្នន័យទៅតាមទំព័រនីមួយៗបាន ឬលុបទិន្នន័យចោលទាំងស្រុងក៏បាន។

- ដាក់ Mouse លើ Menu "កែសម្រួលទិន្នន័យ" រួចចុចលើ "ទិន្នន័យមន្ទីរពេទ្យ" (មើលរូបភាព១៤ លេខ១ និងលេខ២)
- ជ្រើសរើសមូលដ្ឋានសុខាភិបាលដែលយើងចង់កែសម្រួលទិន្នន័យ។ ឧទាហរណ៍៖ *អ្នកចង់កែសម្រួល ទិន្នន័យដែលបានបញ្ចូលសាកល្បងនៅចំណុចបញ្ចូលទិន្នន័យខាងលើ* (មើលរូបភាព១៥ ពីលេខ១ដល់លេខ៦)

រូបភាព ១៤



ចំណាំ៖ ការកែសម្រួលទិន្នន័យត្រូវធ្វើមុនថ្ងៃទី ២០នៃខែបន្ទាប់នីមួយៗ។

រូបភាព ១៥ (របៀបជ្រើសរើសមូលដ្ឋានសុខាភិបាលដើម្បីកែសម្រួលទិន្នន័យ)

- ក្នុងពេលដែលអ្នកកែប្រែទិន្នន័យ អ្នកក៏អាចបន្តការបញ្ចូលទិន្នន័យដែលអ្នកបានផ្អាកពីលើកមុន
- ប្រសិនបើទិន្នន័យដែលអ្នកបានកែប្រែរួចត្រឹមត្រូវនោះ អក្សរពណ៌ក្រហមនឹងបាត់ទៅវិញ (សូមមើលរូបភាព១៣ លេខ១ និងរូបភាព១៦)
- អ្នកអាចកែប្រែទិន្នន័យនៅគ្រប់ទំព័រ ដោយចុចនៅក្នុងប្រអប់ "ជ្រើសរើសទំព័រ" (រូបភាព១៦ លេខ១)
- បន្ទាប់ពីអ្នកបានកែប្រែទិន្នន័យរួចរាល់ ចុចនៅលើប្រអប់ "រក្សាទុកទិន្នន័យ" ឬ "បញ្ចប់ប្រតិបត្តិការ" (រូបភាព១៦ លេខ២ និងលេខ៣)

រូបភាព១៦ (គំរូសម្រាប់ជ្រើសរើសទំព័រដើម្បីកែសម្រួលទិន្នន័យ)



III. អំពីរបាយការណ៍

នៅក្នុងប្រព័ន្ធព័ត៌មានវិទ្យាសុខាភិបាលកម្ពុជាតាមរយៈគេហទំព័រ ជាភាសាអង់គ្លេសដែលគេហៅថា HMIS Web Database បានប្រមូលផ្តុំរបាយការណ៍ចំបងៗចំនួន ៤ ក្នុងនោះរួមមាន៖

១. បញ្ជីរបាយការណ៍ (Inventory Report)

២. របាយការណ៍ប្រចាំខែ (HO2 & HC1)

៣. របាយការណ៍សូចនាករ

៤. របាយការណ៍សូចនាករស្នូល

១. **បញ្ជីរបាយការណ៍** (Inventory Report) (សូមមើលឧបសម្ព័ន្ធទី១) ប្រើប្រាស់សម្រាប់ពិនិត្យមើលចំនួនរបាយការណ៍ តើមូលដ្ឋានសុខាភិបាលណា ដែលមានភាពយឺតយ៉ាវក្នុងការបញ្ចូលទិន្នន័យជារៀងរាល់ខែ និងដើម្បីផ្តល់ព័ត៌មានគ្រឡប់។ បញ្ជីរបាយការណ៍នេះបែងចែកជាផ្នែកតូចៗ រួមមាន៖

- បញ្ជីរបាយការណ៍ទូទាំងប្រទេស
- បញ្ជីរបាយការណ៍សម្រាប់មន្ទីរពេទ្យជាតិ
- បញ្ជីរបាយការណ៍ប្រចាំខេត្ត
- បញ្ជីរបាយការណ៍សម្រាប់មន្ទីរពេទ្យឯកជន
- បញ្ជីរបាយការណ៍សម្រាប់អង្គការ

២. **របាយការណ៍ប្រចាំខែ (HO2 & HC1)** បែងចែកជាពីរទម្រង់ដែលត្រូវបានមូលដ្ឋានសុខាភិបាលប្រើប្រាស់ជាប្រចាំសម្រាប់ធ្វើការរាយការណ៍ និងដើម្បីកំណត់រកភាពខ្លាំង និងភាពខ្សោយ ក៏ដូចជាការរក្សារទុកជាឯកសារសម្រាប់ស្ថាប័នសុខាភិបាលរបស់ខ្លួន។

- **HO2** ជាគំរូរបាយការណ៍ប្រចាំខែសម្រាប់មន្ទីរពេទ្យប្រើប្រាស់ទាំងសេវាសាធារណៈ និងសេវាឯកជន។
- **HC1** ជាគំរូរបាយការណ៍សម្រាប់មណ្ឌលសុខភាព ក៏ប៉ុន្តែទំរង់ HC1 នេះពេលខ្លះក៏ត្រូវបានគេប្រើប្រាស់នៅតាមមន្ទីរពេទ្យឯកជនមួយចំនួនដែរ។

៣. **របាយការណ៍សូចនាករ** (Indicators Report) (សូមមើលឧបសម្ព័ន្ធទី២)

៤. **របាយការណ៍សូចនាករស្នូល** (Core Indicators Report) (សូមមើលឧបសម្ព័ន្ធទី៣)

IV. អំពីការពិនិត្យរបាយការណ៍នៅក្នុង HMIS Web Based Database

១. បញ្ជីរបាយការណ៍

ដូចដែលយើងបានឃើញនៅក្នុងចំណុច "ប្រភេទរបាយការណ៍" បញ្ជីរបាយការណ៍មានទំរង់គំរូចំនួន៥ទៀត ដែលអាចអោយយើងយកមកប្រើប្រាស់តាមតំរូវការ។ ខាងក្រោមនេះយើងនឹងបង្ហាញពីការប្រើប្រាស់របាយការណ៍នីមួយៗតាមលំដាប់លំដោយ។ ដំបូងលោកអ្នកត្រូវចូលទៅកាន់គេហទំព័រដើម។ ដើម្បីចូលទៅកាន់គេហទំព័រ សូមមើលរូបភាព១ "ការចាប់ផ្តើមតំណើរការគេហទំព័រ" និងរូបភាព២ នៃ "របៀបប្រើប្រាស់ HMIS Web Based Database នៅលើគេហទំព័រ"។

✂ របៀបប្រើប្រាស់បញ្ជីរបាយការណ៍ទូទាំងប្រទេស

- ដាក់ Mouse លើពាក្យបញ្ជីរបាយការណ៍នៅលើ Menu "បញ្ជីរបាយការណ៍" (រូបទី១៧ លេខ ១)
- ចុចលើពាក្យ "ទូទាំងប្រទេស" (រូបទី១៧ លេខ ២)
- បន្ទាប់មកលោកអ្នកនឹងបានឃើញរូបភាព បង្ហាញដូចរូបភាព ១៨

រូបភាពទី ១៧ (របៀបជ្រើសរើសការបង្ហាញបញ្ជីរបាយការណ៍ទូទាំងប្រទេស)



រូបភាព ១៨ (របៀបជ្រើសរើសការបង្ហាញបញ្ជីរបាយការណ៍ទូទាំងប្រទេស)



- ចុចលើពាក្យ"ឆ្នាំ" រួចជ្រើសរើសយកឆ្នាំណាដែលអ្នកចង់បង្ហាញ (រូបភាព១៨ លេខ១)
- ចុចលើពាក្យ "ពីខែ" (រូបភាព១៨ លេខ២) និងពាក្យ "ដល់ខែ" (រូបភាព១៨ លេខ៣) ដើម្បីរើសយកខែណាដែលអ្នកចង់បង្ហាញ
- រួចចុចលើពាក្យ "បង្ហាញរបាយការណ៍" (រូបភាព១៨ លេខ៤)
- បញ្ជីរបាយការណ៍នឹងបង្ហាញដូចរូបភាព១៩ ដែលមានរាយឈ្មោះទូទាំង២៤ ខេត្តក្រុង (និងមន្ទីរពេទ្យជាតិដែលត្រូវបានរាប់បញ្ចូលផងដែរ) និងបង្ហាញចាប់ពីខែមករា រហូតដល់ខែធ្នូ (មើលរូបភាព១៩ លេខ១ និងលេខ២)
- អ្នកអាចមើលខេត្តផ្សេងៗទៀត ដោយចុចលើបន្ទាត់នៅខាងស្តាំ និងអូសចុះក្រោម (មើលរូបភាព១៩ លេខ៣)។

រូបភាព ១៩ (ទិន្នន័យបញ្ជីរបាយការណ៍ទូទាំងប្រទេស)



រូបភាព ២០ (របៀបនៃការរក្សារ និងបើក បញ្ជីរបាយការណ៍ទូទាំងប្រទេស)



- ប្រសិនបើអ្នកចង់បានជាឯកសារ Excel ចុចលើពាក្យ "របាយការណ៍សង្ខេបទូទាំងប្រទេស" (មើលរូបភាព២០ លេខ១)
- ប្រសិនបើចង់បើកមើល ចុចលើពាក្យ "Open with" រួចចុច "OK" (មើលរូបភាព២០ លេខ២ និង លេខ៤)
- ប្រសិនបើចង់រក្សារទុក ចុចលើពាក្យ "Save file" រួចចុច "OK" (មើលរូបភាព២០ លេខ៣ និង លេខ៤)
- បន្ទាប់មកឯកសារជា Excel នឹងបង្ហាញដូចរូបភាព ២១។

រូបភាព ២១ (គំរូបញ្ជីរបាយការណ៍ទូទាំងប្រទេស)



✂ *របៀបប្រើប្រាស់បញ្ជីរបាយការណ៍សម្រាប់មន្ទីរពេទ្យជាតិ*

- ដាក់ Mouse លើ Menu "បញ្ជីរបាយការណ៍" រួចជ្រើសរើសពាក្យ"មន្ទីរពេទ្យជាតិ" (មើលរូបភាព ២២ លេខ១ និងលេខ២)
- លោកអ្នកនឹងបានឃើញរូបភាពដែលមានរាយឈ្មោះគ្រប់មន្ទីរពេទ្យជាតិ (រូបភាព២៣)
- ជ្រើសរើសយកឆ្នាំ (រូបភាព២៣ លេខ១) យកខែ (រូបភាព២៣ លេខ២ និង៣) រួចចុចលើពាក្យ "បង្ហាញរបាយការណ៍" (រូបភាព២៣ លេខ៤)
- ប្រសិនបើលោកអ្នកចង់អោយបង្ហាញជាឯកសារ Excel ចេញមកខាងក្រៅចុចលើពាក្យ "របាយការណ៍មន្ទីរពេទ្យជាតិទូទាំងប្រទេស" (រូបភាព២៣ លេខ៥) រួចធ្វើការថតរក្សាទុក ឬចង់បើកមើល សូមមើលជំហានទាំងនេះនៅក្នុង "បញ្ជីរបាយការណ៍ទូទាំងប្រទេស" ដែលបានរៀបរាប់ខាងលើ (រូបភាព២០ និង២១)។

រូបភាព ២២ (របៀបជ្រើសរើសការបង្ហាញបញ្ជីរបាយការណ៍តាមមន្ទីរពេទ្យជាតិ)



រូបភាព ២៣ (របៀបជ្រើសរើសការបង្ហាញបញ្ជីរបាយការណ៍ថ្នាក់ជាតិលំអិត)



✂ *របៀបប្រើប្រាស់បញ្ជីរបាយការណ៍ប្រចាំខេត្ត*

- ចុចលើ Menu "បញ្ជីរបាយការណ៍" រួចជ្រើសរើសពាក្យ "ប្រចាំខេត្ត" (មើលរូបភាព២៤ លេខ១ និងលេខ២)
- ចំពោះរបាយការណ៍ប្រចាំខេត្ត លោកអ្នកអាចជ្រើសរើសយកខេត្តណាមួយដែលអ្នកចង់មើល (មើលរូបភាព២៤ លេខ១)

រូបភាព ២៤ (របៀបជ្រើសរើសការបង្ហាញបញ្ជីរបាយការណ៍ប្រចាំខេត្ត)



រូបភាព ២៥ (របៀបជ្រើសរើសការបង្ហាញបញ្ជីរបាយការណ៍ថ្នាក់ខេត្ត)



- ជ្រើសរើសយកឆ្នាំ (រូបភាព២៥ លេខ២) យកខែ (រូបភាព២៥ លេខ៣ និង៤) និងចុចលើពាក្យ "បង្ហាញរបាយការណ៍" ដើម្បីមើល (រូបភាព២៥ លេខ៥)
- ចុចលើពាក្យ "របាយការណ៍សង្ខេបទូទាំងខេត្ត" ដើម្បីបង្ហាញឯកសារជា Excel (រូបភាព២៥ លេខ៦)
- និងសូមអនុវត្តជំហានបន្តបន្ទាប់ (ដូចបានរៀបរាប់នៅក្នុង"បញ្ជីរបាយការណ៍ទូទាំងប្រទេស")៖ ដូចជាការបើកឯកសារ (រូបភាព២៥ លេខ២ និង៤) ការថតរក្សាទុកឯកសារ (រូបភាព២៥ លេខ៣ និង៤) ។

✂ របៀបប្រើប្រាស់បញ្ជីរបាយការណ៍សម្រាប់មន្ទីរពេទ្យឯកជន និងសម្រាប់អង្គការ

- ចំពោះបញ្ជីរបាយការណ៍ទាំងពីរខាងលើ គឺមានលក្ខណៈដូចគ្នាទៅនឹងការប្រើប្រាស់បញ្ជីរបាយការណ៍ប្រចាំខេត្តដូច្នោះដែរ។
- ប៉ុន្តែលោកអ្នកអាចជ្រើសរើសយកជារបាយការណ៍ទូទាំងប្រទេសក៏បាន ឬជ្រើសរើសតែខេត្តណាមួយដែលលោកអ្នកចង់មើលក៏បាន (សូមមើលទៅលើ "ឧបសម្ព័ន្ធទី៤" រូបភាពទី១ និងទី២)។

៤. គំរូរបាយការណ៍ប្រចាំខែ (HO2 & HC1)

របាយការណ៍ប្រចាំខែសម្រាប់បង្ហាញទិន្នន័យសកម្មភាពសុខាភិបាលប្រចាំខែ ប្រចាំត្រីមាស ប្រចាំឆមាស ប្រចាំឆ្នាំ។ គំរូនេះក៏អាចប្រើសម្រាប់ថ្នាក់ជាតិ ថ្នាក់ខេត្ត ថ្នាក់ស្រុក និងមូលដ្ឋានសុខាភិបាល។

✂ *របៀបប្រើប្រាស់គំរូរបាយការណ៍ប្រចាំខែសម្រាប់មណ្ឌលសុខភាព (HC1)*

HMIS Web Based Database នេះមានលក្ខណៈពិសេសមួយ គឺលោកអ្នកអាចចូលទៅកាន់របាយការណ៍នីមួយៗបានដោយងាយស្រួល ដោយគ្រាន់តែចុះឈ្មោះចូលទៅកាន់ទំព័រដំបូងរបស់គេហទំព័ររួចរាល់ លោកអ្នកនឹងបានឃើញ Menu ដែលមានរាយប្រភេទរបាយការណ៍ធំៗទាំង ៤ ដែលក្នុងនោះគំរូរបាយការណ៍ HC1 និង HO2 គឺស្ថិតនៅក្នុង Menu ឈ្មោះ "គំរូរបាយការណ៍ប្រចាំខែ" (មើលរូបភាព ២៦)។

រូបភាព ២៦ (របៀបជ្រើសរើសគំរូរបាយការណ៍ប្រចាំខែ សម្រាប់មណ្ឌលសុខភាព)



រូបភាព ២៧ (របៀបជ្រើសរើសរបាយការណ៍សម្រាប់មណ្ឌលសុខភាព ជាថ្នាក់ជាតិ)



- ចុចលើ Menu គំរូរបាយការណ៍ប្រចាំខែ (រូបភាព២៦ លេខ១) រួចចុចលើពាក្យ "សម្រាប់មណ្ឌលសុខភាព" (រូបភាព២៦ លេខ២)
- លោកអ្នកនឹងឃើញផ្ទាំងរូបភាព ដូចរូបភាពលេខ ២៧
- នៅក្នុងប្រអប់ "សូមជ្រើសរើសកំឡុងពេល" (រូបភាព២៧ លេខ១ដល់លេខ៣) អ្នកអាចជ្រើសរើសយក ឆ្នាំខែណាដែលអ្នកចង់មើល និងនៅក្នុងប្រអប់ "សូមជ្រើសរើសរបាយការណ៍តាមថ្នាក់" ជ្រើសរើសរបាយការណ៍ថ្នាក់ជាតិ (រូបភាព២៧ លេខ៤ និងលេខ៥)
- ជ្រើសរើសរបាយការណ៍ថ្នាក់ខេត្ត (មើលរូបភាព២៨ លេខ១ ដល់លេខ៣)
- ជ្រើសរើសរបាយការណ៍ថ្នាក់ស្រុក (មើលរូបភាព២៩ លេខ១ ដល់លេខ៤)
- ជ្រើសរើសរបាយការណ៍ថ្នាក់មូលដ្ឋានសុខាភិបាល (មើលរូបភាព៣០ លេខ១ដល់លេខ៥)
- បន្ទាប់ពីលោកអ្នកធ្វើការជ្រើសរើសរួច និងចុចនៅលើប្រអប់ "ទាញយករបាយការណ៍" នោះ លោកអ្នកនឹងឃើញរូបភាពជាឯកសារ Excel ដូចរូបភាព ៣១ ។

រូបភាព ២៨ (របៀបជ្រើសរើសរបាយការណ៍សម្រាប់មណ្ឌលសុខភាព ជាថ្នាក់ខេត្ត)



រូបភាព ២៩ (របៀបជ្រើសរើសរបាយការណ៍សម្រាប់មណ្ឌលសុខភាព ជាថ្នាក់ស្រុក)



រូបភាព ៣០ (របៀបជ្រើសរើសរបាយការណ៍សម្រាប់មណ្ឌលសុខភាព ជាថ្នាក់មូលដ្ឋានសុខាភិបាល)



រូបភាព ៣១ (គំរូរបាយការណ៍ប្រចាំខែសម្រាប់មណ្ឌលសុខភាព)



✂ របៀបប្រើប្រាស់គំរូរបាយការណ៍ប្រចាំខែសម្រាប់មន្ទីរពេទ្យ (HO2)

- ដាក់លើ Menu "គំរូរបាយការណ៍ប្រចាំខែ" ជ្រើសរើសយកពាក្យ "សម្រាប់មន្ទីរពេទ្យ" (រូបភាព៣២ លេខ១ និងលេខ២)។

រូបភាព ៣២ (របៀបជ្រើសរើសគំរូរបាយការណ៍ប្រចាំខែ សម្រាប់មន្ទីរពេទ្យបង្អែក)



រូបភាព ៣៣ (របៀបជ្រើសរើសរបាយការណ៍សម្រាប់មន្ទីរពេទ្យ ជាថ្នាក់ជាតិ)



- នៅក្នុងគំរូ HO2 នេះក៏មិនខុសពី HC1 ខាងលើដែរ លោកអ្នកអាចជ្រើសរើសយកឆ្នាំ ខែ នៅក្នុងប្រអប់ "សូមជ្រើសរើសកំឡុងពេល" (រូបភាព៣៣ លេខ១ ដល់លេខ៣) ជ្រើសរើសថ្នាក់របាយការណ៍ជាថ្នាក់ជាតិ (រូបភាព៣៣ លេខ៤) ឬជ្រើសរើសខេត្ត ស្រុក និងមូលដ្ឋានសុខាភិបាល រួចចុចលើ "ទាញយករបាយការណ៍" (រូបភាព៣៣ លេខ៥) រូបភាជាឯកសារ Excel នឹងបង្ហាញដូចរូបភាព ៣៤។

រូបភាព ៣៤ (គំរូរបាយការណ៍ប្រចាំខែសម្រាប់មន្ទីរពេទ្យ)



- សូមមើលរូបភាពរបាយការណ៍តាមថ្នាក់ខេត្តនៅឧបសម្ព័ន្ធ៨ រូបភាព ៣
- រូបភាពរបាយការណ៍តាមថ្នាក់ស្រុកនៅឧបសម្ព័ន្ធ៨ រូបភាព ៤
- និងរូបភាពរបាយការណ៍តាមថ្នាក់មូលដ្ឋានសុខាភិបាលនៅឧបសម្ព័ន្ធ៨ រូបភាព ៥

៥. របាយការណ៍សូចនាករ (Indicator Report)

របាយការណ៍សូចនាករទាំង១១ បែងចែកចេញជា ៤ថ្នាក់ និងមាន ២គំរូដែលត្រូវបានគេប្រើប្រាស់ជាទូទៅ៖

ថ្នាក់របាយការណ៍៖

១. របាយការណ៍ថ្នាក់ជាតិ

២. របាយការណ៍ថ្នាក់ខេត្ត

៣. របាយការណ៍ថ្នាក់ស្រុក

៤. របាយការណ៍ថ្នាក់មូលដ្ឋានសុខាភិបាលសាធារណៈ

គំរូរបាយការណ៍នៅក្នុងរបាយការណ៍សូចនាករទាំង ១១ មាន៖

១. គំរូរបាយការណ៍ HO2 និង HC1

២. និងរបាយការណ៍តាមខែ

ខាងក្រោមនេះ លោកអ្នកនឹងបានឃើញឧទាហរណ៍អំពីការប្រើប្រាស់របាយការណ៍សូចនាករនីមួយៗ ដែលបែងចែកទៅតាមថ្នាក់ទាំង៤ ដូចបានរៀបរាប់ខាងលើ និងមានតាមគំរូរបាយការណ៍ HO2 និងHC1 និងរបាយការណ៍តាមខែ។

៥.១. សូចនាករ "ការពិនិត្យពិគ្រោះជម្ងឺក្រៅ" តាមគំរូ HO2 និង HC1

✄របាយការណ៍ថ្នាក់ជាតិ

- នៅលើ Menu "របាយការណ៍សូចនាករ" ចុចលើពាក្យ "បង្ហាញជា File Excel" (រូបភាព៣៥ លេខ១ និងលេខ២)
- លោកអ្នកនឹងបានឃើញបញ្ជីរបាយការណ៍សូចនាករបង្ហាញដូចរូបភាព ៣៦។ លោកអ្នកអាចមើលឃើញរបាយការណ៍សូចនាករទាំង ១១នេះបានទាំងអស់ដោយគ្រាន់តែអូសបន្ទាត់ដែលនៅខាងស្តាំនោះចុះក្រោម (មើលរូបភាព៣៦ លេខ១ និងរូបភាព៣៦.១ លេខ២)

រូបភាព ៣៥ (របៀបជ្រើសរើសរបាយការណ៍សូចនាករ)



រូបភាព ៣៦ (របៀបជ្រើសរើសសូចនាករ ការពិនិត្យពិគ្រោះជម្ងឺក្រៅ)



- ជ្រើសរើសយកសូចនាករការពិនិត្យពិគ្រោះជម្ងឺក្រៅ ដោយចុចលើពាក្យ "ការពិនិត្យពិគ្រោះជម្ងឺក្រៅ" (រូបភាព៣៦ លេខ២)

រូបភាព ៣៦.១



- បន្ទាប់មកទើបធ្វើការជ្រើសរើសយកឆ្នាំ ខែនៅក្នុងប្រអប់ "សូមជ្រើសរើសកំឡុងពេល" (រូបភាព ៣៧ ពីលេខ១ ដល់លេខ៤) ជ្រើសរើសរបាយការណ៍ជាថ្នាក់ជាតិ នៅក្នុងប្រអប់ "សូមជ្រើសរើសរបាយការណ៍តាមថ្នាក់" (រូបភាព៣៧ លេខ៥) និងចុចលើ "សូមជ្រើសរើសទីកន្លែង" ដើម្បីកំណត់យកការបង្ហាញរបស់របាយការណ៍ ថាតើអ្នកចង់បង្ហាញតាមស្រុកប្រតិបត្តិ ឬតាមខេត្ត រួចចុចលើ "ទាញយករបាយការណ៍" (រូបភាព៣៧ លេខ៦ លេខ៧ និងលេខ៨) ។

រូបភាព ៣៧ (របៀបជ្រើសរើសរបាយការណ៍សូចនាករ បង្ហាញជាថ្នាក់ជាតិ)



- ចុចលើពាក្យ "Open with" រួចចុច "OK" ដើម្បីបើករបាយការណ៍ (មើលរូបភាព៣៨ លេខ១ និង លេខ៣)
- ចុចលើពាក្យ "Save File" រួចចុច "OK" ដើម្បីថតរក្សារបាយការណ៍ដែលបានជ្រើសរើស(មើលរូបភាព៣៨ លេខ២ និងលេខ៣)
- បន្ទាប់ពីបានជ្រើសរើសបើករបាយការណ៍ ឬរក្សាទុកនោះ លោកអ្នកនឹងបានឃើញរូបភាពជាឯកសារ Excel ដូចបានបង្ហាញនៅរូបភាព៣៩ និងរូបភាព៤០។

រូបភាព ៣៨ (របៀបរក្សាទុក និងបើករបាយការណ៍សូចនាករជា Excel)



រូបភាព ៣៩ (គំរូរបាយការណ៍សូចនាករទូទាំងប្រទេស បង្ហាញតាមស្រុកប្រតិបត្តិ)



រូបភាព ៤០ (គំរូរបាយការណ៍សូចនាករទូទាំងប្រទេស បង្ហាញតាមខេត្ត)



ការពិនិត្យពិគ្រោះជម្ងឺក្រៅ

របាយការណ៍សូចនាករប្រចាំប្រទេស

ពីខែ កក្កដា ដល់ខែ កញ្ញា , 2010

ខេត្ត	ចំនួនសរុបករណីថ្មី								ចំនួនពិនិត្យពិគ្រោះសរុប			NC.IN
	នៅ មណ្ឌល.				នៅ មន្ទី.			សរុប	នៅ មណ្ឌល.	នៅ មន្ទី.	សរុប	
	តំបន់ ក	តំបន់ ខ	តំបន់ គ	សរុប	បញ្ជូនមកពីHC	មកពិនិត្យខ្លួនឯងនៅRH	សរុប					
បន្ទាយមានជ័យ	35437	93516	19922	148875	669	9116	9785	158660	156108	11880	167988	0.2
បាត់ដំបង	31243	82265	29011	142519	951	13376	14327	156846	187317	22249	209566	0.1
កំពង់ចាម	61083	213150	53671	327904	513	14373	14886	342790	342060	15786	357846	0.1
កំពង់ឆ្នាំង	14204	60364	11778	86346	177	4287	4464	90810	90943	4503	95446	0.1
កំពង់ស្ពឺ	9163	53786	15313	78262	195	5342	5537	83799	84681	6029	90710	0.1
កំពង់ធំ	18163	52829	13153	84145	119	3039	3158	87303	93712	6355	100067	0.1
កំពត	14136	37060	11842	63038	716	2412	3128	66166	66190	5696	71886	0.1
កណ្ដាល	48480	111469	43462	203411	1007	13012	14019	217430	223855	20523	244378	0.1
កោះកុង	5606	6286	1134	13026	108	1888	1996	15022	13553	3870	17423	0.1
ក្រចេះ	9927	22494	3393	35814	8	308	316	36130	40133	316	40449	0.1
មណ្ឌលគីរី	4619	7608	689	12916	5	100	105	13021	13065	105	13170	0.
ភ្នំពេញ	32927	41984	12924	87835	756	25105	25861	113696	96537	36318	132855	0.0

✂របាយការណ៍ថ្នាក់ខេត្ត និងថ្នាក់ស្រុក

- រាល់ការជ្រើសរើសរបាយការណ៍សូចនាករតែមួយ "សូចនាករ ការពិនិត្យពិគ្រោះជម្ងឺក្រៅ" គឺមានជំហានដដែលៗ គ្រាន់តែមានការខុសគ្នានៅពេលជ្រើសរើសថ្នាក់របស់របាយការណ៍តែប៉ុណ្ណោះ (មើលរូបភាព៣៦ លេខ២) (និងរូបភាព៣៧ លេខ១ ដល់លេខ៤)
- ជ្រើសរើសរបាយការណ៍ថ្នាក់ខេត្ត (មើលរូបភាព៤១ លេខ១ ដល់លេខ៣)
- ជ្រើសរើសរបាយការណ៍ថ្នាក់ស្រុក (មើលរូបភាព៤២ លេខ១ ដល់លេខ៤)

រូបភាព ៤១ (របៀបជ្រើសរើសរបាយការណ៍សូចនាករ បង្ហាញជាថ្នាក់ខេត្ត)



រូបភាព ៨២ (របៀបជ្រើសរើសរបាយការណ៍សូចនាករ បង្ហាញជាថ្នាក់ស្រុក)



- សូមមើលជំហាននអនុវត្តនៃការបើកឯកសារ និងថតរក្សាឯកសារទុក នៅរូបភាព៣៨ លេខ១ ដល់លេខ៣)
- បន្ទាប់មក រូបភាពជា File Excel នឹងបង្ហាញដូចរូបភាព៨៣ និងរូបភាព៨៤ ខាងក្រោម។

រូបភាព ៨៣ (តំរូវរបាយការណ៍សូចនាករប្រចាំខេត្ត បង្ហាញតាមខេត្ត)



រូបភាព ៩៤ (គំរូរបាយការណ៍សូចនាករប្រចាំខេត្ត បង្ហាញតាមស្រុកប្រតិបត្តិ)



មូលដ្ឋានសុខាភិបាលសាធារណៈ	ចំនួនសរុបករណីថ្មី								ចំនួនពិនិត្យពិគ្រោះសរុប			NC.I
	នៅ មណ្ឌល.				នៅ មន្ទី.			សរុប	នៅ មណ្ឌល.	នៅ មន្ទី.	សរុប	
	តំបន់ ក	តំបន់ ខ	តំបន់ គ	សរុប	បញ្ជូនមកពីHC	មកពិនិត្យខ្លួនឯងនៅRH	សរុប					
ប៊ុនរ៉ានីហ៊ុនសែនរកាកោង_RH	0	0	0	0	0	798	798	798	0	798	798	0.
ព្រែកអញ្ចាញ_HC	1031	1703	778	3512	0	0	0	3512	5185	0	5185	0.
ឫស្សីជ្រោយ_HC	916	622	26	1564	0	0	0	1564	1591	0	1591	0.
ព្រែកដំបង_HC	1075	1348	45	2468	0	0	0	2468	2518	0	2518	0.
សំបូរមាស_HC	229	864	33	1126	0	0	0	1126	1226	0	1226	0.
រកាកោង_HC	930	1452	1093	3475	0	0	0	3475	3562	0	3562	0.
ស្វាយអំពារ_HC	895	1248	38	2181	0	0	0	2181	2214	0	2214	0.
សរុបទូទាំងស្រុក	**5076**	**7237**	**2013**	**14326**	**0**	**798**	**798**	**15124**	**16296**	**798**	**17094**	**0**

✂ *របាយការណ៍ថ្នាក់មូលដ្ឋានសុខាភិបាលសាធារណៈ:*

- ចុចលើ "របាយការណ៍ថ្នាក់មូលដ្ឋានសុខាភិបាលសាធារណៈ:" (រូបភាព៩៥ លេខ១) រួចជ្រើសរើសយកខេត្ត ស្រុកប្រតិបត្តិ និងមូលដ្ឋានសុខាភិបាល រួចចុចលើ "ទាញយករបាយការណ៍" (មើលរូបភាព៩៥ លេខ២ ដល់លេខ៥)

រូបភាព ៩៥ (របៀបជ្រើសរើសរបាយការណ៍សូចនាករ បង្ហាញជាថ្នាក់មូលដ្ឋានសុខាភិបាលសាធារណៈ:)



- រួចជ្រើសរើសយក "Open with" សម្រាប់បើករបាយការណ៍ រួចចុច "OK" (រូបភាព៤៦ លេខ១ និងលេខ៣)
- និងចុចលើ "Save File" ដើម្បីថតរក្សារបាយការណ៍ទុក រួចចុច "OK" ដដែល (រូបភាព៤៦ លេខ២ និងលេខ៣)
- បន្ទាប់មកលោកអ្នកនឹងបានរបាយការណ៍ជាឯកសារ Excel ដូចរូបភាព ៤៧ខាងក្រោម

រូបភាព ៤៦ (របៀបរក្សាទុក និងបើករបាយការណ៍សូចនាករ)



រូបភាព ៤៧ (គំរូរបាយការណ៍សូចនាករសំរាប់មណ្ឌលសុខភាពជា Excel)



៥.២. សូចនាករ "ការពិនិត្យពិគ្រោះជម្ងឺក្រៅ" តាមគំរូរបាយការណ៍ប្រចាំខែ

✂***របាយការណ៍ថ្នាក់ជាតិ - របាយការណ៍ប្រចាំខែតាមប្រភេទជម្ងឺ ភេទ និងក្រុមអាយុ***

ដូចដែលរៀបរាប់នៅក្នុងចំណុច៣ របាយការណ៍សូចនាករទាំង១១ ខាងលើ យើងអាចទាញយករបាយការណ៍សូចនាករមកប្រើក្នុងលក្ខណៈ ២ទំរង់។ លោកអ្នកបានឃើញការប្រើប្រាស់របាយការណ៍សូចនាករ "ការពិនិត្យពិគ្រោះជម្ងឺក្រៅ" តាមទំរង់របាយការណ៍ HO2 និង HC1 រួចមកហើយ។ ក្នុងចំនុចនេះយើងនឹងលើកយកការប្រើប្រាស់របាយការណ៍តាមគំរូប្រចាំខែមកបង្ហាញ។

- លោកអ្នកអាចជ្រើសរើសគំរូប្រចាំខែ តាមប្រភេទជម្ងឺ ភេទ និងក្រុមអាយុ (មើលរូបភាព៤៨ លេខ១ ដល់លេខ៣។
- បន្ទាប់មកធ្វើការជ្រើសរើសខែ ឆ្នាំ ក្នុងប្រអប់ "កំឡុងពេល" (មើលរូបភាព៤៩ លេខ១ ដល់លេខ៣)
- និងជ្រើសរើសថ្នាក់របស់របាយការណ៍ (រូបភាព៤៩ លេខ៤ ដល់លេខ៧)។ ឧទាហរណ៍៖ លោកអ្នកចង់បានរបាយការណ៍ជាថ្នាក់ជាតិ (រូបភាព៤៩ លេខ៤) រួចជ្រើសរើសទីកន្លែង និងចុចលើ "ទាញយករបាយការណ៍" (រូបភាព៤៩ លេខ៨ និងលេខ៩) ។
- លោកអ្នកអាចប្រើប្រាស់របាយការណ៍ថ្នាក់ខេត្ត ស្រុក និងមូលដ្ឋានសុខាភិបាលសាធារណៈ បានដោយអនុវត្តទៅតាមជំហានដូចគ្នាទៅនឹងថ្នាក់ជាតិ តាមរយៈរូបភាពបន្តបន្ទាប់ខាងក្រោយនេះ ឬអ្នកអាចមើលរូបភាព៥១ ៥២ និងរូបភាព៥៥។

រូបភាព ៤៨ (របៀបជ្រើសរើសលំអិត របាយការណ៍សូចនាករការពិនិត្យពិគ្រោះជម្ងឺក្រៅ)



រូបភាព ៤៩ (របៀបជ្រើសរើសរបាយការណ៍សូចនាករលំអិត បង្ហាញជាថ្នាក់ជាតិ)



រូបភាព ៤៩ (របៀបរក្សាទុក និងបើករបាយការណ៍សូចនាករជា Excel)



- អ្នកអាចបើករបាយការណ៍ ដោយចុចលើ "Open with" (រូបភាព៥០ លេខ១ និងលេខ៣)និង ចតរក្សារបាយការណ៍ទុក "Save File" (រូបភាព៥០ លេខ២ និងលេខ៣) រួចចុចលើ "OK"។
- រូបភាពផ្ទាំងឯកសារ Excel នឹងបង្ហាញដូចរូបភាព៥១ ខាងក្រោមនេះ។

រូបភាព ៥១ (គំរូរបាយការណ៍សូចនាករទូទាំងប្រទេស ជា Excel)



OPD បញ្ហាសុខភាពចំនួនករណីថ្មីសរុប ប្រចាំខែ [ភាគ]														
របាយការណ៍សូចនាករប្រចាំប្រទេស														
ពីខែ មករា ដល់ខែ មិថុនា , 2011														
ខេត្ត	ស្រុកប្រតិបត្តិ	មករា	កុម្ភៈ	មិនា	មេសា	ឧសភា	មិថុនា	កក្កដា	សីហា	កញ្ញា	តុលា	វិច្ឆិកា	ធ្នូ	សរុប
បន្ទាយមានជ័យ														
	មន្ទីរពេទ្យខេត្តមិត្តភាពកម្ពុជាជប៉ុន PH	33	32	28	24	26	18							161
	មង្គលបូរី	878	539	491	475	457	534							3374
	ប៉ោយប៉ែត	649	485	499	465	570	697							3365
	ព្រះនេត្រព្រះ	382	343	323	280	228	336							1892
	ថ្មពួក	173	204	157	206	175	197							1112
	សរុបខេត្ត	**2115**	**1603**	**1498**	**1450**	**1456**	**1782**							**9904**
បាត់ដំបង														
	មន្ទីរពេទ្យខេត្តបាត់ដំបង PH	55	22	36	30	25	44							212
	ថ្មគោល	535	341	307	301	288	301							2073
	មោងឫស្សី	307	193	200	163	149	162							1174
	សំពៅលូន	129	82	113	68	88	85							565
	បាត់ដំបង	926	733	819	563	584	562							4187
	សង្កែរ	456	389	362	249	391	422							2269

៥.៣. របៀបប្រើប្រាស់សូចនាករ "ការសម្រាលកូន"

ត្រង់ចំណុចនេះលោកអ្នកនឹងបានឃើញឧទាហរណ៍ ពីការប្រើប្រាស់របាយការណ៍សូចនាករ "ការសម្រាលកូន" របាយការណ៍ឆ្លងឆ្នាំជាថ្នាក់ជាតិ និងបន្តនៅរបាយការណ៍ប្រចាំខែ ដែលលោកអ្នកអាចទាញយកតាមរយៈប្រភេទនៃការសម្រាលនីមួយៗ។

✄របាយការណ៍ថ្នាក់ជាតិ

- ជ្រើសរើសសូចនាករ "ទិន្នន័យស្ត្រីសម្រាលកូន"

  សម្រាប់របាយការណ៍ស្ត្រីសម្រាលកូនសរុបគ្រប់ករណី (មើលរូបភាព៥២ លេខ១)

រូបភាព ៥២ (របៀបជ្រើសរើសរបាយការណ៍សូចនាករ ទិន្នន័យសម្រាលកូល)



រូបភាព ៥៣ (របៀបជ្រើសរើសរបាយការណ៍សូចនាករទិន្នន័យស្ត្រីសម្រាលកូនលំអិត)



- អ្នកអាចជ្រើសរើសរយៈពេលឆ្លងឆ្នាំបាននៅក្នុងប្រអប់ "សូមជ្រើសរើសកំឡុងពេល" មើលរូបភាព៥៣ លេខ១ ដល់លេខ៤)
- បន្ទាប់មកជ្រើសរើសថ្នាក់របស់របាយការណ៍ និងជ្រើសរើសទីកន្លែង (រូបភាព៥៣ លេខ៥ លេខ៦ និងលេខ៨) រួចចុចលើ "ទាញយករបាយការណ៍" ។
- ឧទាហរណ៍៖ លោកអ្នកជ្រើសរើសរបាយការណ៍ថ្នាក់ជាតិ ដែលបង្ហាញតាមស្រុកប្រតិបត្តិ (រូបភាព៥៣ លេខ៥ លេខ៦ និងលេខ៨) រូបភាពជាឯកសារ Excel នឹងបង្ហាញដូចរូបភាព៥៥។ ប្រសិនបើលោកអ្នកជ្រើសរបាយការណ៍ថ្នាក់ជាតិដដែល តែបង្ហាញតាមខេត្ត (រូបភាព៥៣ លេខ៥ លេខ៧ និងលេខ៨) រូបភាពជាឯកសារ Excel នឹងបង្ហាញដូចរូបភាព៥៦។

រូបភាព ៥៤ (របៀបរក្សារទុក និងបើករបាយការណ៍សូចនាករជា Excel)



- ចុចលើពាក្យ "Open with" ដើម្បីបើករបាយការណ៍ដែលបានជ្រើសរើស (មើលរូបភាព៥៤ លេខ១ និងលេខ៣) និងចុចលើ "Save File" ដើម្បីថតរបាយការណ៍ រួចចុច "OK" (រូបភាព៥៤ លេខ២ និងលេខ៣)។

រូបភាព ៥៥ (គំរូរបាយការណ៍សូចនាករទិន្នន័យសម្រាលកូន បង្ហាញតាមស្រុកប្រតិបត្តិជា Excel)



ទិន្នន័យស្ត្រីសម្រាលកូន

របាយការណ៍សូចនាករប្រចាំប្រទេស (RH+HC)

ពី តុលា , 2010 ដល់ មិនា, 2011

ខេត្ត	ស្រុកប្រតិបត្តិ	ស្ត្រីផ្ទៃពោះរំពឹងទុក	ចំនួនសំរាល			រះយកកូន	% រះយកកូន¹	% រះយកកូន²	ធ្លាក់ឈាម	ក្រឡាភ្លើង	រហែកស្បូ
			សំរាលធម្មតា	សំរាលលំបាក	សរុបសំរាល						
បន្ទាយមានជ័យ											
	មន្ទីរពេទ្យខេត្តមិត្តភាពកម្ពុជាជប៉ុន	21709	212	185	397	61	15.37	0.28	36	18	0
	មង្គលបូរី	7040	2082	49	2131	0	0	0	0	3	0
	ប៉ោយប៉ែត	5829	2013	60	2073	36	1.74	0.62	7	1	0
	ព្រះនេត្រព្រះ	4225	1000	31	1031	0	0	0	10	2	0
	ថ្មពួក	3735	1120	16	1136	0	0	0	8	0	0
	សរុបខេត្ត	**21709**	**6427**	**341**	**6768**	**97**	**1.43**	**0.45**	**61**	**24**	**0**
បាត់ដំបង											
	មន្ទីរពេទ្យខេត្តបាត់ដំបង	32831	908	308	1216	178	14.64	0.54	0	1	0
	ថ្មគោល	6089	1909	43	1952	0	0	0	4	0	0
	មោងឫស្សី	5786	1733	50	1783	25	1.4	0.43	17	0	0
	សំពៅលូន	4165	1069	75	1144	14	1.22	0.34	43	1	0
	បាត់ដំបង	10926	2584	0	2584	0	0	0	3	0	0
	សង្កែ	5791	1512	0	1512	0	0	0	5	0	0

រូបភាព ៥៦ (គំរូរបាយការណ៍សូចនាករទិន្នន័យសម្រាលកូន បង្ហាញតាមខេត្តជា Excel)



ទិន្នន័យស្ត្រីសម្រាលកូន

របាយការណ៍សូចនាករប្រចាំប្រទេស (RH+HC)

ពី តុលា , 2010 ដល់ មិនា, 2011

ខេត្ត	ស្ត្រីផ្ទៃពោះរំពឹងទុក	ចំនួនសំរាល			រះយកកូន	% រះយកកូន¹	% រះយកកូន²	ធ្លាក់ឈាម	ក្រឡាភ្លើង	រហែកស្បូន	ការក្លាយរោគ
		សំរាលធម្មតា	សំរាលលំបាក	សរុបសំរាល							
បន្ទាយមានជ័យ	21709	6427	341	**6768**	97	1.43	0.45	61	24	0	1
បាត់ដំបង	32831	9715	476	**10191**	217	2.13	0.66	72	2	0	2
កំពង់ចាម	53802	17798	944	**18742**	370	1.97	0.69	71	14	2	2
កំពង់ឆ្នាំង	17144	5317	308	**5625**	196	3.48	1.14	31	10	0	0
កំពង់ស្ពឺ	23726	6527	356	**6883**	78	1.13	0.33	32	4	0	1
កំពង់ធំ	20221	5336	223	**5559**	89	1.6	0.44	18	9	0	1
កំពត	17511	5177	223	**5400**	109	2.02	0.62	57	8	0	0
កណ្ដាល	35118	8682	227	**8909**	90	1.01	0.26	13	0	0	0
កោះកុង	3637	964	77	**1041**	6	0.58	0.16	11	3	0	10
ក្រចេះ	10905	2255	68	**2323**	49	2.11	0.45	21	6	1	0
មណ្ឌលគីរី	2609	834	33	**867**	10	1.15	0.38	4	4	0	0
ភ្នំពេញ	28345	7255	281	**7536**	88	1.17	0.31	8	0	0	0
ព្រះវិហារ	5663	1719	30	**1749**	28	1.6	0.49	2	1	0	0
ព្រៃវែង	27306	9257	283	**9540**	82	0.86	0.3	33	4	0	0

✂របាយការណ៍ថ្នាក់ខេត្ត ៖ គំរូប្រចាំខែ តាមប្រភេទនៃការសម្រាល

- នៅខាងក្រោមសូចនាករ "ទិន្នន័យស្ត្រីសម្រាលកូន" លោកអ្នកអាចជ្រើសរើសប្រភេទនៃការសម្រាល (រូបភាព៥៧ លេខ១)។ ឧទាហរណ៍៖ ជ្រើសរើសរបាយការណ៍ "៣.២.១. ចំនួនស្ត្រីសម្រាលកូនធម្មតា)

រូបភាព ៥៧ (របៀបជ្រើសរើសរបាយការណ៍សូចនាករលំអិត នៃទិន្នន័យស្ត្រីសម្រាលកូន)



រូបភាព ៥៨ (របៀបជ្រើសរើសរបាយការណ៍សូចនាករទិន្នន័យស្ត្រីសម្រាលកូនលំអិត តាមថ្នាក់ខេត្ត)



- ជ្រើសរើសខែ ឆ្នាំ (មើលរូបភាព៥៨ ពីលេខ១ ដល់លេខ៣)
- ជ្រើសរើសរបាយការណ៍ថ្នាក់ខេត្ត (មើលរូបភាព៥៨ លេខ៤) និងជ្រើសរើសទីកន្លែង (មើលរូបភាព៥៨ លេខ៥ និងលេខ៦) រួចចុចលើ "ទាញយករបាយការណ៍" (និងសូមមើលរូបភាព៥៨ ជំហាននៃការបើករបាយការណ៍ និងថតរក្សារបាយការណ៍ទុក)។
- បន្ទាប់មកលោកអ្នកនឹងបានឯកសារជា Excel ដូចរូបភាព៥៩។

រូបភាព ៥៩ (គំរូរបាយការណ៍សូចនាករស្ត្រីសម្រាលកូនធម្មតា បង្ហាញតាមខេត្តជា Excel)



ចំនួនស្ត្រីសម្រាលកូនធម្មតា ប្រចាំខែ														
របាយការណ៍សូចនាករប្រចាំសៀមរាប														
ពីខែ មករា ដល់ខែ ធ្នូ , 2011														
ស្រុកប្រតិបត្តិ	មូលដ្ឋានសុខាភិបាលសាធារណៈ	មករា	កុម្ភៈ	មិនា	មេសា	ឧសភា	មិថុនា	កក្កដា	សីហា	កញ្ញា	តុលា	វិច្ឆិកា	ធ្នូ	សរុប
មន្ទីរពេទ្យខេត្តសៀមរាប_PH		55	30	49	57	79	54	0	0	0	0	0	0	324
ក្រឡាញ់														
	មន្ទីរពេទ្យបង្អែកក្រឡាញ់_RH	19	15	11	24	16	20	12	0	0	0	0	0	117
	កំពង់ថ្កូវ_HC	24	21	27	32	33	33	0	0	0	0	0	0	170
	សែនសុខ_HC	21	14	12	29	27	18	0	0	0	0	0	0	121
	ពោងគោ_HC	27	21	20	28	33	32	0	0	0	0	0	0	161
	សំបួរ_HC	18	17	12	29	26	29	0	0	0	0	0	0	131
	ស្រីស្នំ_HC	33	31	22	22	25	24	0	0	0	0	0	0	157
	ស្លែងស្ពាន_HC	32	31	29	25	29	42	0	0	0	0	0	0	188
	ស្រណាល_HC	24	20	17	23	25	25	0	0	0	0	0	0	134
	ប្រិយ៍_HC	22	21	13	14	18	18	0	0	0	0	0	0	106
	ចន្លាស់ដៃ_HC	20	9	15	16	27	19	0	0	0	0	0	0	106
	សរុបទូទាំងស្រុក	**240**	**200**	**178**	**242**	**259**	**260**	**12**	**0**	**0**	**0**	**0**	**0**	**1391**
សៀមរាប														

៥.៤. សូចនាករ "សកម្មភាពនៃកម្មវិធីចាក់ថ្នាំបង្ការ" បង្ហាញជាថ្នាក់ស្រុក

អ្នកអាចជ្រើសរើសយកសូចនាករតូចៗ ចំនួន៧ទៀតនៅក្នុងសូចនាករ សកម្មភាពនៃកម្មវិធីចាក់ថ្នាំបង្ការ។ ឧទាហរណ៍៖ អ្នកជ្រើសរើសយក ៥.១. (សូមមើលរូបភាព៦០ លេខ១) សូចនាករនេះនឹងបង្ហាញអ្នកនៅរបាយការណ៍ "ការចាក់ថ្នាំបង្ការសម្រាប់កុមារក្រោមអាយុ១ឆ្នាំ និងតេតាណុលសម្រាប់ស្ត្រីមាន និងគ្មានផ្ទៃពោះ" ។

- ជ្រើសរើសកំឡុងពេល (រូបភាព៦១ ពីលេខ១ ដល់លេខ៤)
- ជ្រើសរើសថ្នាក់របស់របាយការណ៍ (រូបភាព៦១ លេខ៥)
- ជ្រើសរើសទីកន្លែង (រូបភាព៦១ លេខ៦ ដល់លេខ៨) រួចចុច "ទាញយករបាយការណ៍"

រូបភាព ៦០ (របៀបជ្រើសរើសរបាយការណ៍សូចនាករសកម្មភាពនៃកម្មវិធីចាក់ថ្នាំបង្ការ)



រូបភាព ៦១ ((របៀបជ្រើសរើសរបាយការណ៍សូចនាករសកម្មភាពនៃកម្មវិធីចាក់ថ្នាំបង្ការ បង្ហាញជាថ្នាក់ស្រុក)

- ចុចលើ "Open with" ដើម្បីបើករបាយការណ៍ (មើលរូបភាព៦២ លេខ១)
- ចុចលើ "Save File" ដើម្បីថតរក្សាររបាយការណ៍ទុក (មើលរូបភាព៦២ លេខ២)
- រួចចុច "OK" (មើលរូបភាព៦២ លេខ៣)នោះឯកសារជា Excel នឹងបង្ហាញដូចរូបភាព៦៣។

រូបភាព ៦២ (របៀបរក្សាទុក និងបើករបាយការណ៍សូចនាករ ជា Excel)



រូបភាព ៦៣



ការចាក់ថ្នាំបង្ការសម្រាប់កុមារអាយុក្រោម ១ឆ្នាំ និង ថ្នាំតេតាណុលសម្រាប់ ស្ត្រីមាន និងគ្មានផ្ទៃពោះ

របាយការណ៍សូចនាករប្រចាំស្រុកបាកាន, ពោធិ៍សាត់

ពីខែ កក្កដា ដល់ខែ ធ្នូ , 2010

មូលដ្ឋានសុខាភិបាលសាធារណៈ	ស្ត្រីផ្ទៃពោះរំពឹងទុក	# of TT 1	# of TT 2	# of TT 3	# of TT 4	# of TT 5	កុមារ <1 ឆ្នាំ	# of BCG	HepB ពេលកើត <24 ម៉ោង	HepB ពេលកើត 24 ម៉ោង ទៅ 7 ថ្ងៃ	HepB ពេលកើត សរុប	# of DPT 1	# of DPT 2	# of DPT 3
មន្ទីរពេទ្យបង្អែកបាកាន_RH	4049	0	0	0	0	0	2861	0	0	0	0	0	0	0
បឹងខ្នារ_HC	385	106	86	104	95	51	272	218	210	0	210	161	116	135
ស្នាមព្រះ_HC	496	151	122	74	49	34	351	213	157	26	183	221	210	219
ត្រពាំងជង_HC	563	187	144	108	32	22	398	198	157	30	187	180	171	203
មេទឹក_HC	419	232	148	26	28	14	296	186	163	23	186	186	148	131
អូរតាប៉ោង_HC	498	136	134	122	110	87	352	204	191	0	191	181	174	175
ស្វាយដូនកែវ_HC	195	147	165	160	122	33	138	83	75	4	79	93	105	99
ខ្នារទទឹង_HC	241	84	82	113	131	97	170	76	73	0	73	86	80	91
រំលេច_HC	244	94	82	32	33	23	172	89	73	8	81	80	73	82
បឹងបត់កណ្តាល_HC	336	152	132	102	46	41	237	152	116	0	116	139	115	114
តាលោ_HC	672	358	194	113	34	13	475	182	150	3	153	177	156	179
សរុបទូទាំងស្រុក	4049	1647	1289	954	680	415	2861	1601	1365	94	1459	1504	1348	1428

- ក្រៅពីនេះ សូចនាករតូចៗដែលទាក់ទងគ្នានៅក្នុងសកម្មភាពផ្តល់ថ្នាំបង្ការនេះ មាន៖ (៥.២) អាស៊ីតហ្វូលិក និងគ្រាប់ថ្នាំជាតិដែក (៥.៣) វីតាមីនអា (៥.៤) ការផ្តល់ថ្នាំបង្ការកុមារអាយុក្រោម១ឆ្នាំ (៥.៥.) ការផ្តល់ថ្នាំបង្ការស្ត្រីមានផ្ទៃពោះ (៥.៦) ការផ្តល់ថ្នាំបង្ការស្ត្រីគ្មានផ្ទៃពោះអាយុ១៥ ដល់៤៩ឆ្នាំ និង(៥.៧) ការផ្តល់ថ្នាំបង្ការកុមារអាយុលើសពី ១ឆ្នាំ។ ហើយសូចនាករទាំងនោះ លោកអ្នកអាចទាញយកជាគំរូប្រចាំខែក៏បាន ជាគំរូ HO2 និង HC1ក៏បាន។

- អ្នកអាចប្រើប្រាស់របាយការណ៍ដែលបែងចែកលំអិតតូចៗទៀតបាន ដូចជា តេតាណុល១ ២ ៣ ៤ និង៥សម្រាប់ស្ត្រីមាន ឬគ្មានផ្ទៃពោះ (មើលរូបភាព៦៤ លេខ១) ដែលរបាយការណ៍ទាំងនោះជាគំរូរបាយការណ៍ប្រចាំខែ។

រូបភាព ៦៤ (របៀបជ្រើសរើសប្រភេទរបាយការណ៍សូចនាករ ប្រចាំខែ)



៥.៥. សូចនាករ "សកម្មភាពសម្រាកពេទ្យ"

សូចនាករ "សកម្មភាពសំរាកពេទ្យ" មានបែងចែកជាផ្នែកតូចៗចំនួន ៦ និងមានអនុផ្នែកចំនួន២ ផ្សេងទៀត ដែលបង្ហាញជាគំរូប្រចាំខែ។ លោកអ្នកបានឃើញពីវិធីប្រើប្រាស់របាយការណ៍ផ្សេងៗទៅតាមគំរូខុសៗគ្នា បន្ទាប់មកនេះគឺ ការបង្ហាញពីការប្រើប្រាស់របាយការណ៍ថ្នាក់មូលដ្ឋានសុខាភិបាលសាធារណៈ។

រូបភាព ៦៥



✂*របាយការណ៍ថ្នាក់មូលដ្ឋានសុខាភិបាលសាធារណៈ*

- ឧទាហរណ៍៖ *លោកអ្នកជ្រើសរើសសូចនាករ ជម្ងឺ និងមរណៈភាពអ្នកជម្ងឺសម្រាកពេទ្យ (រូបភាព៦៦ លេខ១)*
- ជ្រើសរើសកំឡុងពេល (មើលរូបភាព៦៧ ពីលេខ១ ដល់លេខ៤)
- ជ្រើសរើសថ្នាក់របស់របាយការណ៍ (មើលរូបភាព៦៧ លេខ៥)
- និងជ្រើសរើសទីកន្លែង(រូបភាពលេខ៦៧ លេខ៦ ដល់លេខ៨) រួចចុច "ទាញយករបាយការណ៍" (រូបភាព៦៧ លេខ៩)

រូបភាព ៦៦ (របៀបជ្រើសរើសរបាយការណ៍សូចនាករ ជម្ងឺ និងមរណៈភាពអ្នកជម្ងឺសម្រាកពេទ្យ)



រូបភាព ៦៧ (របៀបជ្រើសរើសរបាយការណ៍សូចនាករ ជម្ងឺ និងមរណៈភាពអ្នកជម្ងឺសម្រាកពេទ្យ បង្ហាញតាមមូលដ្ឋានសុខាភិបាលសាធារណៈ)



- បន្ទាប់ពីលោកអ្នកចុចលើ "ទាញយករបាយការណ៍" អ្នកអាចជ្រើសរើសយកបើករបាយការណ៍ (មើលរូបភាព៦៨ លេខ១) ឬចុចរក្សាររបាយការណ៍ទុក (រូបភាព៦៨ លេខ២) និងចុច "OK" (រូបភាព៥៩ លេខ៣) ឯកសារជា Excel នឹងបង្ហាញ (មើលរូបភាព៦៩។

រូបភាព ៦៨ (របៀបរក្សាទុក និងបើករបាយការណ៍សូចនាករជា Excel)



រូបភាព ៦៩ (គំរូរបាយការណ៍សូនាករបង្ហាញជា Excel)



ជម្ងឺនិងមរណៈភាព អ្នកជម្ងឺសម្រាកពេទ្យ

របាយការណ៍សូចនាករប្រចាំមន្ទីរពេទ្យសម្ពពព្រុង_PH

ពីខែ មករា ដល់ខែ មិនា , 2011

ជំងឺ	0_4 ឆ្នាំ		5_14 ឆ្នាំ		15_49 ឆ្នាំ		≥50 ឆ្នាំ		សរុប	
	ឈឺ	ស្លាប់	ឈឺ	ស្លាប់	ឈឺ	ស្លាប់	ឈឺ	ស្លាប់	ឈឺ	ស្លាប់
រាគ	19	0	2	0	37	0	2	0	60	0
អាសន្នរោគ	0	0	0	0	1	0	0	0	1	0
រាគមូល	0	0	0	0	3	0	1	0	4	0
ជម្ងឺផ្លូវដង្ហើម	25	0	10	0	32	2	24	0	91	2
របេង	0	0	0	0	2	0	3	0	5	0
គ្រុនចាញ់ស្រាល	0	0	0	0	10	0	2	0	12	0
គ្រុនចាញ់ធ្ងន់ធ្ងរ	0	0	0	0	3	0	0	0	3	0
គ្រុនរាំង	0	0	1	0	0	0	0	0	1	0
គ្រុនឈាមស្រាល	0	0	0	0	0	0	0	0	0	0
គ្រុនឈាមធ្ងន់ធ្ងរ	0	0	0	0	0	0	0	0	0	0
គ្រុនពោះវៀន	7	0	13	0	30	0	7	0	57	0
កញ្ជ្រិល	1	0	0	0	0	0	0	0	1	0
ខាន់ស្លាក់	0	0	0	0	0	0	0	0	0	0

៦. របាយការណ៍សូចនាករស្នូល (Core Indicators)

របាយការណ៍សូចនាករស្នូល ជារបាយការណ៍សំខាន់ដែលសុខាភិបាលសាធារណៈប្រើប្រាស់ជាផ្លូវការ សម្រាប់ពិនិត្យលទ្ធផលឆ្នាំចាស់ និងដើម្បីរៀបចំផែនការអនុវត្តសកម្មភាពឆ្នាំថ្មី។ នៅក្នុងសូចនាករស្នូលនេះ អ្នកអាចទាញយកជារបាយការណ៍សរុបប្រចាំឆ្នាំ បង្ហាញលទ្ធផលជាភាគរយ (%) ឬជាចំនួន។ មិនត្រឹមតែប៉ុណ្ណោះ អ្នកអាចបង្ហាញលទ្ធផលជាថ្នាក់ជាតិ/ខេត្ត/ស្រុកប្រតិបត្តិ និងមន្ទីរពេទ្យ ឬមណ្ឌលសុខភាព ដែលទាំងអស់នេះជួយសម្រួលដល់អ្នកប្រើប្រាស់ទាញយកលទ្ធផលរបស់តំបន់ដែលខ្លួនគ្របដណ្តប់បានឆាប់រហ័ស និងទាន់ពេលវេលា។

របាយការណ៍សូចនាករស្នូលមាន៦ទំរង់ដែលយើងអាចទាញយកមកប្រើប្រាស់ជាលក្ខណៈផ្សេងៗ ដូចជា៖

(១) របាយការណ៍សូចនាករស្នូល គិតជា ភាគរយ

(២) របាយការណ៍សូចនាករស្នូល គិតជា ចំនួន

(៣) របាយការណ៍សូចនាករស្នូលតាមខេត្តគិតជា ភាគរយ

(៤) របាយការណ៍សូចនាករស្នូលតាមខេត្តគិតជា ចំនួន

(៥) របាយការណ៍សូចនាករស្នូលតាមការិយាល័យស្រុកប្រតិបត្តិគិតជា ភាគរយ

(៦) របាយការណ៍សូចនាករស្នូលតាមការិយាល័យស្រុកប្រតិបត្តិគិតជា ចំនួន

៦.១. ភាពខុសគ្នារវាងសូចនាករស្នូលទាំង ៦ខាងលើ

- សូចនាករស្នូល (១) និង(២)៖ គឺបង្ហាញលទ្ធផលសរុបទូទាំងប្រទេសជាថ្នាក់ជាតិ ខេត្ត ស្រុកប្រតិបត្តិ និងមូលដ្ឋានសុខាភិបាល។
- សូចនាករស្នូល (៣) និង(៤)៖ អ្នកអាចប្រើប្រាស់ជារបាយការណ៍ថ្នាក់ជាតិ ខេត្ត ស្រុក និងមូលដ្ឋានសុខាភិបាលបាន ដោយបង្ហាញជាលទ្ធផលលំអិត ដែលសូចនាករមន្ទីរពេទ្យជាតិក៏មាននៅក្នុងនោះដែរ។
- សូចនាករស្នូល (៥) និង(៦)៖ ជាសូចនាករបង្ហាញលទ្ធផលសរុបទូទាំងប្រទេស ជាថ្នាក់ស្រុក និងថ្នាក់ខេត្ត។

៦.២. ការប្រើប្រាស់របាយការណ៍សូចនាករស្នូល គិតជាភាគរយ (%)

- របាយការណ៍សូចនាករស្នូល គឺបិតនៅលើ Menu តែមួយជាមួយនិងរបាយការណ៍សូចនាករទាំង១១ ដែរ។
- សូមចុចនៅលើ Menu "របាយការណ៍សូចនាករ" រួចចុចលើពាក្យ "បង្ហាញជា File Excel" (មើលរូបភាព៧០ លេខ១) របាយការណ៍សូចនាករទាំង១១ នឹងបង្ហាញដូចក្នុងរូបភាព៧១ បន្ទាប់មកសូមអូសបន្ទាត់ខាងស្តាំចុះក្រោម (រូបភាព៧១ លេខ១ និងរូបភាព៧២ លេខ១) នោះអ្នកនឹងបានឃើញគំរូរបាយការណ៍សូចនាករស្នូលទាំង ៦ (មើលរូបភាព៧២ លេខ២)។

- នៅក្នុងប្រអប់ “សូមជ្រើសរើសកំឡុងពេល” ជ្រើសរើសខែ និងឆ្នាំ និងជ្រើសរើសថ្នាក់របស់របាយការណ៍ក្នុងប្រអប់ “សូមជ្រើសរើសរបាយការណ៍តាមថ្នាក់” និងនៅក្នុងប្រអប់ “សូមជ្រើសរើសទីកន្លែង” ជ្រើសរើយកខេត្ត ស្រុកប្រតិបត្តិ ឬមូលដ្ឋានសុខាភិបាលណាដែលអ្នកចង់បាន។

រូបភាព ៧០ (របៀបជ្រើសរើសរបាយការណ៍សូចនាករស្នូល)



រូបភាព ៧១



រូបភាព ៧២ (របៀបជ្រើសរើសរបាយការណ៍សូចនាករស្នូល ជាភាគរយ)



- *ឧទាហរណ៍៖ លោកអ្នកកំពុងជ្រើសរើសលទ្ធផលសូចនាករស្នូលជា% (មើលរូបភាព៧២ លេខ៣)*
- *និងជ្រើសរើសរយៈពេល ៦ខែ ចាប់ពីខែមករា ដល់ខែមិថុនា ឆ្នាំ២០១១ (មើលរូបភាព៧៣ លេខ១ ដល់លេខ៤)*

រូបភាព ៧៣ (របៀបជ្រើសរើសរបាយការណ៍សូចនាករស្នូល បង្ហាញជាថ្នាក់ជាតិ)



- *ជ្រើសរើសថ្នាក់របស់របាយការណ៍ ជាថ្នាក់ជាតិ (មើលរូបភាព៧៣ លេខ៥)*
- *រួចចុចលើពាក្យ "ទាញយករបាយការណ៍" (មើលរូបភាព៧៣ លេខ៦)*
- *បន្ទាប់មកលោកអ្នកអាចបើក ឬថតរក្សាររបាយការណ៍នេះទុកដោយចុចលើពាក្យ "Open with" (មើលរូបភាព៧៤ លេខ១) ចុចលើ "Save File" (មើលរូបភាព៧៤ លេខ២) រួចចុច "OK" (រូបភាព៧៤ លេខ៣)*
- *រូបភាព៧៥ ជាឯកសារ Excel នឹងបង្ហាញដូចខាងក្រោម*

រូបភាព ៧៤ (របៀបរក្សារទុក និងបើករបាយការណ៍សូចនាករជា Excel)



រូបភាព ៧៥ (គំរូរបាយការណ៍សូចនាករស្នូលថ្នាក់ជាតិ ជា Excel)



៦.៣. ការប្រើប្រាស់របាយការណ៍សូចនាករស្នូល គិតជាចំនួន

- ចុចលើពាក្យ "លទ្ធផលសូចនាករស្នូលជា ចំនួន" (រូបភាព ៧៦ លេខ១)
- ចំពោះរបាយការណ៍សូចនាករស្នូលជាចំនួននេះ ឧទាហរណ៍ថា "*លោកអ្នកនឹងជ្រើសជាថ្នាក់ខេត្ត (មើលរូបភាព៧៧ លេខ១) ប៉ុន្តែរយៈពេលគឺនៅខែឆ្នាំដដែល រួចជ្រើសរើសខេត្ត បន្ទាយមានជ័យ និងចុច"ទាញយករបាយការណ៍" (មើលរូបភាព៧៧ លេខ២ និងលេខ៣)*"

រូបភាព ៧៦ (របៀបជ្រើសរើសរបាយការណ៍សូចនាករស្នូល ជាចំនួន)



រូបភាព ៧៧ (របៀបជ្រើសរើសរបាយការណ៍សូចនាករស្នូល ជាថ្នាក់ខេត្ត)



- ចុច "Open with" ដើម្បីបើករបាយការណ៍ ឬចុច "Save File" ដើម្បីថតរក្សាររបាយការណ៍ រួចចុច "OK" (មើលរូបភាព៧៨ លេខ១ ដល់លេខ៣)
- រូបភាព៧៩ ជាឯកសារ Excel នឹងបង្ហាញដូចខាងក្រោម

រូបភាព ៧៨ (របៀបរក្សាទុក និងបើករបាយការណ៍សូចនាករស្នូលជា Excel)



រូបភាព ៧៩ (គំរូរបាយការណ៍សូចនាករស្នូលថ្នាក់ខេត្ត ជា Excel)



៦.៤. ការប្រើប្រាស់របាយការណ៍សូចនាករស្នូលតាមខេត្ត គិតជាភាគរយ និងចំនួន

- ក្នុងការប្រើប្រាស់របាយការណ៍សូចនាករស្នូលតាមខេត្ត គិតជាភាគរយ (មើលរូបភាព៨០) និងរបាយការណ៍សូចនាករស្នូលតាមខេត្ត គិតជាចំនួន (មើលរូបភាព៨១) នេះគឺមានលក្ខណៈដូចគ្នាទាំងវិធីនៃការជ្រើសរើស និងទំរង់ ប៉ុន្តែមានភាពខុសប្លែកគ្នាតែត្រង់លទ្ធផលមួយជាភាគរយ និងមួយទៀតជាចំនួនប៉ុណ្ណោះ។

រូបភាព ៨០ (របៀបជ្រើសរើសរបាយការណ៍សូចនាករតាមខេត្ត ជាភាគរយ)



រូបភាព ៨១ (របៀបជ្រើសរើសរបាយការណ៍សូចនាករតាមខេត្ត ជាចំនួន)



- បន្ទាប់ពីលោកអ្នកជ្រើសរើសយកសូចនាករស្នូលរួចរាល់
- ឧទាហរណ៍៖ "*នៅពេលនេះ លោកអ្នកចង់បានសូចនាករស្នូលដែលបង្ហាញគ្រប់ស្រុកទាំងអស់នៃខេត្តរបស់លោកអ្នក(ប៉ៃលិន)។*
- *ជ្រើសរើសថ្នាក់របស់របាយការណ៍ក្នុងប្រអប់ "សូមជ្រើសរើសរបាយការណ៍តាមថ្នាក់" និង ជ្រើសរើសទីកន្លែង រួចចុចលើ "ទាញយករបាយការណ៍" (មើលរូបភាព៨២ លេខ១ ដល់លេខ៤)*

រូបភាព ៨២ (របៀបជ្រើសរើសរបាយការណ៍សូចនាករថ្នាក់ស្រុកលម្អិត)



រូបភាព ៨៣ (របៀបរក្សាទុក និងបើករបាយការណ៍សូចនាករស្នូលជា Excel)



- លោកអ្នកអាចបើករបាយការណ៍ ឬចតរក្សារទុក (សូមមើលរូបភាព៨៣ ពីលេខ១ ដល់លេខ៣)
- បន្ទាប់មកលោកអ្នកនឹងបានទំរង់របាយការណ៍ជាឯកសារ Excel ដូចរូបភាព៨៤ (បង្ហាញពីលទ្ធផលសូចនាករស្ទួល គិតជា**ភាគរយ**) និងរូបភាព៨៥ (បង្ហាញពីលទ្ធផលសូចនាករស្ទួល គិតជា**ចំនួន**)

រូបភាព ៨៤ (គំរូរបាយការណ៍សូចនាករស្ទួលបង្ហាញជាភាគរយ ជា Excel)



របាយការណ៍សង្ខេបពិនិត្យលទ្ធផលនៃការអនុវត្តន៍ផែនការ

ខែ : មករា 2011

តារាងក្របខណ្ឌសូចនាករស្ទួលនៃការត្រួតពិនិត្យតាមដាន និងវាយតំលៃប្រចាំឆ្នាំ

១. លទ្ធផលនៃការផ្តល់សេវាសុខភាពបន្តពូជមាតា - ទារក និង កុមារ		មន្ទីរពេទ្យខេត្តប៉ៃលិន	សួនកុមារ	អូរជ្រា	ភ្នំស្ពង់	ភ្នំព្រាល	ផ្សារព្រំ	ក្រចាប់
១	% នៃការសម្រាលកូនដោយបុគ្គលិកសុខាភិបាលនៅមូលដ្ឋានសុខាភិបាល	5300	0	12.36	5.26	4.33	3.67	2.03
២	% នៃការសម្រាលកូនដោយបុគ្គលិកសុខាភិបាលដែលមានការបណ្តុះបណ្តាល	5300	0	12.36	5.26	4.33	3.67	2.03
៣	% នៃការពិនិត្យផ្ទៃពោះមុនសំរាល ២ដងរឺ ច្រើនជាង ដោយបុគ្គលិកសុខាភិបាល	0	13.29	12.36	10.86	9.06	7	2.85
៤	% នៃការពិនិត្យផ្ទៃពោះមុនសំរាល ៤ដងរឺ ច្រើនជាង ដោយបុគ្គលិកសុខាភិបាល	0	21.1	27.8	17.43	12.6	14	10.98
៥	% នៃការសំរាលកូនដោយវះកាត់	700	0	0	0	0	0	0
៦	% នៃស្ត្រីមានផ្ទៃពោះទទួលថ្នាំបង្ការជំងឺតេតាណូសយ៉ាងតិច២ដង	0	0.58	4.25	1.64	3.54	4.67	1.63
៧	% នៃស្ត្រីមានផ្ទៃពោះបានទទួលគ្រាប់ថ្នាំជាតិដែក / អាស៊ីដហ្វូលីក៩០គ្រាប់	0	12.43	12.36	6.58	7.09	7.33	5.28
៨	% នៃស្ត្រីក្រោយសំរាលបានទទួលគ្រាប់ថ្នាំជាតិដែក / អាស៊ីដហ្វូលីក៤២គ្រាប់	3800	0	11.58	5.26	5.51	3.67	2.03
៩	% អត្រាប្រើប្រាស់វិធីពន្យាកំណើតទំនើប	7857.14	35.53	37.66	15.77	34.13	12.98	14.09
១០	% នៃកុមារក្រោមអាយុ១ឆ្នាំដែលបានទទួលថ្នាំបង្ការ DPT - HepB3	0	11.66	10.25	3.48	4.17	7.42	1.72

រូបភាព ៨៥ (គំរូរបាយការណ៍សូចនាករស្ទួលបង្ហាញជាចំនួន ជា Excel)



របាយការណ៍សង្ខេបពិនិត្យលទ្ធផលនៃការអនុវត្តន៍ផែនការ

ខែ :មករា , 2011

តារាងក្របខណ្ឌសូចនាករស្ទួលនៃការត្រួតពិនិត្យតាមដាន និងវាយតំលៃប្រចាំឆ្នាំ

១. លទ្ធផលនៃការផ្តល់សេវាសុខភាពបន្តពូជមាតា - ទារក និង កុមារ		Pailin Prov. Hosp.	Suon Koma	Ou chra	Phnom Spong	Phnom Preal	Phsar Prom	Krachab
១	ចំនួនការសម្រាលកូនដោយបុគ្គលិកសុខាភិបាលនៅមូលដ្ឋានសុខាភិបាល	53	0	32	16	11	11	5
២	ចំនួនការសម្រាលកូនដោយបុគ្គលិកសុខាភិបាលដែលមានការបណ្តុះបណ្តាល	53	0	32	16	11	11	5
៣	ចំនួនការពិនិត្យផ្ទៃពោះមុនសំរាល ២ដងរឺ ច្រើនជាង ដោយបុគ្គលិកសុខាភិបាល	0	46	32	33	23	21	7
៤	ចំនួនការពិនិត្យផ្ទៃពោះមុនសំរាល ៤ដងរឺ ច្រើនជាង ដោយបុគ្គលិកសុខាភិបាល	0	73	72	53	32	42	27
៥	ចំនួនការសំរាលកូនដោយវះកាត់	7	0	0	0	0	0	0
៦	ចំនួនស្ត្រីមានផ្ទៃពោះទទួលថ្នាំបង្ការជំងឺតេតាណូសយ៉ាងតិច២ដង	0	4	21	10	18	28	5
៧	ចំនួនស្ត្រីមានផ្ទៃពោះបានទទួលគ្រាប់ថ្នាំជាតិដែក / អាស៊ីដហ្វូលីក៩០គ្រាប់	0	43	32	20	18	22	13
៨	ចំនួនស្ត្រីក្រោយសំរាលបានទទួលគ្រាប់ថ្នាំជាតិដែក / អាស៊ីដហ្វូលីក៤២គ្រាប់	38	0	30	16	14	11	5
៩	ចំនួនប្រើប្រាស់វិធីពន្យាកំណើតទំនើប	0	614	488	240	434	195	173
១០	ចំនួនកុមារក្រោមអាយុ១ឆ្នាំដែលបានទទួលថ្នាំបង្ការ DPT - HepB3	0	38	25	10	10	21	4

⋆ របាយការណ៍សូចនាករស្នូល របស់មន្ទីរពេទ្យជាតិទូទាំងប្រទេស

- អ្នកអាចជ្រើសរើសយករបាយការណ៍សូចនាករស្នូលរបស់មន្ទីរពេទ្យទាំងអស់បាន ដោយចុចនៅលើ "លទ្ធផលសូចនាករស្នូលតាមខេត្ត ជាភាគរយ ឬជាចំនួន" ទៅតាមតំរូវការរបស់អ្នក (មើលរូបភាព៨១ លេខ១)
- ឧទាហរណ៍៖ អ្នកជ្រើសរើសសូចនាករស្នូលរបស់មន្ទីរពេទ្យជាតិ ជាចំនួន (មើលរូបភាព៨១ លេខ២)
- ជ្រើសរើសរយៈពេល ១២ខែ ក្នុងឆ្នាំ២០១០ (មើលរូបភាព៨៦ លេខ១ ដល់លេខ៤)
- ចុចលើ "របាយការណ៍មន្ទីរពេទ្យជាតិ" នៅក្នុងប្រអប់ "សូមជ្រើសរើសរបាយការណ៍តាមថ្នាក់" រួចចុចលើ "ទាញយករបាយការណ៍" (មើលរូបភាព៨៦ លេខ៥ និងលេខ៦)

រូបភាព ៨៦ (របៀបជ្រើសរើសរបាយការណ៍សូចនាករស្នូល របស់មន្ទីរពេទ្យជាតិទូទាំងប្រទេស)



- បន្ទាប់មកចុច "Open with" (មើលរូបភាព៨៧ លេខ១ និងលេខ៣) ដើម្បីបើក ឬថតរក្សារបាយការណ៍មន្ទីរពេទ្យជាតិទុកចុច "Save File" (មើលរូបភាព៨៧ លេខ២ និងលេខ៣) រួចចុច "OK" ។
- លោកអ្នកនឹងបានសូចនាករស្នូលរបស់មន្ទីរពេទ្យជាតិដូចរូបភាព៨៨ជា Excel ដូចខាងក្រោម។

រូបភាព ៨៧ (របៀបរក្សាទុក និងបើករបាយការណ៍សូចនាករស្នូលរបស់មន្ទីរពេទ្យជាតិទូទាំងប្រទេស)



រូបភាព ៨៨ (គំរូរបាយការណ៍សូចនាករស្នូលជា Excel)



របាយការណ៍សង្ខេបពិនិត្យលទ្ធផលនៃការអនុវត្តន៍ផែនការ

ពីខែ : មករា ដល់ខែ : ធ្នូ ឆ្នាំ 2010

តារាងក្របខណ្ឌសូចនាករស្នូលនៃការត្រួតពិនិត្យតាមដាន និងវាយតំលៃប្រចាំឆ្នាំ

១. លទ្ធផលនៃការផ្តល់សេវាសុខភាពបន្តពូជមាតា - ទារក និង កុមារ		មន្ទីរពេទ្យព្រះអង្គឌួង	មន្ទីរពេទ្យកុមារអង្គរ	មន្ទីរពេទ្យកាល់ម៉ែត	មជ្ឈមណ្ឌលជាតិកំចាត់ជំងឺរបេង	មន្ទីរពេទ្យជ័យវរ្ម័នទី៧	មន្ទីរពេទ្យមិត្តភាពខ្មែរសូវៀត	មន្ទីរពេទ្យព្រះកុសមៈ	មន្ទីរពេទ្យគន្ធបុប្ផា
១	% នៃការសម្រាលកូនដោយបុគ្គលិកសុខាភិបាលនៅមូលដ្ឋានសុខាភិបាល	0	0	5484	0	0	1521	389	0
២	% នៃការសម្រាលកូនដោយបុគ្គលិកសុខាភិបាលដែលមានការបណ្តុះបណ្តាល	0	0	5484	0	0	1521	389	0
៣	% នៃការពិនិត្យផ្ទៃពោះមុនសំរាល ២ដង	0	0	3325	0	0	524	82	0
៤	% នៃការពិនិត្យផ្ទៃពោះមុនសំរាល ៤ដង រឺ ច្រើនជាង ដោយបុគ្គលិកសុខាភិបាល	0	0	7931	0	0	803	71	0
៥	% នៃការសំរាលកូនដោយវះកាត់	0	0	1472	0	0	186	104	0
៦	% នៃស្ត្រីមានផ្ទៃពោះទទួលថ្នាំបង្ការជំងឺតេតាណូសយ៉ាងតិច២ដង	0	0	1087	0	0	212	33	25
៧	% នៃស្ត្រីមានផ្ទៃពោះបានទទួលគ្រាប់ថ្នាំជាតិដែក / អាស៊ីដហ្វូលីក៩០គ្រាប់	0	0	2493	0	0	484	127	0
៨	% នៃស្ត្រីក្រោយសំរាលបានទទួលគ្រាប់ថ្នាំជាតិដែក / អាស៊ីដហ្វូលីក៤២គ្រាប់	0	0	1159	0	0	214	419	0
៩	% អត្រាប្រើប្រាស់វិធីពន្យាកំណើតទំនើប	0	0	11988	0	0	0	2	0
១០	% នៃកុមារក្រោមអាយុ១ឆ្នាំដែលបានទទួលថ្នាំបង្ការ DPT - HepB3	0	0	0	0	0	687	0	1629
១១	% កុមារអាយុ ៦- ៥៩ ខែបានទទួលគ្រាប់ថ្នាំជីវជាតិអា ២ ដូសក្នុងរយៈ ១២ ខែចុងក្រោយ								

៦.៥. ការប្រើប្រាស់របាយការណ៍សូចនាករស្នូលតាមការិយាល័យស្រុកប្រតិបត្តិ គិតជាភាគរយ

- របាយការណ៍សូចនាករស្នូលតាមការិយាល័យស្រុកប្រតិបត្តិ នេះនឹងបង្ហាញលោកអ្នកពីលទ្ធផលជាថ្នាក់ខេត្តទូទាំងប្រទេស និងថ្នាក់ស្រុកប្រតិបត្តិទូទាំងប្រទេស។
- លោកអ្នកអាចទាញយករបាយការណ៍សូចនាករស្នូលសម្រាប់ថ្នាក់ខេត្ត ឬស្រុកប្រតិបត្តិដែលលោកអ្នកត្រូវការក៏បាន។
- ឧទាហរណ៍៖ *សូមចុចនៅលើ "លទ្ធផលសូចនាករស្នូលតាមការិយាល័យស្រុកប្រតិបត្តិជា%" (មើលរូបភាព៨៩)*
- ជ្រើសរើសកំឡុងពេល (មើលរូបភាព៩០ លេខ១ ដល់លេខ៣) និងជ្រើសរើសការបង្ហាញរបស់របាយការណ៍ រួចចុច"ទាញយករបាយការណ៍" (មើលរូបភាព៩០ លេខ៤ ៥ និងលេខ៦)។ "ប្រសិនបើលោកអ្នកជ្រើសរើសថ្នាក់របស់របាយការណ៍ជាថ្នាក់ខេត្ត នោះលទ្ធផលនឹងបង្ហាញជាសរុបទៅលើខេត្តនីមួយៗ ប៉ុន្តែប្រសិនបើលោកអ្នកចង់បានលទ្ធផលបង្ហាញជាស្រុកប្រតិបត្តិ សូមជ្រើសរើសយកស្រុកប្រតិបត្តិ។

រូបភាព ៨៩ (របៀបជ្រើសរើសរបាយការណ៍សូចនាករស្នូលតាមការិយាល័យស្រុកប្រតិបត្តិ ជាភាគរយ)



រូបភាព ៨៩ (របៀបជ្រើសរើសរបាយការណ៍សូចនាករស្នូលតាមការិយាល័យស្រុកប្រតិបត្តិ ជាភាគរយ បង្ហាញជាថ្នាក់ខេត្ត)

- ជំហាននៃការបើក ឬថតរក្សាររបាយការណ៍គឺមានលក្ខណ:ដូចគ្នាទៅនឹងរបាយការណ៍មុនៗដែរ (មើលរូបភាព៧៧ លេខ១ ដល់លេខ៣)
- បន្ទាប់មកលោកអ្នកនឹងបានរបាយការណ៍ជា Excel ដូចរូបភាព៩២ ឬរូបភាព៩៣ខាងក្រោម

រូបភាព ៩១ (របៀបរក្សាទុក និងបើករបាយការណ៍សូចនាករស្នូលជា Excel)



រូបភាព ៩២ (គំរូរបាយការណ៍សូចនាករស្តួលបង្ហាញជាភាគរយតាមថ្នាក់ខេត្ត ជា Excel)



រូបភាព ៩៣ (គំរូរបាយការណ៍សូចនាករស្តួលបង្ហាញជាចំនួនតាមថ្នាក់ខេត្ត ជា Excel)



V. នាំចេញនាំចូល និងគ្រប់គ្រងអ្នកប្រើ

V.1. នាំចូល នាំចេញ (សម្រាប់អ្នកគ្មាន Internet ប្រើប្រាស់)

"នាំចូលនាំចេញ" គឺជា Menu មួយដែលត្រូវបានគេបង្កើតឡើងដើម្បីសម្រួលដល់អ្នកប្រើប្រាស់ដែលមិនមាន Internet នៅការិយាល័យធ្វើការរបស់ខ្លួន។ រាល់ពេលអ្នកអាចនាំចូល ឬនាំចេញទិន្នន័យពីកុំព្យូទ័រ ទៅកាន់គេហទំព័រ និងពីគេហទំព័រមកកុំព្យូទ័ររបស់ខ្លួនវិញ។ (សូមមើលឧបសម្ព័ន្ធសម្រាប់ការនាំចូលនាំចេញទិន្នន័យ)។

V.2. គ្រប់គ្រងអ្នកប្រើ (សម្រាប់តែក្រសួងសុខាភិបាលប៉ុណ្ណោះ)

"គ្រប់គ្រងអ្នកប្រើ" គឺជា Menu សម្រាប់តែក្រសួងសុខាភិបាលប៉ុណ្ណោះ ដែលមានសិទ្ធិក្នុងការគ្រប់គ្រង និងរៀបចំចាត់ចែងទៅលើការប្រើប្រាស់ប្រព័ន្ធនេះ។ ការកំណត់សិទ្ធិរបស់ប្រតិបត្តិករនីមួយៗ គឺត្រូវបានបង្កើតឡើងដោយក្រសួងសុខាភិបាល ការបង្កើតឈ្មោះ និងលេខកូដសំងាត់សម្រាប់ចូលទៅកាន់ប្រព័ន្ធ។ ប្រតិបត្តិករម្នាក់ៗ បន្ទាប់ពីមានឈ្មោះអាចចូលទៅកាន់ប្រព័ន្ធ អ្នកអាចប្តូរលេខកូដសំងាត់សម្រាប់ឈ្មោះរបស់ខ្លួនអ្នកផ្ទាល់។

- បន្ទាប់ពីអ្នកបានចូលទៅកាន់គេហទំព័រដើមរបស់ HMIS Web Database (ដូចក្នុងរូបភាព៩៤)។
- អ្នកនឹងបានឃើញពាក្យ "ប្តូរពាក្យសំងាត់/Change Password/ចាកចេញ/Log Out" ដូចក្នុងរូបភាព៩៥
- ចុចលើពាក្យ "ប្តូរពាក្យសំងាត់/Change Password/ចាកចេញ/Log Out" (រូបភាព៩៥ លេខ១)

រូបភាព ៩៤ (របៀបចូលទៅការកាន់គេហទំព័រ HMIS)

រូបភាព ៩៥ (របៀបប្តូរពាក្យសំងាត់)



- បញ្ចូល "ពាក្យសំងាត់ចាស់" ដែលអ្នកទទួលបានពីក្រសួងសុខាភិបាល (រូបភាព៩៦ លេខ១)
- វាយបញ្ចូល "ពាក្យសំងាត់ថ្មី" (រូបភាព៩៦ លេខ២)
- បន្ទាប់អ្នកត្រូវបញ្ជាក់ពាក្យសំងាត់ថ្មីរបស់អ្នក (រូបភាព៩៦ លេខ៣)
- ធីកនៅក្នុងប្រអប់ពីមុខពាក្យ "ប្តូរពាក្យសំងាត់សម្រាប់" (រូបភាព៩៦ លេខ៤)
- ចុចលើប្រអប់ "ប្តូរពាក្យសំងាត់" (រូបភាព៩៦ លេខ៥)

រូបភាព ៩៦ (របៀបប្តូរពាក្យសំងាត់)



- បន្ទាប់មកអ្នកនឹងបានឃើញរូបភាព ៩៧ខាងក្រោមនេះបញ្ជាក់អំពីការផ្លាស់ប្តូរពាក្យសំងាត់របស់អ្នក។

រូបភាព ៩៧



គោលការណ៍ណែនាំ
សម្រាប់ការគ្រប់គ្រងប្រព័ន្ធព័ត៌មានវិទ្យាសុខាភិបាលកម្ពុជា
តាមរយៈគេហទំព័រ

✵✵✵✵✵

ជំពូក ២
សម្រាប់មូលដ្ឋានសុខាភិបាលសេវាឯកជន
និង
អង្គការមិនមែនរដ្ឋាភិបាល

I. ទស្សនៈទូទៅ

សៀវភៅណែនាំសម្រាប់ការគ្រប់គ្រងប្រព័ន្ធព័ត៌មានសុខាភិបាលកម្ពុជាតាមរយៈគេហទំព័រ ផ្នែកមូលដ្ឋានសុខាភិបាលសេវាឯកជន និងអង្គការមិនមែនរដ្ឋាភិបាលនេះ មានគោលបំណងជាជំនួយដល់ការបញ្ចូលទិន្នន័យ ការប្រើប្រាស់របាយការណ៍ និងជួយពន្លឿនដល់ការផ្ញើរបាយការណ៍ពីថ្នាក់មូលដ្ឋានសុខាភិបាលមកកាន់ក្រសួងសុខាភិបាល ហើយជំពូកនេះនឹងត្រូវបានប្រើប្រាស់ជាឯកសារគោល ក្នុងការបណ្តុះបណ្តាល និងវគ្គបំប៉នបន្ថែមទៅដល់មន្ត្រីសុខាភិបាលគ្រប់រូបដែលជាគ្រូបង្វឹកបន្ត។

១. ការចាប់ផ្តើមដំណើរការគេហទំព័រ

- វាយបញ្ចូលឈ្មោះគេហទំព័រ **www.hiscambodia.org** (មើលរូប ១ លេខ ១)
- វាយបញ្ចូលឈ្មោះអ្នកប្រើ។ ឧទាហរណ៍: msambath (មើលរូបភាព ១ លេខ ២)
- វាយបញ្ចូល “លេខសំងាត់”។ ឧទាហរណ៍:****** (មើលរូបភាព ១ លេខ ៣)
- វាយបញ្ចូលលេខ “កូតបញ្ជាក់” ចំនួនប្រាំខ្ទង់។ ឧទាហរណ៍:៧១៧៩៦ (មើលរូបភាព១ លេខ៤)
- ចុចលើប្រអប់ “ចូលប្រើប្រាស់” (មើលរូបភាព ១ លេខ ៥) វានឹងបង្ហាញដូចរូបភាព ២

រូបភាពទី ១



រូបភាពទី ២



II. ការបញ្ចូលទិន្នន័យ

❖ ការបញ្ចូលមូលដ្ឋានសុខាភិបាលរបស់អង្គការ និងសេវាឯកជន មានតែក្រសួងសុខាភិបាលប៉ុណ្ណោះដែលមានសិទ្ធិក្នុងការបង្កើត។

ការបញ្ចូលទិន្នន័យសេវាឯកជន និងអង្គការ

ទំរង់បញ្ចូលទិន្នន័យរបស់សេវាឯកជន និងអង្គការមានភាពប្រហាក់ប្រហែលគ្នាទៅនឹងសេវាសាធារណៈ។ ដូច្នេះយើងបង្ហាញអំពីរបៀបបញ្ចូលទិន្នន័យរបស់អង្គការ។

របៀបប្រើប្រាស់:

- ដំបូងអ្នកគ្រាន់តែចូលទៅលើ Menu បញ្ចូលទិន្នន័យ (មើលរូបភាពទី៣ លេខ១)
- ហើយជ្រើសរើសយកទិន្នន័យសេវាឯកជន ឬ ទិន្នន័យអង្គការទៅតាមមូលដ្ឋានរបស់អ្នក (រូបភាពទី៣ លេខ២)។ ឧទាហរណ៍៖ ជ្រើសរើសយកការបញ្ចូលទិន្នន័យរបស់អង្គការ ហើយចុចលើពាក្យ *ទិន្នន័យអង្គការ* (រូបភាពទី៣ លេខ២) នោះប្រព័ន្ធនឹងបង្ហាញដូចរូបភាពទី២។

រូបភាពទី ៣



- បន្ទាប់ពីអ្នកជ្រើសរើសទិន្នន័យអង្គការរួចហើយនោះ ប្រព័ន្ធនឹងបង្ហាញដូចរូបភាពខាងក្រោមនេះ (រូបភាពទី៤)
- ដំបូងសូមជ្រើសរើសកាលបរិច្ឆេទ ឆ្នាំ ខែណាមួយដែលអ្នកត្រូវបញ្ចូលទិន្នន័យ (រូបភាពទី៤ លេខ១ និង លេខ២)
- បន្ទាប់មកជ្រើសរើសតំបន់ ខេត្ត ស្រុកប្រតិបត្តិ និងមូលដ្ឋានសុខាភិបាល (រូបភាពទី៤ លេខ៣ លេខ៤ និង លេខ៥)
- ចុងក្រោយចុចលើពាក្យ *បញ្ចូលទិន្នន័យ* (រូបភាពទី៤ លេខ៦)ឧទាហរណ៍៖ បញ្ចូលទិន្នន័យ ឆ្នាំ២០០៩ ខែមករា នៅខេត្តប៉ៃលិន ស្រុកប៉ៃលិន មូលដ្ឋានសុខាភិបាល អង្គការម៉ារីស្តុបកម្ពុជា បន្ទាប់មកចុចលើពាក្យ *បញ្ចូលទិន្នន័យ* នោះវានឹងបង្ហាញដូចរូបទី៣

រូបភាពទី ៤



ដើម្បីផ្តល់ភាពងាយស្រួល និងជៀសវាងការភាន់ច្រឡំក្នុងការបញ្ចូលទិន្នន័យ នៅក្បាលទំព័រមាន បង្ហាញ មូលដ្ឋាសុខាភិបាល ឆ្នាំ ខែដែលអ្នកជ្រើសរើសសម្រាប់បញ្ចូលទិន្នន័យ (រូបភាពទី៥ លេខ១)

- ដំបូងជ្រើសរើសសេវាណាមួយ ហើយចុចលើសេវាដែលអ្នលត្រូវបញ្ចូល បន្ទាប់មកប្រព័ន្ធនឹង បង្ហាញ ដូចរូបខាងក្រោម (រូបភាពទី៥ លេខ២)។ ឧទាហរណ៍៖ ការពិនិត្យផ្ទៃពោះមុនពេល សម្រាល និងសម្រាលកូន
- ចាប់ផ្តើមបញ្ចូលទិន្នន័យទៅក្នុងកូឡោននីមួយៗ (រូបភាពទី៥ លេខ៤)។
- ចុងក្រោយសូមចុចយកពាក្យ *រក្សារទុក* (រូបភាពទី៥ លេខ៥) មានន័យថាទិន្នន័យទាំងអស់ត្រូវ បានរក្សារទុកក្នុងប្រព័ន្ធព័តមានសុខាភិបាលដោយស្វ័យប្រវត្តិ។ឧទាហរណ៍៖ បញ្ចូលទិន្នន័យ ទៅលើការពិនិត្យលើកទី១ ទី២ ទី៣ ។ល។ (រូបភាពទី៥ លេខ៤)

រូបភាពទី ៥



III. ការកែសម្រួលទិន្នន័យ

គោលបំណង ៖ នៅក្នុងការកែសម្រួលទិន្នន័យមានមុខងារកែតម្រូវទិន្នន័យណាមួយដែលមានកំហុស ឬបញ្ចូលមិនត្រឹមត្រូវទៅក្នុងប្រព័ន្ធទិន្នន័យ។

របៀបប្រើប្រាស់:

- ដំបូងត្រូវចូលទៅលើ **Menu** កែសម្រួលទិន្នន័យ (រូបភាពទី៦ លេខ១)
- ជ្រើសរើសទិន្នន័យមូលដ្ឋានណាមួយដែលអ្នកចង់កែសម្រួល ហើយចុចទៅលើទិន្នន័យមូលដ្ឋាននោះ (រូបភាពទី៦ លេខ២) បន្ទាប់មកវានឹងបង្ហាញជារូបភាពថ្មីមួយទៀត។ ឧទាហរណ៍៖ ធ្វើការកែសម្រួលទិន្នន័យរបស់អង្គការ ។

រូបភាពទី៦



បន្ទាប់ពីអ្នកជ្រើសរើសមូលដ្ឋានសុខាភិបាលដែលចង់ធ្វើការកែសម្រួលទិន្នន័យ នោះប្រព័ន្ធនឹងបង្ហាញដូច រូបភាពទី៧ ខាងក្រោមនេះ៖

- សូមជ្រើសរើសកាលបរិច្ឆេទ ឆ្នាំ ខែ ណាមួយដែលអ្នកចង់កែសម្រួល (រូបភាពទី៧ លេខ១ និង លេខ២)
- សូមជ្រើសរើសតំបន់ ខេត្ត ស្រុកប្រតិបត្តិ និងមូលដ្ឋានសុខាភិបាល (រូបភាពទី៧ លេខ៣ លេខ៤ និង លេខ៥)
- ចុចទៅលើពាក្យ *កែសម្រួលទិន្នន័យ* (រូបភាពទី៧ លេខ៦) ឧទាហរណ៍៖ អ្នកចង់កែទិន្នន័យរបស់អង្គការ ម៉ារីស្តុបកម្ពុជា នៅឆ្នាំ២០០៩ ខែមករា ខេត្តប៉ៃលិន ស្រុកប៉ៃលិន មូលដ្ឋានសុខាភិបាលអង្គការម៉ារីស្តុបកម្ពុជា នោះប្រព័ន្ធនឹងបង្ហាញដូចរូបភាពទី៧។

រូបភាពទី៧



បន្ទាប់ពីអ្នកបានជ្រើសរើសមូលដ្ឋានសុខាភិបាលដែលត្រូវកែតម្រូវរួចហើយនោះ វានឹងបង្ហាញដូចរូបភាពទី៨ ខាងក្រោមនេះ៖

- ដំបូងជ្រើសរើស ហើយចុចទៅលើសេវាណាមួយដែលអ្នកចង់កែសម្រួលទិន្នន័យនោះ (មើលរូបភាពទី៨ លេខ១)។ ឧទាហរណ៍៖ សកម្មភាពទូទៅ និងសកម្មភាពវះកាត់របស់មន្ទីរពេទ្យ នោះវានឹងបង្ហាញនូវក្បាលទំព័រ (មើលរូបភាពទី៨ លេខ២)
- បន្ទាប់មកអ្នកអាចកែសម្រួលទិន្នន័យ នៅក្នុងកូឡោនណាមួយដែលមិនត្រឹមត្រូវ (មើលរូបភាពទី៨ លេខ៣)
- បន្ទាប់ពីអ្នកធ្វើការកែទិន្នន័យរួចហើយ សូមជ្រើសរើសដោយចុចទៅលើពាក្យ *រក្សាទុក* ដើម្បីធ្វើការរក្សាទិន្នន័យទុកទៅក្នុងប្រព័ន្ធទិន្នន័យ។

រូបភាពទី៨



IV. បង្ហាញទិន្នន័យ

គោលបំណង ៖ មានមុខងារក្នុងការពិនិត្យនិងផ្ទៀងផ្ទាត់ទិន្នន័យដែលបានបញ្ចូលរួចហើយជាមួយនឹងរបាយការណ៍ដើមថាតើ វាមានភាពត្រឹមត្រូវដែរ ឬទេ។

របៀបប្រើប្រាស់:

- ដំបូងត្រូវចូលទៅលើ **Menu** បង្ហាញទិន្នន័យ (រូបភាពទី៩ លេខ១)
- ជ្រើសរើស ហើយចុចទៅលើទិន្នន័យណាមួយដែលអ្នកចង់មើល (រូបភាពទី៩ លេខ២)។ ឧទាហរណ៍៖ អ្នកជ្រើសរើស ហើយចុចលើទិន្នន័យរបស់អង្គការពេលនោះប្រព័ន្ធនឹងបង្ហាញដូចរូបភាពទី១០

រូបភាពទី៩



បន្ទាប់ពីអ្នកជ្រើសរើសមូលដ្ឋានសុខាភិបាលដែលចង់ធ្វើការបង្ហាញទិន្នន័យ នោះប្រព័ន្ធនឹងបង្ហាញដូចរូបភាពទី១០ ខាងក្រោមនេះ៖

- សូមជ្រើសរើសកាលបរិច្ឆេទ ឆ្នាំ ខែ ណាមួយដែលអ្នកចង់បង្ហាញ (រូបភាពទី១០ លេខ១ និងលេខ២)
- សូមជ្រើសរើសតំបន់ ខេត្ត ស្រុកប្រតិបត្តិ និងមូលដ្ឋានសុខាភិបាល (រូបភាពទី១០ លេខ៣ លេខ៤ និង លេខ៥)
- ចុចទៅលើពាក្យ *បង្ហាញទិន្នន័យ* (រូបភាពទី១០ លេខ៦)។ ឧទាហរណ៍ ៖ អ្នកចង់បង្ហាញទិន្នន័យរបស់អង្គការ ម៉ារីស្តុបកម្ពុជា នៅឆ្នាំ២០០៩ ខែមករា ខេត្តប៉ៃលិន ស្រុកប៉ៃលិន មូលដ្ឋានសុខាភិបាល អង្គការម៉ារីស្តុបកម្ពុជា នោះប្រព័ន្ធនឹងបង្ហាញដូចរូបភាពទី១១។

រូបភាពទី១០



បន្ទាប់ពីអ្នកបានជ្រើសរើសមូលដ្ឋានសុខាភិបាលដែលអ្នកចង់បង្ហាញរួចហើយនោះ វានឹងបង្ហាញដូចរូបភាពទី១១ ខាងក្រោមនេះ៖

- ដំបូងជ្រើសរើស ហើយចុចទៅលើសេវាណាមួយដែលអ្នកចង់មើល (មើលរូបភាពទី១១ លេខ១) ឧទាហរណ៍៖ សកម្មភាពទូទៅ និងសកម្មភាពវះកាត់របស់មន្ទីរពេទ្យ នោះវានឹងបង្ហាញនូវក្បាលទំព័រ (មើលរូបភាពទី១១ លេខ២)
- នៅក្នុងកូឡោននីមួយៗគឺជាតួលេខ ឬទិន្នន័យដែលអ្នកបានបញ្ចូល និងចំនួនទិន្នន័យសរុប (មើលរូបភាពទី១១ លេខ៣)។

រូបភាពទី១១



V. ប្រភេទរបាយការណ៍

នៅក្នុងប្រព័ន្ធព័ត៌មានវិទ្យាសុខាភិបាលកម្ពុជាតាមរយៈគេហទំព័រ ជាភាសាអង់គ្លេសដែលគេហៅថា HMIS Web Database បានប្រមូលផ្តុំរបាយការណ៍ចំបងៗចំនួន ២ ក្នុងនោះរួមមាន៖

១. បញ្ជីរបាយការណ៍ (Inventory Report)

២. របាយការណ៍ប្រចាំខែ (HO2 & HC1)

១. បញ្ជីរបាយការណ៍ (Inventory Report) ប្រើប្រាស់សម្រាប់ពិនិត្យមើលថា តើមូលដ្ឋានសុខាភិបាលណាដែលមានភាពយឺតយ៉ាវក្នុងការបញ្ចូលទិន្នន័យជារៀងរាល់ខែ និងដើម្បីផ្តល់ព័ត៌មានត្រឡប់។ បញ្ជីរបាយការណ៍នេះបែងចែកជាផ្នែកតូចៗ រួមមាន៖

- បញ្ជីរបាយការណ៍ទូទាំងប្រទេស
- បញ្ជីរបាយការណ៍សម្រាប់មន្ទីរពេទ្យជាតិ
- បញ្ជីរបាយការណ៍ប្រចាំខេត្ត
- បញ្ជីរបាយការណ៍សម្រាប់មន្ទីរពេទ្យឯកជន
- បញ្ជីរបាយការណ៍សម្រាប់អង្គការ

២. របាយការណ៍ប្រចាំខែ (HO2 & HC1) បែងចែកជាពីរទម្រង់ដែលត្រូវបានមូលដ្ឋានសុខាភិបាលប្រើប្រាស់ជាប្រចាំសម្រាប់ធ្វើការរាយការណ៍ និងដើម្បីកំណត់រកភាពខ្លាំង និងភាពខ្សោយ ក៏ដូចជាការរក្សារទុកជាឯកសារសម្រាប់ស្ថាប័នសុខាភិបាលរបស់ខ្លួន។

- **HO2** ជាគំរូរបាយការណ៍ប្រចាំខែសម្រាប់មន្ទីរពេទ្យប្រើប្រាស់ទាំងសេវាសាធារណៈ និងសេវាឯកជន ។
- **HC1** ជាគំរូរបាយការណ៍សម្រាប់មណ្ឌលសុខភាព ក៏ប៉ុន្តែទំរង់ HC1 នេះពេលខ្លះក៏ត្រូវបានគេប្រើប្រាស់នៅតាមមន្ទីរពេទ្យឯកជនមួយចំនួនដែរ ។

៣. បញ្ជីរបាយការណ៍

ដូចដែលយើងបានឃើញនៅក្នុងចំណុច "ប្រភេទរបាយការណ៍" បញ្ជីរបាយការណ៍មានទំរង់គំរូចំនួន៥ទៀត ដែលអាចអោយយើងយកមកប្រើប្រាស់តាមតំរូវការ។ ខាងក្រោមនេះយើងនឹងបង្ហាញពីការប្រើប្រាស់របាយការណ៍នីមួយៗតាមលំដាប់លំដោយ។ ដំបូងលោកអ្នកត្រូវចូលទៅកាន់គេហទំព័រដើម។ ដើម្បីចូលទៅកាន់គេហទំព័រ សូមមើលរូបភាព១២ និងរូបភាព១៣ នៃ "របៀបចូលកាន់គេហទំព័រដើម"។

✄ *របៀបប្រើប្រាស់បញ្ជីរបាយការណ៍ទូទាំងប្រទេស*

- ចុចលើពាក្យបញ្ជីរបាយការណ៍នៅលើ Menu "បញ្ជីរបាយការណ៍" (រូបទី១២ លេខ ១)
- ចុចលើពាក្យ "ទូទាំងប្រទេស" (រូបទី១២ លេខ ២)
- បន្ទាប់មកលោកអ្នកនឹងបានឃើញរូបភាព បង្ហាញដូចរូបភាព ១៣

រូបភាពទី ១២



រូបភាព ១៣



- ចុចលើពាក្យ"ឆ្នាំ" រួចជ្រើសរើសយកឆ្នាំណាដែលអ្នកចង់បង្ហាញ (រូបភាព១៣ លេខ១)
- ចុចលើពាក្យ "ពីខែ" (រូបភាព១៣ លេខ២) និងពាក្យ "ដល់ខែ" (រូបភាព១៣ លេខ៣) ដើម្បីរើសយកខែណាដែលអ្នកចង់បង្ហាញ
- រួចចុចលើពាក្យ "បង្ហាញរបាយការណ៍" (រូបភាព១៣ លេខ៤)
- បញ្ជីរបាយការណ៍នឹងបង្ហាញដូចរូបភាព១៤ ដែលមានរាយឈ្មោះទូទាំង២៤ ខេត្តក្រុង (និងមន្ទីរពេទ្យជាតិដែលត្រូវបានរាប់បញ្ចូលផងដែរ) និងបង្ហាញចាប់ពីខែមករា រហូតដល់ខែធ្នូ (មើលរូបភាព១៤ លេខ១ និងលេខ២)
- អ្នកអាចមើលខេត្តផ្សេងៗទៀត ដោយចុចលើបន្ទាត់នៅខាងស្តាំ និងអូសចុះក្រោម (មើលរូបភាព ១៤ លេខ៣)។

រូបភាព ១៤



រូបភាព ១៥



- ប្រសិនបើអ្នកចង់បានជាឯកសារ Excel ចុចលើពាក្យ "របាយការណ៍សង្ខេបទូទាំងប្រទេស" (មើលរូបភាព១៥ លេខ១)
- ប្រសិនបើចង់បើកមើល ចុចលើពាក្យ "Open with" រួចចុច "OK" (មើលរូបភាព១៥ លេខ២ និង លេខ៤)
- ប្រសិនបើចង់រក្សាទុក ចុចលើពាក្យ "Save file" រួចចុច "OK" (មើលរូបភាព១៥ លេខ៣ និង លេខ៤)
- បន្ទាប់មកឯកសារជា Excel នឹងបង្ហាញដូចរូបភាព ៧។

រូបភាព ១៦



✄ របៀបប្រើប្រាស់បញ្ជីរបាយការណ៍សម្រាប់មន្ទីរពេទ្យជាតិ

- ដាក់ Mouse លើ Menu "បញ្ជីរបាយការណ៍" រួចជ្រើសរើសពាក្យ"មន្ទីរពេទ្យជាតិ" (មើលរូបភាព ១៧ លេខ១ និងលេខ២)
- លោកអ្នកនឹងបានឃើញរូបភាពដែលមានរាយឈ្មោះគ្រប់មន្ទីរពេទ្យជាតិ (រូបភាព១៨)
- ជ្រើសរើសយកឆ្នាំ (រូបភាព១៨ លេខ១) យកខែ (រូបភាព១៨ លេខ២ និង៣) រួចចុចលើពាក្យ "បង្ហាញរបាយការណ៍" (រូបភាព១៨ លេខ៤)
- ប្រសិនបើលោកអ្នកចង់អោយបង្ហាញជាឯកសារ Excel ចេញមកខាងក្រៅចុចលើពាក្យ "របាយការណ៍មន្ទីរពេទ្យជាតិទូទាំងប្រទេស" (រូបភាព១៨ លេខ៥) រួចធ្វើការរក្សារទុក ឬចង់បើកមើល សូមមើលជំហានទាំងនេះនៅក្នុង "បញ្ជីរបាយការណ៍ទូទាំងប្រទេស" ដែលបានរៀបរាប់ខាងលើ ។

រូបភាព ១៨



រូបភាព ១៩



✂ របៀបប្រើប្រាស់បញ្ជីរបាយការណ៍ប្រចាំខេត្ត

- ចុចលើ Menu "បញ្ជីរបាយការណ៍" រួចជ្រើសរើសពាក្យ "ប្រចាំខេត្ត" (មើលរូបភាព២០ លេខ១ និងលេខ២)
- ចំពោះរបាយការណ៍ប្រចាំខេត្ត លោកអ្នកអាចជ្រើសរើសយកខេត្តណាមួយដែលអ្នកចង់មើល (មើលរូបភាព២១ លេខ១)

រូបភាព ២០



រូបភាព ២១



- ជ្រើសរើសយកឆ្នាំ (រូបភាព២១ លេខ២) យកខែ (រូបភាព២១ លេខ៣ និង៤) និងចុចលើពាក្យ "បង្ហាញរបាយការណ៍" ដើម្បីមើល (រូបភាព២១ លេខ៥)
- ចុចលើពាក្យ "របាយការណ៍សង្ខេបទូទាំងខេត្ត" ដើម្បីបង្ហាញឯកសារជា Excel (រូបភាព២១ លេខ៦)
- និងសូមអនុវត្តជំហានបន្តបន្ទាប់ (ដូចបានរៀបរាប់នៅក្នុង"បញ្ជីរបាយការណ៍ទូទាំងប្រទេស")

✂ របៀបប្រើប្រាស់បញ្ជីរបាយការណ៍សម្រាប់មន្ទីរពេទ្យឯកជន និងសម្រាប់អង្គការ

- ចំពោះបញ្ជីរបាយការណ៍ទាំងពីរខាងលើ គឺមានលក្ខណៈដូចគ្នាទៅនឹងការប្រើប្រាស់បញ្ជីរបាយការណ៍ប្រចាំខេត្តដូច្នោះដែរ។
- ប៉ុន្តែលោកអ្នកអាចជ្រើសរើសយកជារបាយការណ៍ទូទាំងប្រទេសក៏បាន ឬជ្រើសរើសតែខេត្តណាមួយដែលលោកអ្នកចង់មើលក៏បាន ។

៤. គំរូរបាយការណ៍ប្រចាំខែ (HO2 & HC1)

✂ របៀបប្រើប្រាស់គំរូរបាយការណ៍ប្រចាំខែសម្រាប់មណ្ឌលសុខភាព (HC1)

HMIS Web Database នេះមានលក្ខណៈពិសេសមួយ គឺលោកអ្នកអាចចូលទៅកាន់របាយការណ៍នីមួយៗបានដោយងាយស្រួល ដោយគ្រាន់តែចុះឈ្មោះចូលទៅកាន់ទំព័រដំបូងរបស់គេហទំព័រ (មើលចំណុច១ ពី "របៀបចូលទៅកាន់គេហទំព័រដើម" ក្នុងផ្នែកទី៣ នៃរបៀបប្រើប្រាស់របាយការណ៍នៅក្នុង HMIS Web Database) រួចរាល់ លោកអ្នកនឹងបានឃើញ Menu ដែលមានវាយប្រភេទ របាយការណ៍ធំៗទាំង ៤ ដែលក្នុងនោះគំរូរបាយការណ៍ HC1 និង HO2 គឺស្ថិតនៅក្នុង Menu ឈ្មោះ "គំរូរបាយការណ៍ប្រចាំខែ" (មើលរូបភាព ២២)។

រូបភាព ២២



រូបភាព ២៣



- ចុចលើ Menu គំរូរបាយការណ៍ប្រចាំខែ (រូបភាព១២ លេខ១) រួចចុចលើពាក្យ "សម្រាប់មណ្ឌលសុខភាព" (រូបភាព២២ លេខ២)
- លោកអ្នកនឹងឃើញផ្ទាំងរូបភាព ដូចរូបភាពលេខ ២៣
- នៅក្នុងប្រអប់ "សូមជ្រើសរើសកំឡុងពេល" (រូបភាព២៣ លេខ១ដល់លេខ៣) អ្នកអាចជ្រើសរើសយក ឆ្នាំខែណាដែលអ្នកចង់មើល និងនៅក្នុងប្រអប់ "សូមជ្រើសរើសរបាយការណ៍តាមថ្នាក់" ជ្រើសរើសរបាយការណ៍ថ្នាក់ជាតិ (រូបភាព២៣ លេខ៤ និងលេខ៥)
- ជ្រើសរើសរបាយការណ៍ថ្នាក់ខេត្ត (មើលរូបភាព២៤ លេខ១ ដល់លេខ៣)

- ជ្រើសរើសរបាយការណ៍ថ្នាក់ស្រុក (មើលរូបភាព២៥ លេខ១ ដល់លេខ៤)
- ជ្រើសរើសរបាយការណ៍ថ្នាក់មូលដ្ឋានសុខាភិបាល (មើលរូបភាព២៦ លេខ១ដល់លេខ៥)
- បន្ទាប់ពីលោកអ្នកធ្វើការជ្រើសរើសរួច និងចុចនៅលើប្រអប់ "ទាញយករបាយការណ៍" នោះ លោកអ្នកនឹងឃើញរូបភាពជាឯកសារ Excel ដូចរូបភាព ២៧ ។

រូបភាព ២៤



រូបភាព ២៥



រូបភាព ២៦



រូបភាព ២៧



✂ របៀបប្រើប្រាស់គំរូរបាយការណ៍ប្រចាំខែសម្រាប់មន្ទីរពេទ្យ (HO2)

- នៅលើ *Menu* "គំរូរបាយការណ៍ប្រចាំខែ" ជ្រើសរើសយកពាក្យ "សម្រាប់មន្ទីរពេទ្យ" (រូបភាព២៨ លេខ១ និងលេខ២)។

រូបភាព ២៨



រូបភាព ២៩



- នៅក្នុងគំរូ HO2 នេះក៏មិនខុសពី HC1 ខាងលើដែរ លោកអ្នកអាចជ្រើសរើសយកឆ្នាំ ខែ នៅក្នុងប្រអប់ "សូមជ្រើសរើសកំឡុងពេល" (រូបភាព២៩ លេខ១ ដល់លេខ៣) ជ្រើសរើសថ្នាក់របាយការណ៍ជាថ្នាក់ជាតិ (រូបភាព២៩ លេខ៤) ឬជ្រើសរើសខេត្ត ស្រុក និងមូលដ្ឋានសុខាភិបាល រួចចុចលើ "ទាញយករបាយការណ៍" (រូបភាព២៩ លេខ៥) រូបភាពជាឯកសារ Excel នឹងបង្ហាញដូចរូបភាព ៣០។

រូបភាព ៣០



- សូមមើលរូបភាពរបាយការណ៍តាមថ្នាក់ខេត្ត
- រូបភាពរបាយការណ៍តាមថ្នាក់ស្រុក
- និងរូបភាពរបាយការណ៍តាមថ្នាក់មូលដ្ឋានសុខាភិបាល

គោលការណ៍ណែនាំ
សម្រាប់ការគ្រប់គ្រងប្រព័ន្ធព័ត៌មានវិទ្យាសុខាភិបាលកម្ពុជា
តាមរយៈគេហទំព័រ

✲✲✲✲✲

ជំពូក ៣
សម្រាប់កម្មវិធីការបង្ការការចម្លងមេរោគអេដស៍ពីម្ដាយទៅកូន
តាមវិធីសាស្ត្រឆ្លើយតបរួមគ្នា

I. វត្ថុបំណង

ជំពូក៣ ស្តីពីការបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូន តាមវិធីសាស្ត្រឆ្លើយតបរួមគ្នាមានគោលបំណងពង្រឹង និងបង្កើតកម្មវិធីបង្ការការចម្លងមេរោគអេដស៍ពី ម្តាយទៅកូនប្រកបដោយប្រសិទ្ធភាព ដើម្បីបុព្វហេតុនៃការឆ្ពោះទៅរកការគ្រប់គ្រងដ៏ល្អ។

មូលដ្ឋានទិន្នន័យរបស់កម្មវិធី ការបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូនតាមរយៈគេហទំព័រ គឺជាការគ្រប់គ្រងទិន្នន័យសុខាភិបាល ដែលត្រូវបានបញ្ចូលពីគ្រប់ថ្នាក់នៃមូលដ្ឋានសុខាភិបាលទូទាំងប្រទេសកម្ពុជា ដែលបានបង្កើតឡើងចាប់តាំងពីខែកក្កដា ឆ្នាំ២០១១។

មូលដ្ឋានទិន្នន័យទាំងនេះបានផ្តោតសំខាន់ទៅលើទម្រង់បីៈ

១. ទម្រង់របាយការណ៍ប្រចាំខែ ផ្នែកពិនិត្យផ្ទៃពោះ និងពន្យារកំណើត
២. ទម្រង់របាយការណ៍ប្រចាំខែ ផ្នែកសម្ភព
៣. ទម្រង់របាយការណ៍ប្រចាំខែ ផ្នែកកុមារប្រឈម (OI/ART)

II. ការចាប់ផ្តើមដំណើរការគេហទំព័រ

- វាយបញ្ចូលអាស័យដ្ឋានគេហទំព័រ www.hiscambodia.org (មើលរូប ១ លេខ ១)
- វាយបញ្ចូលឈ្មោះអ្នកប្រើ។ ឧទាហរណ៍: msambath (មើលរូបភាព ១ លេខ ២)
- វាយបញ្ចូល "លេខសំងាត់"។ ឧទាហរណ៍: ****** (មើលរូបភាព ១ លេខ ៣)
- វាយបញ្ចូលលេខ "កូតបញ្ជាក់" ចំនួនប្រាំខ្ទង់។ ឧទាហរណ៍:៧១៧៩៦ (មើលរូបភាព១ លេខ៤)
- ចុចលើប្រអប់ "ចូលប្រើប្រាស់" (មើលរូបភាព១ លេខ៥) វានឹងបង្ហាញដូចរូបភាព ២

រូបភាពទី១ (របៀបនៃការចូលទៅកាន់គេហទំព័រដំបូង)



- នៅក្នុងរូបភាពទី២នេះ ប្រព័ន្ធព័ត៌មានបានបង្ហាញជម្រើសពីរដែលអ្នកត្រូវតែធ្វើការជ្រើសរើសមួយក្នុងនោះផងដែរអ្នកត្រូវប្រាកដថាតើ ឈ្មោះអ្នកប្រើប្រាស់ និងលេខសម្ងាត់របស់អ្នកអាចប្រើបានជាមួយនឹងព័ត៌មានសុខាភិបាល MOH- HIS ឬក៏សម្រាប់កម្មវិធី MCH- HIS ។
  ១. MOH- HIS សម្រាប់ព័ត៌មានសុខាភិបាល MOH-HIS ៖ មានន័យថា នៅពេលដែលអ្នកចុចទៅលើជម្រើសនេះ ប្រព័ន្ធនឹងបង្ហាញទំព័រ ព័ត៌មានសុខាភិបាល MOH-HIS (រូបភាពទី២ លេខ១)
  ២. MCH- HIS សម្រាប់កម្មវិធី MCH- HIS ៖ មានន័យថា នៅពេលដែលអ្នកជ្រើសរើស ហើយចុចទៅលើជម្រើសនេះ ប្រព័ន្ធនឹងបង្ហាញទំព័រសម្រាប់កម្មវិធី MCH- HIS (រូបភាពទី២ លេខ២)
- ដូច្នេះនៅពេលដែលអ្នកជ្រើសរើសយកកម្មវិធី MCH- HIS វានិងបង្ហាញដូចរូបភាពទី៣ខាងក្រោមនេះ៖

រូបភាពទី២ (របៀបចូលទៅកាន់កម្មវិធី PMTCT)



រូបភាពទី៣



III. របៀបប្រើប្រាស់ព័ត៌មានការបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូន តាមវិធីសាស្ត្រឆ្លើយតបរួមគ្នានៅលើគេហទំព័រ

១. ពិនិត្យទិន្នន័យ

ពិនិត្យទិន្នន័យ មានមុខងារក្នុងការពិនិត្យ និងផ្ទៀងផ្ទាត់ទិន្នន័យដែលបានបញ្ចូលរួចហើយជាមួយនឹងរបាយការណ៍ដើមថាតើ វាមានភាពត្រឹមត្រូវដែរឬទេ។

- ជាដំបូងអ្នកត្រូវចុចចូលទៅក្នុងបញ្ជីរបាយការណ៍ ពិនិត្យទិន្នន័យ(រូបភាពទី៤ លេខ១)
- បន្ទាប់មកទម្រង់របាយការណ៍នឹងបង្ហាញឡើង (រូបភាពទី៤ លេខ២)
- អ្នកត្រូវចុចលើប្រអប់ *ជ្រើសរើសខេត្ត* (រូបភាពទី៤ លេខ២) ហើយធ្វើការជ្រើសរើសខេត្តណាមួយដែលអ្នកចង់ពិនិត្យទិន្នន័យ
- បន្ទាប់មកចុចលើប្រអប់ *ជ្រើសរើសស្រុកប្រតិបត្តិ* (រូបភាពទី៤ លេខ៣) ហើយធ្វើការជ្រើសរើសស្រុកប្រតិបត្តិរបស់អ្នក
- រួចពីនោះអ្នកត្រូវជ្រើសរើសមូលដ្ឋានសុខាភិបាលរបស់អ្នក ដោយចុចលើប្រអប់ *មូលដ្ឋានសុខាភិបាល* (រូបភាពទី៤ លេខ៤)
- រួចហើយអ្នកអាចជ្រើសរើសឆ្នាំតាមដែលអ្នកត្រូវការ (រូបភាពទី៤ លេខ៥)
- ជំហានបន្ទាប់អ្នកត្រូវជ្រើសរើសខែដូចដែលអ្នកត្រូវការ (រូបភាពទី៤ លេខ៦)
- បន្ទាប់មកទៀតអ្នកចាប់ផ្តើមចុចយកប្រអប់ *ចាប់ផ្តើមពិនិត្យទិន្នន័យ* (រូបភាពទី៤ លេខ៧) ពេលនោះរបាយការណ៍សម្រាប់ពិនិត្យទិន្នន័យនិងបង្ហាញដូចរូបភាពទី៥

រូបភាពទី៤ (របៀបចូលពិនិត្យទិន្នន័យប្រចាំឆ្នាំ)

រូបភាពទី៥ (ការពិនិត្យទិន្នន័យគំរូរបាយការណ៍ប្រចាំខែ ផ្នែក ANC)



រូបភាពទី៥.១ (ការពិនិត្យទិន្នន័យគំរូរបាយការណ៍ប្រចាំខែ ផ្នែកសម្ភព)

រូបភាពទី៥.២ (ការពិនិត្យទិន្នន័យគំរូរបាយការណ៍ប្រចាំខែ ផ្នែកOI/ART)



តាមរយៈការបង្ហាញរបស់របាយកាណ៍ពិនិត្យទិន្នន័យ(រូបភាពទី៥) អ្នកអាចទាញពិនិត្យមើលតាមផ្នែកនីមួយៗបានដូចជាសម្រាប់មណ្ឌលសុខភាពផ្ទែលសម្តពនិងផ្នែកOI/ARI ដោយធ្វើការផ្ទៀងផ្ទាត់ជាមួយទិន្នន័យដើម (សូមមើលលេខ១ រូបភាពទី ៥)

- ក្រោយពេលការទាញរបាយការណ៍បានហើយ អ្នកចាប់ផ្តើមពិនិត្យទិន្នន័យឡើងវិញដោយអ្នកមើលលើប្រអប់នៅខាងស្តាំរបស់សំណួរនីមួយៗ (សូមមើលលេខ២ រូបភាពទី៥)ជាមួយសំណៅឯកសារដើមរបស់ទិន្នន័យថាមានភាពត្រឹមត្រូវឬទេ។

២. បញ្ចូលទិន្នន័យ

បញ្ចូលទិន្នន័យ គឺមានតួនាទីក្នុងការទទួលយកទិន្នន័យថ្មីទាំងអស់របស់មណ្ឌលសុខភាព និង មន្ទីរពេទ្យជាប្រចាំខែ។

រូបភាពទី៦ (របៀបបញ្ចូលជ្រើសរើសពេលវេលា មូលដ្ឋានសុខាភិបាល សម្រាប់បញ្ចូលទិន្នន័យ)

ដើម្បីឈានទៅដល់ការបញ្ចូលទិន្នន័យអ្នកត្រូវ៖

- ចុចប្រអប់បញ្ចូលទិន្នន័យ (សូមមើរូបភាពទី៦ លេខ១) បន្ទាប់មករូបភាពរបស់បញ្ជីទិន្នន័យ និង បង្ហាញឡើងដូចរូបភាពទី៦ ផ្នែកខាងស្តាំដៃ
- សូមចុចលើប្រអប់ខេត្តដើម្បីរើសយកខេត្តណាមួយដែលអ្នកត្រូវបញ្ចូល (សូមមើលរូបភាពទី៦ លេខ២)
- ជំហានបន្តមកទៀត អ្នកត្រូវចុចលើប្ញូតុងរើសយកស្រុកប្រតិបត្តិ(សូមមើលរូបភាពទី៦ លេខ៣)
- បន្ទាប់មកចាប់ផ្តើមជ្រើសរើសយកឆ្នាំ(សូមមើលរូបភាពទី៦ លេខ៥)
- រួចហើយអ្នកត្រូវរើសយកខែណាមួយសម្រាប់បញ្ចូលទិន្នន័យ(សូមមើលរូបភាពទី៦ លេខ៦)
- ចុងក្រោយអ្នកត្រូវចុចលើប្រអប់ *ចាប់ផ្តើមបញ្ចូលទិន្នន័យ* (សូមមើលរូបភាពទី៦ លេខ៧) ជាចុងក្រោយអ្នកនិងឃើញផ្ទាំងសម្រាប់បញ្ចូលទិន្នន័យដូចខាងក្រោម(រូបភាពទី៧)

រូបភាពទី៧ (ទម្រង់គំរូរបាយការណ៍សម្រាប់បញ្ចូលទិន្នន័យរបស់មណ្ឌលសុខភាព)



ក្រោយពេលទម្រង់របាយការណ៍សម្រាប់PMTCTបានបង្កើតឡើងហើយអ្នកអាចចាប់ផ្តើមធ្វើការបញ្ចូលទិន្នន័យបានដោយងាយស្រួល៖

- ជ្រើសរើសទម្រង់សម្រាប់បញ្ចូលដូចជារបាយការណ៍សម្រាប់មណ្ឌលសុខភាព ផ្នែកសម្ភព ឬក៏ផ្នែកOI/ART(សូមមើលរូបភាពទី៧ លេខ១)
- បន្ទាប់មកអ្នកអាចវាយបញ្ចូលទិន្នន័យទៅក្នុងប្រអប់ខាងស្តាំដៃ(មើលរូបភាពទី៧ លេខ២) ទៅក្នុងទម្រង់នីមួយៗតាមរបាយការណ៍ដើមរបស់អ្នក។ ក្រោយការបញ្ចូលទិន្នន័យ តាមទម្រង់នីមួយៗចប់ហើយ អ្នកត្រូវចុចទៅលើប្រអប់*រក្សារទុក* (មើលរូបភាព៧ លេខ៣)ខាងក្រោមផ្នែកខាងស្តាំ ដើម្បីរក្សារទុកទិន្នន័យ ទាំងអស់ដែលអ្នកបានវាយបញ្ចូលរួចហើយ។

ចំណាំ៖ *ការចុចលើប្រអប់រក្សារទុក គឺមានសារសំខាន់ណាស់រាល់ពេលដែលអ្នកបញ្ចូលទិន្នន័យ ពីព្រោះទិន្នន័យទាំងអស់ដែលអ្នកបានបញ្ចូលគឺត្រូវបានរក្សាទុកនៅកន្លែងដែលមានសុវត្ថិភាព។*

៣. កែទិន្នន័យ

កែទិន្នន័យ៖ មានមុខងារកែតម្រូវទិន្នន័យណាមួយដែលមានកំហុស ឬបញ្ចូលមិនត្រឹមត្រូវនៅក្នុងប្រព័ន្ធទិន្នន័យ។

1. ដំបូងអ្នកគ្រាន់តែចូលទៅលើ **Menu** ជ្រើសរើសពាក្យ *កែទិន្នន័យ* នោះប្រព័ន្ធនិងបង្ហាញពី *ជម្រើសទិន្នន័យសម្រាប់ធ្វើការកែសម្រួល*
2. បន្ទាប់មកសូមជ្រើសរើស ខេត្ត ស្រុកប្រតិបត្តិ មូលដ្ឋានសុខាភិបាល ឆ្នាំ ខែ ណាមួយដែលអ្នកចង់កែសម្រួល(មើលរូបភាពទី៨ លេខ១ ២ ៣ ៤ ៥ និងលេខ៦) ហើយចុចទៅលើប្រអប់ ***ចាប់ផ្តើមកែសម្រួលទិន្នន័យ*** (មើលរូបភាពទី៨ លេខ៧)។ បន្ទាប់មកវានិងបង្ហាញដូចរូបភាពទី៩។
ឧទាហរណ៍៖ អ្នកជ្រើសរើសយកខេត្តបន្ទាយមានជ័យ ស្រុកប្រតិបត្តិមង្គលបូរី មូលដ្ឋានសុខាភិបាលម្កាក់ ឆ្នាំ២០១១ ខែមករា រួចហើយចុចលើពាក្យ ចាប់ផ្តើមកែសម្រួលទិន្នន័យ នោះប្រព័ន្ធនឹងបង្ហាញដូចរូបភាពទី៩។

រូបភាពទី៨ (របៀបចូលទៅកែទិន្នន័យ)



នៅក្នុងការកែសម្រួលទិន្នន័យ មានទម្រង់របាយការណ៍៣ប្រភេទដែលត្រូវជ្រើសរើសដូចជា៖ ទម្រង់សម្រាប់ពិនិត្យផ្ទៃពោះ និងពន្យាកំណើត (ANC & Birth Spacing) ទម្រង់សម្រាប់ផ្នែកសម្ភព និងទម្រង់

សម្រាប់ផ្នែក OI/ART។ ដូច្នេះសូមធ្វើការជ្រើសរើសទម្រង់របាយការណ៍ណាមួយដែលអ្នកចង់កែសម្រួលទិន្នន័យ (សូមមើលរូបភាពទី៩ លេខ១)។

- នៅពេលដែលអ្នកជ្រើសរើសទម្រង់របាយការណ៍ណាមួយ នោះវានិងបង្ហាញប្រភេទរបាយការណ៍ប្រចាំខែ ឆ្នាំ (មើលរូបភាពទី៩ លេខ២)។ **ឧទាហរណ៍៖** ទម្រង់សម្រាប់មណ្ឌលសុខភាព ប្រចាំខែមករា ឆ្នាំ២០១១ សម្រាប់មណ្ឌលសុខភាពម្កាក់ ស្រុកប្រតិបត្តិមង្គលបូរី ខេត្តបន្ទាយមានជ័យ (មើលរូបភាពទី៩ លេខ២)។
- បន្ទាប់មកអ្នកអាចធ្វើការកែសម្រួលទិន្នន័យរបស់អ្នកនៅក្នុងប្រអប់ខាងស្តាំ (មើលរូបភាពទី៩ លេខ៣)
- ចុងក្រោយបន្ទាប់ពីកែទិន្នន័យរួចហើយ សូមចុចលើប្រអប់ ***រក្សារទុក*** នៅក្នុងប្រអប់ខាងស្តាំផ្នែកខាងក្រោមដើម្បីរក្សារទុកទិន្នន័យទាំងអស់ទៅក្នុងប្រព័ន្ធ (សូមមើលរូបភាពទី៩ លេខ៤)។ **ឧទាហរណ៍៖** ទម្រង់សម្រាប់មណ្ឌលសុខភាព (សូមមើលរូបភាពទី៩ លេខ២)។ សូមធ្វើការកែសម្រួលទិន្នន័យណាមួយដែលអ្នកបានបញ្ចូលខុសនៅក្នុងប្រអប់ខាងស្តាំ បន្ទាប់មកចុចទៅលើពាក្យ ***រក្សារទុក*** (សូមមើលរូបភាពទី៩ លេខ៣ និង ៤)។

រូបភាពទី៩ (ទម្រង់របាយការណ៍សម្រាប់កែសម្រួលទិន្នន័យ)



៤. ចំនួនរបាយការណ៍តាមខែ

ចំនួនរបាយការណ៍តាមខែ៖ មានមុខងារតាមដានទិន្នន័យនៅតាមមូលដ្ឋានសុខាភិបាល តាមខែ ឆ្នាំណា ដែលបានបញ្ចូលទៅក្នុងប្រព័ន្ធព័ត៌មាន។

1. ដំបូងគ្រាន់តែចូលទៅលើ **Menu** ជ្រើសរើសពាក្យ *ចំនួនរបាយការណ៍តាមខែ* (រូបភាពទី១០ លេខ១)
2. ជ្រើសរើសឆ្នាំណាមួយដែលអ្នកចង់មើល (រូបភាពទី១០ លេខ២)។ បន្ទាប់មក ប្រព័ន្ធនឹងបង្ហាញ ចំនួនរបាយការណ៍តាមខែថ្នាក់ជាតិសម្រាប់ឆ្នាំដែលអ្នកបានជ្រើសរើស ទៅតាមខែ និងតាមខេត្ត នីមួយៗនៅទូទាំងប្រទេស (រូបភាពទី១០ លេខ៣ និងលេខ៤)។ ក្នុងនោះដែរក៏ មានបង្ហាញរបាយការណ៍សរុបទូទាំងប្រទេសតាមខែ នីមួយៗផងដែរ (រូបភាពទី១០ លេខ៥)។ ឧទាហរណ៍៖ អ្នកជ្រើសរើសយកឆ្នាំ២០១១ នោះចំនួនរបាយការណ៍តាមខែ និងតាមខេត្ត ទាំងអស់បង្ហាញដូចរូបភាពទី១០ ខាងក្រោម។

3. របាយការណ៍ទាំងអស់នេះក៏អាចបំលែងចេញជាExcel Fileផងដែរ ដោយគ្រាន់តែចុចលើប្រអប់ *បំលែងជា Excel File* (រូបភាពទី១០ លេខ៦)។
4. លើសពីនេះទៅទៀតនោះអ្នកក៏អាចចូលទៅមើល របាយការណ៍លម្អិតនៅតាមមូលដ្ឋានសុខាភិបាលតាមខេត្តនីមួយៗ ដោយគ្រាន់តែចុចលើពាក្យ ***លម្អិត*** នៅផ្នែកខាងស្តាំនៃខេត្តណាមួយដែលអ្នកចង់មើល(រូបភាពទី១០ លេខ៧) បន្ទាប់មកវានឹងបង្ហាញដូចរូបភាពទី១១។

រូបភាពទី១០ (គំរូចំនួនរបាយការណ៍តាមខែថ្នាក់ជាតិ)



លេខ	ឈ្មោះខេត្ត	មករា	កុម្ភៈ	មិនា	មេសា	ឧសភា	មិថុនា	កក្កដា	សីហា	កញ្ញា	តុលា	វិច្ឆិកា	ធ្នូ	លំអិត
1	បន្ទាយមានជ័យ	100%	100%	100%	97%	95%	95%	0%	0%	0%	0%	0%	0%	លំអិត
2	បាត់ដំបង	99%	99%	99%	99%	99%	99%	0%	0%	0%	0%	0%	0%	លំអិត
3	កំពង់ចាម	99%	98%	98%	84%	84%	74%	0%	0%	0%	0%	0%	0%	លំអិត
4	កំពង់ឆ្នាំង	100%	100%	100%	100%	100%	100%	0%	0%	0%	0%	0%	0%	លំអិត
5	កំពង់ស្ពឺ	70%	70%	70%	94%	94%	94%	0%	0%	0%	0%	0%	0%	លំអិត
6	កំពង់ធំ	100%	100%	100%	100%	100%	100%	0%	0%	0%	0%	0%	0%	លំអិត
7	កំពត	100%	100%	100%	91%	91%	91%	0%	0%	0%	0%	0%	0%	លំអិត
8	កណ្តាល	89%	89%	89%	89%	89%	89%	0%	0%	0%	0%	0%	0%	លំអិត
9	កោះកុង	93%	93%	93%	93%	93%	79%	0%	0%	0%	0%	0%	0%	លំអិត
10	ក្រចេះ	0%	0%	0%	0%	0%	0%	0%	0%	0%	0%	0%	0%	លំអិត
11	មណ្ឌលគិរី	0%	0%	0%	0%	0%	0%	0%	0%	0%	0%	0%	0%	លំអិត
12	ភ្នំពេញ	38%	38%	38%	38%	38%	38%	0%	0%	0%	0%	0%	0%	លំអិត
13	ព្រះវិហារ	14%	14%	14%	14%	14%	16%	0%	0%	0%	0%	0%	0%	លំអិត
14	ព្រៃវែង	100%	100%	100%	100%	95%	93%	0%	0%	0%	0%	0%	0%	លំអិត
15	ពោធិ៍សាត់	100%	100%	100%	100%	97%	97%	0%	0%	0%	0%	0%	0%	លំអិត
16	រតនគិរី	0%	0%	0%	0%	0%	0%	0%	0%	0%	0%	0%	0%	លំអិត
17	សៀមរាប	99%	99%	99%	92%	92%	93%	0%	0%	0%	0%	0%	0%	លំអិត
18	ខេត្តព្រះសីហនុ	100%	100%	92%	92%	92%	92%	0%	0%	0%	0%	0%	0%	លំអិត
19	ស្ទឹងត្រែង	89%	90%	90%	90%	90%	90%	0%	0%	0%	0%	0%	0%	លំអិត
20	ស្វាយរៀង	98%	98%	98%	98%	98%	90%	0%	0%	0%	0%	0%	0%	លំអិត
21	តាកែវ	0%	0%	0%	0%	0%	0%	0%	0%	0%	0%	0%	0%	លំអិត
22	ឧត្តរមានជ័យ	28%	28%	24%	24%	10%	10%	0%	0%	0%	0%	0%	0%	លំអិត
23	កែប	0%	0%	0%	0%	0%	0%	0%	0%	0%	0%	0%	0%	លំអិត
24	ប៉ៃលិន	100%	100%	100%	100%	100%	86%	0%	0%	0%	0%	0%	0%	លំអិត
25	មន្ទីរពេទ្យជាតិ	30%	30%	30%	30%	30%	30%	0%	0%	0%	0%	0%	0%	លំអិត
របាយការណ៍ទូទាំងប្រទេស		80%	80%	80%	78%	77%	75%	0%	0%	0%	0%	0%	0%	លំអិត

- បន្ទាប់ពីអ្នកបានជ្រើសរើសយកពាក្យ *លម្អិត* នៅខេត្តណាមួយដែលអ្នកចង់មើល វានិងបង្ហាញដូចរូបភាពទី១១ខាងក្រោមនេះ។ ក្នុងនោះដែរ អ្នកក៏អាចជ្រើសរើសយកឆ្នាំណាមួយ (រូបភាពទី១១ លេខ១)។

ឧទាហរណ៍៖ អ្នកជ្រើសរើសយកឆ្នាំ ២០១១ សម្រាប់ខេត្តបន្ទាយមានជ័យ នោះប្រព័ន្ធនឹងបង្ហាញមូលដ្ឋានសុខាភិបាលទាំងអស់នៅក្នុងខេត្តនេះ (រូបភាពទី១១ លេខ ១ ២ និងលេខ៣)។

- នៅក្នុងតារាងនិមួយៗបានបង្ហាញលេខ ១ និង លេខ 0 តាមខែ និងតាមមូលដ្ឋានសុខាភិបាលដែលមានន័យដូចខាងក្រោម៖

  លេខ១ មានន័យថា ទិន្នន័យបានបញ្ចូលទៅក្នុងប្រព័ន្ធរួចហើយ (រូបភាពទី១១ លេខ៤)

  លេខ0 មានន័យថា មិនទាន់បានបញ្ចូលទិន្នន័យទៅក្នុងប្រព័ន្ធនោះទេ (រូបភាពទី១១ លេខ៥)

- នៅក្នុងរបាយការណ៍នេះអ្នកក៏អាចបំលែងជា Excel File ដោយគ្រាន់តែចុចលើប្រអប់ ***បំលែងជា Excel File*** (រូបភាពទី១១ លេខ៦)។

រូបភាពទី១១ (ទម្រង់គំរូចំនួនរបាយការណ៍តាមខែ)



៥. របាយការណ៍

នៅក្នុង Menu របាយការណ៍នេះមានមុខងារគ្រប់គ្រងរបាយការណ៍ទាំងអស់របស់មូលដ្ឋានទិន្នន័យ កម្មវិធីបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូនដូចជា របាយការណ៍សម្រាប់ការពិនិត្យផ្ទៃពោះមុនសំរាល និងពន្យាកំណើត របាយការណ៍ផ្នែកសម្ភព និងរបាយការណ៍OI/ART។ នៅក្នុងរបាយការណ៍នេះ មានគ្រប់ថ្នាក់ជាប្រចាំខែ ប្រចាំឆមាស ប្រចាំឆ្នាំនៃមូលដ្ឋានសុខាភិបាលថ្នាក់ជាតិ ថ្នាក់ស្រុកប្រតិបត្តិ។

ការប្រើប្រាស់

ក្រោយពេលដែលអ្នកចុចលើប៊ូតុងរបស់*របាយការណ៍* (សូមមើលលេខ១ របស់រូបភាពទី១២)ហើយវានឹងបង្ហាញទម្រង់ *បញ្ចេញរបាយការណ៍* (ដូចរូបភាពទី១២)។

- បន្ទាប់ពីនោះអ្នកអាចជ្រើសរើសយករបាយការណ៍ណាមួយតាមតម្រូវការរបស់អ្នក (សូមមើលលេខ ២ រូបភាពទី១២) ដូចជារបាយការណ៍សរុបតាមទម្រង់នីមួយៗ ទម្រង់សម្រាប់មណ្ឌលសុខភាព។ របាយការណ៍ទាំងនោះមានលម្អិតជូនដូចក្នុងរូបភាពទី១២។

រូបភាពទី១២ (កន្លែងបញ្ចេញរបាយការណ៍)

ក្រោយពេលអ្នកចុចជ្រើសរើសយករបាយការណ៍រួចមក អ្នកនឹងបានឃើញទម្រង់រូបភាពទីមួយដូចរូបភាពទី១៣ ខាងក្រោម។ ដោយអនុវត្តតាមការណែនាំខាងក្រោម អ្នកនឹងអាចទាញយករបាយការណ៍ តាមការចង់បានរបស់អ្នក។

របៀបប្រើប្រាស់

- ជាដំបូងអ្នកត្រូវចូលក្នុង Menu*របាយការណ៍* (សូមមើលលេខ១ រូបភាពទី១៣) បន្ទាប់មកវានឹងបង្ហាញឡើងនូវផ្ទាំងមួយដែលស្ថិតនៅខាងស្តាំដៃរបស់ Menu ទាំងមូល(រូបភាពទី១៣)។ ផ្ទាំងដែលស្ថិតនៅខាងស្តាំនោះមានសេចក្តីលម្អិតអំពីការជ្រើសរើសពេលវេលា (ខែ ឆ្នាំ) ការជ្រើសរើសថ្នាក់ (ថ្នាក់ជាតិ ថ្នាក់ស្រុកប្រតិបត្តិ ថ្នាក់មន្ទីរពេទ្យ......) និងការជ្រើសរើសទីកន្លែង (ខេត្ត ស្រុកប្រតិបត្តិ មូលដ្ឋានសុខាភិបាល) ។

ឧទាហរណ៍៖ អ្នកធ្វើរបាយការណ៍មួយដោយរើសយកឆ្នាំ ២០១១ ខែមករា ដល់ខែមិថុនារបស់ទម្រង់សម្រាប់មណ្ឌលនៃមណ្ឌលសុខភាពកំពង់ស្វាយ។

ក្រោយពេលអ្នកឃើញផ្ទាំងរបាយការណ៍បង្ហាញហើយ អ្នកអាចចាប់ផ្តើមទាញយករបាយការណ៍មកប្រើប្រាស់បានដោយគ្រាន់តែ៖

- សូមអ្នកជ្រើសរើសពេលវេលារបស់របាយការណ៍ ដែលអ្នកបម្រុងនិងទាញយក(សូមមើល លេខ២ រូបភាពទី១៣)។ នៅក្នុង Menu របស់របាយការណ៍អ្នកអាចជ្រើសរើសយកឆ្នាំណាមួយ ដែលស្របតាមតម្រូវការ ហើយអ្នកក៏អាចជ្រើសរើសខែតាមតម្រូវការដូចគ្នាផងដែរ។
- តមកទៀតអ្នកចាប់ផ្តើមជ្រើសរើសថ្នាក់មូលដ្ឋានសុខាភិបាល ដែលអ្នកចង់បាន (សូមមើលលេខ៣ រូបភាព១៣)
- រួចហើយអ្នកចាប់ផ្តើមរើសយកមូលដ្ឋានសុខាភិបាលណាមួយ ដែលអ្នកត្រូវការដោយជ្រើសរើសយកខេត្ត និងស្រុកប្រតិបត្តិរបស់មូលដ្ឋានសុខាភិបាលតាំងនៅ ជាចុងក្រោយអ្នកអាចជ្រើសរើសយកមូលដ្ឋានសុខាភិបាលនោះ(សូមមើលលេខ៤ រូបភាពទី១៣)។
- ជាជំហានចុងក្រោយអ្នកត្រូវចុចលើប្រអប់*ចាប់ផ្តើមបំលែងរបាយការណ៍* (សូមមើលលេខ៥ រូបភាពទី១៣) របាយការណ៍របស់អ្នកនិងត្រូវបានបំលែងជាFile Excel (ដូចរូបភាពទី១៤)

រូបភាពទី១៣ (របៀបចូលជ្រើសរើសរបាយការណ៍)



ក្រោយពេលអ្នកចាប់ផ្តើមបំលែងរបាយការណ៍រួចមកពេលនោះអ្នកនិងបានឃើញផ្ទាំងមួយជាFile Excel (សូមមើលលេខ១ រូបភាពទី១៤)លេចឡើងមក។

- បន្ទាប់មកអ្នកត្រូវចុចលើពាក្យOpen with ក្នុងករណីបើអ្នកចង់បើកមើល (សូមមើលលេខ២ រូបភាពទី១៤) ឬក៏
- អ្នកអាចចុចលើពាក្យ Save file (អ្នកអាចរក្សារទុកក្នុងMy document, Desktop ឬក៏កន្លែងណាមួយដែលអ្នកអាចស្វែងរកដោយងាយ) (សូមមើលលេខ៣ រូបភាពទី១៤)
- បន្ទាប់មកសូចចុចលើពាក្យ OK (សូមមើលលេខ៤ រូបភាពទី១៤)

រូបភាពទី ទី១៤ (ការបង្ហាញជាទម្រង់រក្សារទុកក្នុង Excel File)



ជាលទ្ធផលផ្ទាំងរបាយការណ៍និងបង្ហាញឡើងជាទម្រង់ Excel ដូចខាងក្រោម (រូបភាពទី១៥)

រូបភាពទី១៥ (ទម្រង់របាយការណ៍ ANC & Birth Spacing មណ្ឌលសុខភាពExcel)



1	ព្រះរាជាណាចក្រកម្ពុជា	
2	ជាតិ សាសនា ព្រះមហាក្សត្រ	
3	ក្រសួងសុខាភិបាល	
4	ទម្រង់របាយការណ៍ PMTCT / LINKED RESPONSE	
5	ឧទាហរណ៍មណ្ឌលសុខភាព កំពង់ស្វាយ ពីខែមករា ដល់ ខែមិថុនា ឆ្នាំ ២០១១	
6	ផ្នែកទី១-ព័ត៌មានពីសេវាពិនិត្យផ្ទៃពោះ	សរុប
7	១.ការធ្វើតេស្តឈាមចំពោះស្ត្រីមានផ្ទៃពោះ	
8	១-ចំនួនស្ត្រីមកពិនិត្យផ្ទៃពោះលើកទី១ទាំងអស់	418
9	១.១-ចំនួនស្ត្រីមកពិនិត្យផ្ទៃពោះលើកទី១ទាំងអស់នៅមណ្ឌលសុខភាព	418
10	១.២-ចំនួនស្ត្រីមកពិនិត្យផ្ទៃពោះលើកទី១ទាំងអស់នៅតាមមូលដ្ឋាន	0
11	២-ចំនួនស្ត្រីមកពិនិត្យផ្ទៃពោះលើកទី៤	109
12	៣-ចំនួនស្ត្រីផ្ទៃពោះដែលដឹងពីស្ថានភាពមេរោគអេដស៍រួចហើយនៅអំឡុងពេលមានផ្ទៃពោះលើកនេះ	0
13	៣.១-ចំនួនស្ត្រីផ្ទៃពោះដែលមានលទ្ធផលតេស្តមេរោគអេដស៍វិជ្ជមាននៅអំឡុងពេលមានផ្ទៃពោះលើកនេះ	0
14	៣.២-ចំនួនស្ត្រីផ្ទៃពោះដែលមានលទ្ធផលតេស្តមេរោគអេដស៍វិជ្ជមាន(មកដោយខ្លួនឯង/បញ្ជូនពីសេវាផ្សេង)	0
15	៤-ចំនួនសំណាកឈាមរបស់ស្ត្រីផ្ទៃពោះដែលបញ្ជូនទៅមន្ទីរពិសោធន៍	251
41	១៣-ចំនួនអ្នកជំងឺកាមរោគបានធ្វើតេស្តឈាមរកមេរោគអេដស៍	0
42	១៤-ចំនួនអ្នកជំងឺកាមរោគបានទទួលលទ្ធផលតេស្តឈាមរកមេរោគអេដស៍	0
43	១៤.១-ចំនួនអ្នកជំងឺកាមរោគដែលវិជ្ជមានមេរោគអេដស៍	0
44	១៥-ចំនួនអ្នកផ្សេងៗទៀតបានធ្វើតេស្តឈាមរកមេរោគអេដស៍(បញ្ជូនសំណាកឈាមទៅមន្ទីរពិសោធន៍)	17
45	១៦-ចំនួនអ្នកផ្សេងៗទៀតដែលបានមកទទួលលទ្ធផលតេស្តឈាមរកមេរោគអេដស៍	12
46	១៦.១-ចំនួនអ្នកផ្សេងៗទៀតដែលវិជ្ជមានមេរោគអេដស៍	1
47	៤.ការពន្យារកំណើត	
48	១៧-ចំនួនស្ត្រីផ្ទុកមេរោគអេដស៍បានប្រើមធ្យោបាយពន្យារកំណើតទំនើប(កំពុងប្រើ)	10
49	១៧.១-ចំនួនស្ត្រីផ្ទុកមេរោគអេដស៍បានចាប់ផ្តើមប្រើមធ្យោបាយពន្យារកំណើតទំនើបបន្ទាប់ពីសម្រាលកូនបាន៦សប្ដា	0
50	ផ្នែកទី២-ការសម្រាលនិងការថែទាំក្រោយពេលសម្រាល	
51	១.ការថែទាំ-ការព្យាបាលនៅពេលសម្រាល	
52	១-ចំនួនម្តាយដែលមកសម្រាលកូននៅមណ្ឌលសុខភាព	106
53	១.១-ចំនួនម្តាយដែលមកសម្រាលកូនបានដឹងពីស្ថានភាពមេរោគអេដស៍	100
54	១.១.១-ចំនួនម្តាយមានផ្ទុកមេរោគអេដស៍ដែលមកសម្រាលកូន	0
55	១.២-ចំនួនម្តាយដែលមកសម្រាលកូនមិនបានដឹងពីស្ថានភាពមេរោគអេដស៍	6
56	២.ការថែទាំ-ការព្យាបាលក្រោយពេលសម្រាល	
57	២-ចំនួនម្តាយដែលបានទទួលការថែទាំក្រោយសម្រាលយ៉ាងហោចណាស់២ដងរួមទាំងស្ត្រីផ្ទុកមេរោគអេដស៍	149

ចំណាំ៖ ដោយប្រើប្រាស់របៀបដូចគ្នាតាមការបង្ហាញជូនខាងលើ អ្នកទាញយករបាយការណ៍ណាមួយដែលអ្នកចង់បាន ដូចជា៖

1. *របាយការណ៍សរុបតាមទម្រង់នីមួយៗ*
2. *របាយការណ៍លម្អិតតម្រៀបតាមខែ*
3. *របាយការណ៍លម្អិតតម្រៀបតាមមូលដ្ឋានសុខាភិបាល*
4. *របាយការណ៍លម្អិតតម្រៀបតាមខែ និងមូលដ្ឋានសុខាភិបាល*
5. *របាយការណ៍លម្អិតតម្រៀបតាមសូចនាករ និងមូលដ្ឋានសុខាភិបាល*
6. *របាយការណ៍សូចនាករ*

រូបភាពទី១៥.១ (ទម្រង់របាយការណ៍របស់ផ្នែកសម្ភព Excel)



ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសុខាភិបាល

ទម្រង់របាយការណ៍ PMTCT / LINKED RESPONSE

ទម្រង់មណ្ឌលសុខភាព គំពង់ស្វាយ ផ្នែកសម្ភព ប្រចាំខែ: មករា ឆ្នាំ ២០១១

6	ផ្នែកទី២-ការសម្រាលនិងការថែទាំក្រោយពេលសម្រាល	សរុប
7	១.ការថែទាំ-ការព្យាបាលនៅពេលសម្រាល	
8	១-ចំនួនម្តាយដែលមកសម្រាលកូននៅមន្ទីរពេទ្យ	16
9	១.១-ចំនួនម្តាយដែលមកសម្រាលកូនបានដឹងពីស្ថានភាពមេរោគអេដស៍មុនពេលសម្រាល	16
10	១.១.១-ចំនួនម្តាយមានផ្ទុកមេរោគអេដស៍	0
11	១.១.១.១-ចំនួនម្តាយដែលបានទទួលការព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍	0
12	១.១.១.២-ចំនួនម្តាយដែលបានទទួលការបង្ការដោយឱសថប្រឆាំងមេរោគអេដស៍ (៣មុខ)	0
13	១.១.១.៣-ចំនួនម្តាយដែលបានទទួលឱសថបង្ការតែនៅពេលឈឺពោះ/ក្រោយពេលសម្រាល	0
14	១.២-ចំនួនម្តាយដែលមកសម្រាលកូនមិនបានដឹងពីស្ថានភាពមេរោគអេដស៍	0
11	១.១.១.១-ចំនួនម្តាយដែលបានទទួលការព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍	0
12	១.១.១.២-ចំនួនម្តាយដែលបានទទួលការបង្ការដោយឱសថប្រឆាំងមេរោគអេដស៍ (៣មុខ)	0
13	១.១.១.៣-ចំនួនម្តាយដែលបានទទួលឱសថបង្ការតែនៅពេលឈឺពោះ/ក្រោយពេលសម្រាល	0
14	១.២-ចំនួនម្តាយដែលមកសម្រាលកូនមិនបានដឹងពីស្ថានភាពមេរោគអេដស៍	0
15	១.២.១-ចំនួនម្តាយបានធ្វើតេស្តឈាមនិងទទួលលទ្ធផលតេស្តនៅពេលសម្រាល	0
16	១.២.១.១-ចំនួនម្តាយមានលទ្ធផលតេស្តឈាមវិជ្ជមានមេរោគអេដស៍	0
17	១.២.១.១.១-ចំនួនម្តាយបានទទួលឱសថបង្ការនៅពេលឈឺពោះ/ក្រោយសម្រាល	0
18	២-ចំនួនម្តាយផ្ទុកមេរោគអេដស៍ដែលបានសម្រាលកូននៅមន្ទីរពេទ្យ (១.១.១ + ១.២.១.១)	0
19	៣-ចំនួនម្តាយមានផ្ទុកមេរោគអេដស៍ដែលបានសម្រាលកូននៅមណ្ឌលសុខភាព	0
20	៤-ចំនួនទារកប្រឈមដែលកើតពីម្តាយមានផ្ទុកមេរោគអេដស៍	0
21	៤.១-ចំនួនទារកដែលស្លាប់មុនកើត និងស្លាប់ក្រោយកើត(នៅមន្ទីរសម្ភព)	0
22	៥-ចំនួនទារកប្រឈមបានទទួលឱសថ ARV បង្ការ៦សប្តាហ៍	0
23	៦-ចំនួនម្តាយផ្ទុកមេរោគអេដស៍ដែលបានទទួលការផ្តល់ប្រឹក្សាពីការចិញ្ចឹមកូន	0
24	៦.១-ចំនួនម្តាយដែលមានបំណងនឹងចិញ្ចឹមកូនដោយទឹកដោះម្តាយ	0
25	៦.២-ចំនួនម្តាយដែលមានបំណងនឹងចិញ្ចឹមកូនដោយទឹកដោះគោម្សៅ	0
26	២.ការថែទាំ-ការព្យាបាលក្រោយពេលសម្រាល	
27	៧-ចំនួនម្តាយដែលបានទទួលការថែទាំក្រោយសម្រាលយ៉ាងហោចណាស់២ដងរួមទាំងស្ត្រីផ្ទុកមេរោគអេដស៍	0

រូបភាពទី១៥.២ (ទម្រង់របាយការណ៍OI/ART)



ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសុខាភិបាល

ទម្រង់របាយការណ៍ PMTCT / LINKED RESPONSE

ទម្រង់មណ្ឌលសុខភាព កំពង់ស្វាយ ផ្នែកសម្ភព ប្រចាំខែ: មករា ឆ្នាំ ២០១១

ឈ្មោះមន្ទីរពេទ្យ............................ ស្រុកប្រតិបត្តិ..ខេត្ត/ក្រុង..........................

ផ្នែកទី៣-ព័ត៌មាន OI/ART កុមារប្រឈម	សរុប
៤-ចំនួនកុមារប្រឈមដែលបានរាយការណ៍ថាបានទទួលស៊ីរ៉ូ NVP ឬ AZT រាល់ថ្ងៃតាំងពីកើតរហូតដល់អាយុ៦សប្តាហ៍	0
៥-ចំនួនកុមារប្រឈមកើតពីម្តាយមានផ្ទុកមេរោគអេដស៍ចាប់ផ្តើមប្រើ CTx បង្ការនៅមុនអាយុ២ខែ	0
៦-ចំនួនកុមារប្រឈមដែលបានរាយការណ៍ថាបានចិញ្ចឹមដោយទឹកដោះម្តាយសុទ្ធនៅអាយុ៦ខែ	0
៧-ចំនួនកុមារប្រឈមដែលបានរាយការណ៍ថាបានចិញ្ចឹមដោយទឹកដោះសិប្បនិម្មិតនៅអាយុ៦ខែ	0
៩.៣.១.១-ចំនួនធ្វើតេស្តបញ្ជាក់លើលទ្ធផលHIV-DNA-PCR ក្នុងករណីមានរោគសញ្ញាជំងឺនិកាសនិយម (វិជ្ជមាន)	0
៩.៣.១.១.១-ចំនួនលទ្ធផលតេស្តបញ្ជាក់វិជ្ជមាន	0
៩.៤-ចំនួនកុមារប្រឈមបានទទួលការធ្វើតេស្តអង្គបដិបក្ខ HIV (Antibody Test)	0
៩.៤.១-ចំនួនលទ្ធផលតេស្ត HIV វិជ្ជមាន	0
១០-ចំនួនកុមារប្រឈមស្លាប់ក្នុងអំឡុងពេលតាមដាន	0

ថ្ងៃទី ខែ ឆ្នាំ ២០១១

បានឃើញនិងឯកភាព ប្រធានមន្ទីរពេទ្យ   បានពិនិត្យនិងបញ្ជូន   អ្នកធ្វើរបាយការណ៍

គោលការណ៍ណែនាំ
សម្រាប់ការគ្រប់គ្រងប្រព័ន្ធព័ត៌មានវិទ្យាសុខាភិបាលកម្ពុជា
តាមរយៈគេហទំព័រ

✵✵✵✵✵

ជំពូក ៤
ប្រព័ន្ធគ្រប់គ្រងទិន្នន័យមរណភាពមាតា

វត្ថុបំណង

មូលដ្ឋានទិន្នន័យស្តីពីមរណៈភាពមាតាប្រើសម្រាប់ត្រួតពិនិត្យ និងតាមដានការទទួលមរណៈភាពរបស់មាតានៅតាមមូលដ្ឋានសុខាភិបាលក្នុងកំឡុងពេល និងក្រោយសំរាល។

១. ការចាប់ផ្តើមដំណើរគេហទំព័រ

- សូមវាយបញ្ចូលឈ្មោះរបស់គេហទំព័រ www.hiscambodia.org (មើលរូបភាព១ លេខ១)
- បន្ទាប់មកវាយឈ្មោះដែលត្រូវបានផ្តល់ឲ្យសម្រាប់ប្រើក្នុងប្រព័ន្ធទៅក្នុងប្រអប់ "ឈ្មោះអ្នកប្រើ" *ឧទាហរណ៍៖ ybunyeu* (មើលរូបភាព១ លេខ២)
- ជំហានមួយទៀតអ្នកត្រូវវាយលេខសំងាត់ដែលបានផ្តល់ជូនចូលទៅក្នុងប្រអប់ "លេខសំងាត់" *ឧទាហរណ៍៖ ១២៣៤៥៦* (មើលរូបភាព១ លេខ៣)
- អ្វីដែលអ្នកត្រូវធ្វើបន្តទៀតគឺវាយបញ្ចូលលេខកូដបញ្ជាក់ចូលទៅក្នុងប្រអប់ "កូដបញ្ជាក់" (មើលរូបភាព១ លេខ៤)។ *ឧទាហរណ៍៖ ៣២៧៥៩*
- រួចចុចលើពាក្យចូលប្រើប្រាស់ (រូបភាព១ លេខ៥)

រូបភាព១ (គេហទំព័ររបស់ប្រព័ន្ធព័ត៌មានវិទ្យាសុខាភិបាល)



រូបភាព២ (របៀបជ្រើសរើសប្រព័ន្ធគ្រប់គ្រងទិន្នន័យ)

រូបភាព២.១ (រូបភាពរបស់ប្រព័ន្ធទិន្នន័យស្តីពីមរណៈភាពមាតា)



២. បង្ហាញទិន្នន័យមរណៈភាពមាតា

“បង្ហាញទិន្នន័យ” មានមុខងារក្នុងការបង្ហាញទិន្នន័យរបស់មរណៈមាតាតាមគ្រប់ថ្នាក់នៃមូលដ្ឋានសុខាភិបាលទូទាំងប្រទេស។

- ជាតំបូងអ្នកត្រូវដាក់ Mouse លើពាក្យ “បង្ហាញទិន្នន័យ” (មើលរូបភាព៣ លេខ១)
- បន្ទាប់មកចុចលើពាក្យ “សម្រង់ព័ត៌មានស្តីពីមរណៈមាតា” (មើលរូបភាព៣ លេខ២)ជាលទ្ធផល (ផ្ទាំងរូបភាព៣.១) និងបង្ហាញឡើង

រូបភាព៣ (របៀបជ្រើសរើសការបង្ហាញទិន្នន័យ)



- ជាតំបូងអ្នកត្រូវជ្រើសរើសក្នុងប្រអប់ “របាយការណ៍ពី” (មើលរូបភាព៣.១ លេខ១)
- អ្នកអាចវាយឈ្មោះស្ត្រីដែលបានទទួលមរណៈភាព (ក្នុងករណីអ្នកស្គាល់ ប៉ុន្តែអ្នកអាចរំលងចោល ក្នុងករណីដែលអ្នកមិនស្គាល់ ឬអ្នកចង់បានចំនួនច្រើន)
- រួចចុចលើប្រអប់ “កាលៈទេសៈនៃមរណៈភាព” (មើលរូបភាព៣.១ លេខ២)
- បន្ទាប់មកអ្នកត្រូវជ្រើសរើសយក “ទីកន្លែងមរណៈភាព” (មើលរូបភាព៣.១ លេខ៣)
- និងចុចលើប្រអប់ “កំឡុងពេលទទួលមរណៈភាព” ដើម្បីជ្រើសរើសរយៈពេលដែលអ្នកចង់បាន (មើលរូបភាព៣.១ លេខ៤ លេខ៥ និងលេខ៦)
- សូមចុចលើប្រអប់ “កំពុងតាមដានបន្ត?” ក្នុងករណីដែលអ្នកចង់ដឹងថា ករណីស្លាប់នេះកំពុងតាមដានបន្ត ឬមិនមែន (មើលរូបភាព៣.១ លេខ៧)
- ជាចុងក្រោយ អ្នកត្រូវចុចលើប្រអប់ “ស្វែងរក” ដើម្បីទទួលបានទិន្នន័យ (មើលរូបភាព៣.១ លេខ៨) ជាលទ្ធផលរបាយការណ៍នឹងបង្ហាញដូចក្នុងរូបភាព៤

រូបភាព៣.១ (របៀបជ្រើសរើស ដើម្បីស្វែងរកព័ត៌មានមរណៈភាពមាតា)



តាមរយៈព័ត៌មានទូទៅស្តីពីមរណៈភាពមាតាអ្នកអាច ៖

- ពិនិត្យមើលឈ្មោះរបស់ស្ត្រីម្នាក់ដែលបានទទួលមរណៈភាពជា Excel ដោយគ្រាន់តែអ្នកចុចលើប្រអប់ "Excel" (មើលរូបភាព៣.២ លេខ១)
- អ្នកក៏អាចពិនិត្យមើលព័ត៌មានលម្អិតរបស់ស្ត្រីដែលបានទទួលមរណៈភាព ដោយគ្រាន់តែអ្នក ចុចលើប្រអប់ "លម្អិត" (មើលរូបភាព៣.២ លេខ២)
- បន្ទាប់មកអ្នកក៏អាចបំលែងព័ត៌មានទូទៅស្តីពីមរណៈភាពរបស់មាតាទៅជា Excel (មើលរូបភាព៣.២ លេខ៣)

រូបភាព៣.២ (តារាងព័ត៌មានទូទៅស្តីពីមរណៈ ភាពរបស់មាតាទូទាំងប្រទេស)



លរ	ឈ្មោះស្ត្រីទទួលមរណៈភាព	អាយុ	ចំនួននៃផ្ទៃពោះ	ថ្ងៃ ខែ ឆ្នាំ ទទួលមរណៈភាព	ប្ដីឈ្មោះ	ទូរស័ព្ទប្ដី	តាមដាន?	Excel	លំអិត
1	ឃុន សាវឿន	28	2	03 / មិនា / 2011	ឡុង ចំរើ	0859331		Excel	លំអិត
2	ហួត លី	29	3	05 / មិនា / 2011				Excel	លំអិត
3	អួន ស្រីនីត	30	1	14 / មិនា / 2011	ម៉ាន សុខុម			Excel	លំអិត
4	ជឹម លីដា	22	1	23 / មិនា / 2011				Excel	លំអិត
5	អូ ដាវី	23	1	02 / កុម្ភៈ / 2011				Excel	លំអិត
6	នៅ ព៉ង	29	1	15 / មករា / 2011				Excel	លំអិត
7	សាម ឌីជីនៀត	23	1	04 / មករា / 2011				Excel	លំអិត
8	យក់ សាផន	27	4	10 / មេសា / 2011	មៀយ អ៊ឹម			Excel	លំអិត
9	ពុំ ឆេងហុង	32	5	27 / មិនា / 2011	គង ពុំ			Excel	លំអិត
10	អែម តា	29	2	18 / មិនា / 2011	អាត អួន			Excel	លំអិត
11	ណែម ចឺ	28	6	07 / មិនា / 2011	ញ៉ាំ តា			Excel	លំអិត
12	ចិន ចាន់ថា	40	9	11 / មករា / 2011				Excel	លំអិត
13	សុខ ស៊ីថា	40	9	11 / មករា / 2011				Excel	លំអិត
14	ពៅ សាផន	24	1	21 / មិនា / 2011				Excel	លំអិត
15	អ៊ិក ពុម	47	2	21 / មិនា / 2011				Excel	លំអិត
16	អ៊ិក សោភ័ណ្ឌ	41	4	04 / មករា / 2011				Excel	លំអិត
17	អួន ហ៊ត	23	1	12 / មករា / 2011				Excel	លំអិត
18	ឆេ នៀត	24	1	05 / កុម្ភៈ / 2011	គេង ថា			Excel	លំអិត
19	ភិន ណយ	26	1	23 / មករា / 2011	ជា ណុល			Excel	លំអិត
20	កាយ ពៀន	30	1	26 / មករា / 2011				Excel	លំអិត
21	ខុម ទុំ	33	4	13 / កុម្ភៈ / 2011				Excel	លំអិត
22	លាត ម៉ៅ	32	4	24 / កុម្ភៈ / 2011	ឆេង សេង			Excel	លំអិត
23	ជុច ផន	35	3	17 / មិនា / 2011				Excel	លំអិត
24	អឿន សាំង	26	2	17 / មេសា / 2011				Excel	លំអិត
25	ណឹម សំអាង	36	5	28 / មិនា / 2011				Excel	លំអិត
26	ជ្រឹង ច្រឹប	44	4	02 / មេសា / 2011	លួ សាវឿន			Excel	លំអិត
27	សោម សាផន	41	4	16 / មេសា / 2011	ផាត			Excel	លំអិត
28	ស៊ឹង សុផាត	35	2	03 / មេសា / 2011	លី ហ៊ុន			Excel	លំអិត
29	ហូ ចាន់	37	4	03 / មករា / 2011				Excel	លំអិត
30	យ៉ាន មុំ	36	3	02 / មិនា / 2011	គង់ គន			Excel	លំអិត
31	អ៊ិន រី	46	12	03 / មេសា / 2011	ញឹក ម៉េង			Excel	លំអិត
32	យឹម នួន	37	7	30 / មិនា / 2011	ជុយ			Excel	លំអិត
33	ជឹង ឆន	24	2	22 / មិនា / 2011	លិន លន	092 692104		Excel	លំអិត
34	ឆែម ហុច	38	7	25 / កុម្ភៈ / 2011	ណែម ផន			Excel	លំអិត
35	ឡុង វណ្ណាព៍	29	2	18 / មេសា / 2011	ជា សាមឿន			Excel	លំអិត
36	ម៉េង ស្រីពៅ	24	2	07 / មករា / 2011	ជា ពេជ្រ			Excel	លំអិត
37	វៀន ស្រីពៅ	26	5	18 / មករា / 2011	អ៊ុល ចំរ៉ុង			Excel	លំអិត
38	សំ យ៉ា	29	5	06 / កុម្ភៈ / 2011	ឃុត យឹម			Excel	លំអិត
39	គុណ សុភាព	28	2	02 / មិនា / 2011				Excel	លំអិត
40	អែល សុផុន	41	7	08 / មិនា / 2011	វៀម ឡាវ			Excel	លំអិត
41	ផន ឡុង	21	5	15 / មិនា / 2011	ណុប ចំនួរញ៉			Excel	លំអិត
42	ជុំ ភឿន	32	4	18 / មិនា / 2011	សុខ ណាត			Excel	លំអិត
43	ទី សៅហ៊ាន	26	2	08 / មិនា / 2011				Excel	លំអិត
44	ព្រាប សុផាត	19	1	23 / មិនា / 2011				Excel	លំអិត
45	ឡៀង ធីចាវ	45	3	30 / មិនា / 2011				Excel	លំអិត

រូបភាព៣.៣ (តារាងព័ត៌មានទូទៅស្តីពីមរណៈ ភាពរបស់មាតាជា Excel)



លរ	ហេតុការណ៍ពី	ថ្ងៃ ខែ ឆ្នាំ ធ្វើហេតុការណ៍	ឈ្មោះស្ត្រី	អាយុ	ថ្ងៃ ខែ ឆ្នាំ ទទួលមរណៈភាព	ផ្ទៃពោះទី	ស្វាមីឈ្មោះ	លេខទូរស័ព្ទ	អ្នកនៅជាមួយពេលស្លា
1	បន្ទាយមានជ័យ	06 / មិនា / 2011	យុន សារឿន	28	03 / មិនា / 2011	2	ឡុង ប៊ីវ	៨៥៩៣៣១	
2	បន្ទាយមានជ័យ	17 / មិនា / 2011	ហួត លី	29	05 / មិនា / 2011	3			
3	បន្ទាយមានជ័យ	18 / មិនា / 2011	អួន ស្រីនីត	30	14 / មិនា / 2011	1	ម៉ាន សុខុម		
4	បាត់ដំបង	25 / មិនា / 2011	ជឹម លីដា	22	23 / មិនា / 2011	1			
5	បាត់ដំបង	25 / មិនា / 2011	អ៊ូ ដាវី	23	02 / កុម្ភៈ / 2011	1			
6	បាត់ដំបង	25 / មិនា / 2011	នៅ រ៉េង	29	15 / មករា / 2011	1			
7	បាត់ដំបង	25 / មិនា / 2011	សាម នីជីនៀត	23	04 / មករា / 2011	1			
8	កំពង់ចាម	26 / មេសា / 2011	យក់ សារ៉េន	27	10 / មេសា / 2011	4	មៀយ អ៊ឹម		
9	កំពង់ចាម	26 / មេសា / 2011	ពុំ ឆេងហុង	32	27 / មិនា / 2011	5	គង់ ពុំ		
10	កំពង់ចាម	26 / មេសា / 2011	អែម គា	29	18 / មិនា / 2011	2	អាត អួន		
11	កំពង់ឆ្នាំង	18 / មិនា / 2011	ណែម ប៊ី	28	07 / មិនា / 2011	6	ញ៉ាំ ភា		
12	កំពង់ស្ពឺ	12 / មករា / 2011	ប៊ិន ចាន់ថា	40	11 / មករា / 2011	9			
13	កំពង់ស្ពឺ	23 / មិនា / 2011	សុខ ស៊ីថា	40	11 / មករា / 2011	9			
14	កំពង់ស្ពឺ	23 / មិនា / 2011	ពៅ សារ៉េន	24	21 / មិនា / 2011	1			
15	កំពង់ស្ពឺ	23 / មិនា / 2011	អ៊ិក ពុម	47	21 / មិនា / 2011	2			
16	កំពង់ធំ	10 / មករា / 2011	អ៊ិក សោភ័ណ្ឌ	41	04 / មករា / 2011	4			
17	កំពង់ធំ	01 / កុម្ភៈ / 2011	អួន ហ៊ត	23	12 / មករា / 2011	1			
18	កំពង់ធំ	07 / កុម្ភៈ / 2011	ឆេ នៀត	24	05 / កុម្ភៈ / 2011	1	គេង ថា		
19	កំពង់ធំ	08 / កុម្ភៈ / 2011	ភិន ណយ	26	23 / មករា / 2011	1	ផា ណុល		
20	កំពង់ធំ	08 / កុម្ភៈ / 2011	កាយ រឿន	30	26 / មករា / 2011	1			
21	កំពង់ធំ	16 / កុម្ភៈ / 2011	ខុម ទុំ	33	13 / កុម្ភៈ / 2011	4			
22	កំពង់ធំ	02 / មិនា / 2011	ណាត ម៉ៅ	32	24 / កុម្ភៈ / 2011	4	ឆេង សេង		
23	កំពង់ធំ	27 / មេសា / 2011	ផុច ផន	35	17 / មិនា / 2011	3			
24	កំពង់ធំ	27 / មេសា / 2011	អឿន សាំង	26	17 / មេសា / 2011	2			
25	កំពត	25 / សីហា / 2011	ហេង សុខលី	43	23 / កក្កដា / 2011	6	អ៊ូ ពុធ		
26	កណ្តាល	04 / មេសា / 2011	ណឹម សំអាង	36	28 / មិនា / 2011	5			
27	កណ្តាល	08 / មេសា / 2011	ជ្រឹង ច្រឹប	44	02 / មេសា / 2011	4	លូ សារឿន		
28	ក្រចេះ	28 / មេសា / 2011	សោម សារ៉េន	41	16 / មេសា / 2011	4	ផាត		
29	ក្រចេះ	28 / មេសា / 2011	ស៊ឹង សុផាត	35	03 / មេសា / 2011	2	លី ហ៊ុន		
30	ព្រៃវែង	27 / មេសា / 2011	ហ៊ូ ចាន់	37	03 / មករា / 2011	4			
31	ពោធិ៍សាត់	03 / មិនា / 2011	យ៉ាន មុំ	36	02 / មិនា / 2011	3	គង់ គន		

រូបភាព៣.៤ (តារាងរបស់របាយការណ៍បន្ទាន់ស្តីពីមរណៈភាពមាតានៅលើគេហទំព័រ)

រូបភាព៣.៥ (តារាងជា Excel របស់របាយការណ៍បន្ទាន់ស្តីពីមរណៈភាពមាតា)



៣. បញ្ចូលទិន្នន័យ

៣.១. បញ្ចូលទិន្នន័យទូទៅរបស់មរណៈភាពមាតា

បញ្ចូលទិន្នន័យមានតួនាទីក្នុងការទទួលយកទិន្នន័យទាំងអស់ដែលមិនទាន់បានបញ្ចូលជាពិសេសទិន្នន័យសម្រាប់ការទទួលមរណៈភាពរបស់មាតាថ្មីៗ។

របៀបប្រើប្រាស់

- ជាបឋមអ្នកត្រូវចូលទៅកាន់ "Menu" បញ្ចូលទិន្នន័យ (មើលរូបភាព៤ លេខ១)
- រួចហើយអ្នកត្រូវចុចលើប្រអប់ "សម្រង់ព័ត៌មានស្តីពីមរណៈភាពមាតា" (មើលរូបភាព៤ លេខ២) ជាផ្ទាំងសម្រាប់បញ្ចូលទិន្នន័យនឹងត្រូវបង្ហាញដូចរូបភាព៥.១

រូបភាព៨ (របៀបនៃការចូលទៅកាន់ Menu បញ្ចូលទិន្នន័យ)



ការបញ្ចូលព័ត៌មានទូទៅស្តីពីមរណៈភាពមាតា (មើលរូបភាព៨.១) មិនមានលក្ខណៈស្មុគស្មាញអ្វីនោះទេ។ អ្នកអាចបញ្ចូលទៅតាមព័ត៌មានលម្អិតដូចដែលអ្នកបានឃើញក្នុងតារាងស្រាប់។

- អ្នកត្រូវតែជ្រើសរើសប្រភេទនៃរបាយការណ៍ (មើលរូបភាព៨.១ លេខ១)
- បន្ទាប់មកជ្រើសរើសតាមពេលវេលានៃរបាយការណ៍ដែលអ្នកត្រូវបញ្ចូល (មើលរូបភាព៨.១ លេខ២)
- អ្នកត្រូវបំពេញរបាយការណ៍នេះឲ្យបានគ្រប់ជ្រុងជ្រោយមុនពេលដែលអ្នកចុចប្រអប់រក្សាទុក មើលរូបភាព៨.១ លេខ៣)

ចំណាំ៖ ការបញ្ចូលទិន្នន័យត្រូវធ្វើជាប្រចាំសប្តាហ៍ គឺនៅរៀងរាល់ថ្ងៃអង្គារ។

រូបភាព៤.១ (តារាងបញ្ចូលព័ត៌មានទូទៅស្តីពីមរណៈភាពមាតា)



៣.២. បញ្ចូលទិន្នន័យរបាយការណ៍ប្រចាំសប្តាហ៍ស្តីពីមរណៈភាពមាតា

បញ្ចូលទិន្នន័យរបស់របាយការណ៍ប្រចាំសប្តាហ៍ស្តីពីមរណៈភាពមាតាមានតួនាទីក្នុងការទទួលយកទិន្នន័យទាំងអស់ដែលមិនទាន់បានបញ្ចូល ជាពិសេសទិន្នន័យប្រចាំអាទិត្យនៃការទទួលមរណៈភាពរបស់មាតា។

របៀបជ្រើសរើស

- ដាក់ Mouse នៅលើ Menu បញ្ចូលទិន្នន័យ (មើលរូបភាព៥ លេខ១)
- បន្ទាប់មកចុចលើ “របាយការណ៍ប្រចាំសប្តាហ៍ស្តីពីមរណៈភាពមាតា” (មើលរូបភាព៥ លេខ២) អ្នកនឹងឃើញផ្ទាំងមួយដូចក្នុងរូបភាព៥.១)

រូបភាព៥ (របៀបចូលទៅកាន់របាយការណ៍ប្រចាំសប្តាហ៍ស្តីពីមរណៈភាពមាតា)



របៀបបញ្ចូលទិន្នន័យ

- ទី១ ជ្រើសរើសពេលវេលារបស់របាយការណ៍ (ឆ្នាំ ខែ និងថ្ងៃ)ដែលនឹងត្រូវបញ្ចូល (មើលរូបភាព៥.១ លេខ១២ និងលេខ៣)
- ទី២ ជ្រើសរើសអង្គភាពសុខាភិបាលរបស់របាយការណ៍ដូចជា ថ្នាក់ខេត្ត ស្រុកប្រតិបត្តិ និង មូលដ្ឋានសុខាភិបាល (មើលរូបភាព៥.១ លេខ៤ និងលេខ៥)
- ទី៣ ជ្រើសរើសថ្នាក់មូលដ្ឋានសុខាភិបាលជាក់លាក់ណាមួយដែលនឹងត្រូវបញ្ចូល អាចជាថ្នាក់ខេត្ត ស្រុកប្រតិបត្តិ និងមូលដ្ឋានសុខាភិបាល (មើលរូបភាព៥.១ លេខ៦)បន្ទាប់មកចុចលើប្រអប់ “ចាប់ផ្តើម” (មើលរូបភាព៥.១ លេខ៧) ជាចុងបញ្ចប់នៃដំណើរការបង្កើតទម្រង់បញ្ចូលទិន្នន័យ។

ឧទាហរណ៍អ្នកបានបង្កើតទម្រង់សម្រាប់បញ្ចូលទិន្នន័យរបស់មន្ទីពេទ្យបាត់ដំបង ប្រចាំខែមករា ឆ្នាំ ២០១០។ ដូច្នេះទម្រង់របាយការណ៍របស់អ្នកបានបង្ហាញដូចរូបភាព៥.២

រូបភាព៥.១ (របៀបជ្រើសរើសថ្នាក់ និងពេលវេលារបស់របាយការណ៍)



រូបភាព៥.២ (ទម្រង់សម្រាប់បញ្ចូលទិន្នន័យរបស់របាយការណ៍ប្រចាំសប្តាហ៍)

៤. កែសម្រួលទិន្នន័យ

កែសម្រួលទិន្នន័យមានមុខងារក្នុងការកែទិន្នន័យទាំងឡាយដែលមិនត្រឹមត្រូវ ឬទិន្នន័យដែលអ្នកបានរក្សាទុកដោយបញ្ចូលមិនទាន់ចប់។

របៀបកែសម្រួលទិន្នន័យ

- ជ្រើសរើសក្នុងប្រអប់ "របាយការណ៍ពី" បន្ទាប់មកជ្រើសរើសថ្នាក់ដែលអ្នកចង់បាន (មើលរូបភាព៦ លេខ១)
- វាយបញ្ចូលឈ្មោះស្ត្រីដែលបានទទួលមរណៈភាព (ក្នុងករណីអ្នកស្គាល់ ប៉ុន្តែអ្នកអាចរំលងចោលក្នុងករណីដែលអ្នកមិនស្គាល់ ឬអ្នកចង់បានចំនួនច្រើន)
- ចុចលើប្រអប់ "កាលៈទេសៈនៃមរណៈភាព" (មើលរូបភាព៦ លេខ២)
- ជ្រើរើសយកកន្លែងដែលស្ត្រីទទួលមរណៈភាពក្នុងប្រអប់ "ទីកន្លែងមរណៈភាព" (រូបភាព៦ លេខ៤)
- ចុចលើប្រអប់ "កំឡុងពេលទទួលមរណៈភាព" អ្នកអាចជ្រើសរើសពីពេលវេលាតាមការចង់បាន (មើលរូបភាព៦ លេខ៥ លេខ៦ និងលេខ៧)
- ចុចលើប្រអប់ "ស្វែងរក" ដើម្បីទទួលបានទិន្នន័យ (មើលរូបភាព៦លេខ៨)
- និងចុងក្រោយសូមចុចលើប្រអប់ "កែប្រែ" (មើលរូបភាព៦ លេខ៩)ដើម្បីឈានទៅកាន់ការកែប្រែទិន្នន័យទាំងស្រុង (រូបភាពរបស់កែទិន្នន័យនឹងត្រូវបានបង្ហាញដូចរូបភាព ៦.១)

រូបភាព៦ (របៀបជ្រើសរើសព័ត៌មានមរណៈភាពមាតាដើម្បីកែទិន្នន័យ)



ដោយបានឆ្លងកាត់ដំណាក់កាលជាច្រើនដូចរៀបរាប់ជូនខាងលើរួចហើយ អ្នកអាចចាប់ផ្តើមកែប្រែទិន្នន័យរបស់អ្នកតាមចំណុចនីមួយៗ ដូចដែលមានលម្អិតនៅក្នុងតារាងស្រាប់។ ក្រោយពេលអ្នកបានបំពេញព័ត៌មានចប់សព្វគ្រប់ហើយ អ្នកត្រូវចុចប្រអប់រក្សាទុកដើម្បីធានាបានថាទិន្នន័យរបស់នឹងមិនត្រូវបានបាត់បង់ (មើលរូបភាព៦.១ លេខ១)។

រូបភាព៦.១ (របៀបកែសម្រួលព័ត៌មានទូទៅស្តីពីមរណៈភាពមាតា)



៥. របាយការណ៍

របាយការណ៍មានមុខងារក្នុងការគ្រប់គ្រងរាល់ទិន្នន័យទាំងអស់របស់ប្រព័ន្ធទិន្នន័យស្តីពីមរណៈភាពរបស់មាតា។

របៀបទាញយករបាយការណ៍

- ដាក់ Mouse លើប្រអប់ "របាយការណ៍" (មើលរូបភាព៧ លេខ១)
- បន្ទាប់មកចុចលើប្រអប់ "សម្រង់ព័ត៌មានស្តីពីមរណៈភាព" (មើលរូបភាព៧ លេខ២) ជាលទ្ធផលរបាយការណ៍នឹងបង្ហាញដូចរូបភាព៧.១

រូបភាព៧ (របៀបចូលជ្រើសរើសរបាយការណ៍សូចនាករ)



របៀបជ្រើសរើសរបាយការណ៍ (រូបភាព៧.១)

- សូមចុចប្រអប់ "ចាប់ពីខែ" ដើម្បីជ្រើសរើសខែណាមួយដែលអ្នកចង់បាន (មើលរូបភាព៧.១ លេខ១)
- សូមចុចប្រអប់ "ដល់ខែ" សម្រាប់ពេលវេលាដែលអ្នកនិងត្រូវទាញយករបាយការណ៍ (មើលរូបភាព៧.១ លេខ២)
- បន្ទាប់មកទៀតជ្រើសរើសឆ្នាំរបស់របាយការណ៍ក្នុងប្រអប់ "ឆ្នាំ" (មើលរូបភាព៧.១ លេខ៣)
- សូមចុចប្រអប់ករណីមរណៈភាពតាមខេត្តនិងប្រភេទទីកន្លែង (មើលរូបភាព៧.១ លេខ៤)
